# មុខវិជ្ជា៖
# ទែម៉ូឌីណាមិច

## កញ្ចប់សមត្ថភាពទី ១
## ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ

## ពណ៌នាអំពីមុខវិជ្ជា៖

ទែម៉ូឌីណាមិច គឺជាការសិក្សាអំពីការបំប្លែងថាមពលដែលពាក់ព័ន្ធនឹងកម្តៅ កម្មន្តមេកានិច ថាមពលក្នុងទម្រង់ផ្សេងៗ និងរបៀបដែលការបំប្លែងទាំងនេះទាក់ទងនឹងលក្ខណៈសម្បត្តិនៃរូបធាតុ។ តាមរយៈច្បាប់ទែម៉ូឌីណាមិច គេអាចស្វែងយល់ពីរបៀបដែលថាមពលនៅក្នុងប្រព័ន្ធផ្លាស់ប្តូរ និងកំណត់ថាតើប្រព័ន្ធនេះអាចកម្មន្តដែលមានប្រយោជន៍លើបរិស្ថានជុំវិញខ្លួនដែរឬទេ។ វគ្គសិក្សានេះត្រូវបានរចនាឡើងសម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រអប់រំ។ វាគ្របដណ្តប់លើគោលគំនិតជាមូលដ្ឋាន ដូចជាច្បាប់ទីសូន្យ ទីមួយ និងទីពីរនៃទែម៉ូឌីណាមិច ការផ្លាស់ប្តូរស្ថានភាពនៃរូបធាតុ ម៉ាស៊ីនកំដៅ និងទូទឹកកកជាដើម។

## លទ្ធផលសិក្សារំពឹងទុក៖

- ក្រោយពីបញ្ចប់ការសិក្សាមុខវិជ្ជានេះដោយជោគជ័យអ្នកសិក្សានឹង៖

**លទ្ធផលសិក្សារំពឹងទុកទី១៖** ពន្យល់ពីគោលការណ៍គ្រឹះនៃទែម៉ូឌីណាមិច រួមទាំងច្បាប់គ្រប់គ្រងការផ្លាស់ប្តូរថាមពល។

**លទ្ធផលសិក្សារំពឹងទុកទី២៖** ពន្យល់ពីទំនាក់ទំនងរវាងកម្តៅ កម្មន្ត និងថាមពលនៅក្នុងដំណើរការទែម៉ូឌីណាមិចផ្សេងៗ។

**លទ្ធផលសិក្សារំពឹងទុកទី៣៖** កំណត់និងពណ៌នាអំពីឥរិយាបទនៃប្រព័ន្ធទែម៉ូឌីណាមិចផ្សេងៗគ្នា ក្រោមលក្ខខណ្ឌផ្សេងៗគ្នា។

**លទ្ធផលសិក្សារំពឹងទុកទី៤៖** ពន្យល់ពីគោលគំនិតនៃទែម៉ូឌីណាមិចក្នុងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។

**លទ្ធផលសិក្សារំពឹងទុកទី៥៖** អនុវត្តបច្ចេកទេសគណិតវិទ្យាដើម្បីដោះស្រាយបញ្ហាទែម៉ូឌីណាមិច រួមទាំងការគណនាពាក់ព័ន្ធនឹងការផ្ទេរកម្តៅ កម្មន្តដែលបានធ្វើ និងការផ្លាស់ប្តូរថាមពល។

**លទ្ធផលសិក្សារំពឹងទុកទី៦៖** ប្រើប្រាស់ដ្យាក្រាម និងគំនូសតាងនៃទែម៉ូឌីណាមិច ដើម្បីវិភាគ និងបកស្រាយទិន្នន័យទាក់ទងនឹងដំណើរការទែម៉ូឌីណាមិច។

**លទ្ធផលសិក្សារំពឹងទុកទី៧៖** ប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពពេលមានការពិភាក្សាអំពីគោលគំនិត និងការរកឃើញនៃទែម៉ូឌីណាមិច តាមរយៈរបាយការណ៍ជាលាយលក្ខណ៍អក្សរ និងការធ្វើបទបង្ហាញ។

**លទ្ធផលសិក្សារំពឹងទុកទី៨៖** បង្កើតវិធីសាស្ត្រជាប្រព័ន្ធ និងវិភាគចំពោះការដោះស្រាយបញ្ហា ជាពិសេសនៅក្នុងបរិបទនៃបាតុភូតទែម៉ូឌីណាមិច។

**លទ្ធផលសិក្សារំពឹងទុកទី៩៖** បណ្តុះការចង់ដឹងចង់ឃើញ និងការទទួលស្គាល់តួនាទីនៃទែម៉ូឌីណាមិចក្នុងការសម្រួចការយល់ដឹងរបស់យើងក្នុងពិភពរូបវិទ្យា។

## របាយតម្លៃសិក្សា

- ដើម្បីបំពេញគ្រប់លក្ខខណ្ឌបញ្ចប់ការសិក្សាមុខវិជ្ជានេះ អ្នកសិក្សាត្រូវ

១. វត្តមានចូលសិក្សា ១០%

២. ការចូលរួមសកម្មភាពសិក្សា ២០%

៣. ការវាយតម្លៃកំឡុងពេលសិក្សា ៣០%

៤. ការប្រឡងបញ្ចប់មុខវិជ្ជាសិក្សា ៤០%

# អារម្ភកថា

វិស័យអប់រំ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាចាត់ទុកថាជាវិស័យអាទិភាព និងត្រូវបានធ្វើកំណែទម្រង់ជាប្រចាំ ឆ្ពោះទៅលើកកម្ពស់គុណភាពនៃការសិក្សានៅគ្រប់កម្រិត។ ក្រសួងអប់រំ យុវជន និងកីឡាបាននិងកំពុងពិនិត្យឡើងវិញកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន និងជំរុញកំណែទម្រង់សាលារៀននៅគ្រប់កម្រិត ដើម្បីធានាថាសាលារៀនមានដំណើរការប្រកបដោយប្រសិទ្ធភាពសម្រាប់ការសិក្សារៀនសូត្ររបស់សិស្ស និងផ្តល់ដល់សិស្សនូវវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា ឆ្លើយតបបានទៅតាមតម្រូវការទីផ្សារការងារ និងចូលរួមចំណែកពេញលេញក្នុងការអភិវឌ្ឍសហគមន៍ និងប្រទេសជាតិ ឈានឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ និងឆ្នាំ២០៥០ ។

ជាផ្នែកមួយនៃកំណែទម្រង់ការបណ្តុះបណ្តាលគ្រូបង្រៀន ឆ្ពោះទៅលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនតាមរយៈគម្រោងកែលម្អការអប់រំចំណេះទូទៅ ក្រសួងបានរៀបចំ "ក្របខណ្ឌកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលបរិញ្ញាបត្រអប់រំ វិជ្ជាជីវៈគ្រូបង្រៀន ឯកទេសទាំង ៦ (អក្សរសាស្ត្រខ្មែរ, គណិតវិទ្យា, គីមីវិទ្យា, ជីវវិទ្យា, រូបវិទ្យា, ប្រវត្តិវិទ្យា) ដើម្បីប្រើប្រាស់ក្នុងកម្មវិធីវិក្រឹតការគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀននៅតាមសាលារៀនចំណេះទូទៅ។ ក្របខណ្ឌកម្មវិធីសិក្សានេះជាឯកសាររស់ ដែលនឹងអាចមានការកែសម្រួលទៅតាមស្ថានភាពជាក់ស្តែង ជាពិសេសនៅដំណាក់កាលអន្តរកាលនៃការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន។

ក្រសួងមានជំនឿយ៉ាងមុតមាំ លើប្រសិទ្ធភាពនៃការអនុវត្តក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលនេះ ដែលនឹងនាំគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀននៅគ្រប់ភូមិសិក្សា សម្រេចបានគោលដៅអប់រំ ដែលនឹងចូលរួមចំណែកក្នុងការសម្រេចបានចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា។

ខ្ញុំសូមថ្លែងអំណរគុណ និងសូមកោតសរសើរដ៏ស្មោះចំពោះ ឯកឧត្តមបណ្ឌិតសភាចារ្យនាយកគម្រោង និងក្រុមការងារគម្រោងកែលម្អការអប់រំចំណេះទូទៅ ជាពិសេសក្រុមការងារនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញដែលបានខិតខំផលិតឯកសារក្របខណ្ឌកម្មវិធីសិក្សានេះឡើង សម្រាប់ប្រើប្រាស់ក្នុងការបណ្តុះបណ្តាលក្នុងគម្រោងកែលម្អការអប់រំចំណេះទូទៅ។

ថ្ងៃ ចន្ទ ៦រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែសីហា ឆ្នាំ ២០២៣

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# គណៈកម្មការ

## ១. គណៈកម្មការគ្រប់គ្រង

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិតសភាចារ្យ | **ហង់ជួន ណារ៉ុន** | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា |
| ២. ឯកឧត្តមបណ្ឌិតសភាចារ្យ | **ណាត ប៊ុនរឿន** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |
| ៣. ឯកឧត្តមបណ្ឌិត | **ជេត ជាលី** | សាកលវិទ្យាធិការសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៤. លោកបណ្ឌិត | **ឈុន ហុក** | សាកលវិទ្យាធិការរង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៥. លោក | **ប៉ាល់ ដែល** | សាកលវិទ្យាធិការរង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៦. លោកបណ្ឌិត | **សំអោ អឌ្ឍរតន៍** | អគ្គនាយករង អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ |
| ៧. លោក | **ព្រឹង មរកត** | ប្រធាននាយកដ្ឋានមធ្យមសិក្សា |

## ២. គណៈកម្មការនិពន្ធ រៀបរៀង និងចងក្រង

| | | |
|---|---|---|
| ១. លោកបណ្ឌិត | **សុខ សុទ្រា** | ព្រឹទ្ធបុរសមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ២. លោក | **មាក ភាមេរ៉ាន** | ព្រឹទ្ធបុរសមហាវិទ្យាល័យវិទ្យាសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៣. លោកបណ្ឌិត | **ជ័យ ចាន់រឿន** | ព្រឹទ្ធបុរសរងមហាវិទ្យាល័យវិទ្យាសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៤. លោកបណ្ឌិត | **ម៉ម សុជាតិ** | ព្រឹទ្ធបុរសរងមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៥. លោក | **សុត វិសាល** | ប្រធានដេប៉ាតឺម៉ង់សិក្សាអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៦. លោកបណ្ឌិត | **ឃុន គឹមលាង** | ប្រធានដេប៉ាតឺម៉ង់រូបវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៧. លោកស្រីបណ្ឌិត | **ស៊ូ កល្យាណ** | អនុប្រធានដេប៉ាតឺម៉ង់រូបវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៨. លោក | **ហង់ ស៊ឹម** | សាស្ត្រាចារ្យដេប៉ាតឺម៉ង់រូបវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៩. លោក | **ដួង ប៉េងអាន** | អ្នកសម្របសម្រួលកម្មវិធីមធ្យមសិក្សា មហាវិទ្យាល័យអប់រំ |
| ១០. កញ្ញា | **ហុង ឡៃហៀក** | បុគ្គលិកមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ១១. លោក | **សើ ពន្លក** | បុគ្គលិកមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |

## ៣. គណៈកម្មការត្រួតពិនិត្យ និងកែលម្អ

| | | |
|---|---|---|
| ១. លោកបណ្ឌិត | **សំអោ អឌ្ឍរតន៍** | អគ្គនាយករង អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ |
| ២. លោក | **ព្រឹង មរកត** | ប្រធាននាយកដ្ឋានមធ្យមសិក្សា |
| ៣. លោក | **ង៉ោ ប៉េងឡុង** | ប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ |
| ៤. ឯកឧត្តមបណ្ឌិត | **សិត សេង** | នាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ |
| ៥. លោកបណ្ឌិត | **ឈុក ច័ន្ទឆាយា** | អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ |
| ៦. លោក | **កែវ សារ៉ាត់** | ទីប្រឹក្សាបច្ចេកទេសគម្រោងកែលម្អការអប់រំចំណេះទូទៅ |

## ៤. ការរិកុំព្យូទ័រ

| | | |
|---|---|---|
| ១. លោក | **ម៉ៅ ម៉ារ៉ាឌី** | បុគ្គលិកមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ២. លោក | **ឱន សំណាង** | បុគ្គលិកមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |

## លទ្ធផលសិក្សារំពឹងទុក

ការសិក្សាក្នុងកម្មវិធីនេះគឺផ្តោតលើប្រតិបត្តិជាក់ស្តែងរបស់អ្នកសិក្សាដែលអនុវត្តផ្ទាល់នៅសាលារៀន។ ទាំងអ្នកសិក្សា និងសិស្ស (ដែលអ្នកសិក្សានឹងធ្វើការជាមួយផ្ទាល់) ចាំបាច់មាន (១) បំណិនចិត្តសង្គម (២) បំណិនពុទ្ធិ និង (៣) បំណិនបច្ចេកទេស ជាមូលដ្ឋាន (ដូចក្នុងរូបទី១)។ កញ្ចប់សមត្ថភាពទាំងបីខាងដើមនឹងជួយឱ្យអ្នកសិក្សា អភិវឌ្ឍបំណិនចិត្តសង្គម បំណិនពុទ្ធិ និងពង្រឹងសមត្ថភាពផ្នែក (ក)ការសម្រេចចិត្ត ទំនាក់-ទំនង សេចក្តីអំណត់ ទឹកចិត្តអាណិតអាសូរ និងការគ្រប់គ្រងខ្លួនឯង ថែមទាំងអាចអនុវត្តការបង្រៀនមុខវិជ្ជា ឯកទេសរូបវិទ្យាប្រកបដោយវិជ្ជាជីវៈ និងនវានុវត្តន៍ដោយប្រើប្រាស់ឧត្តមានុវត្តន៍ផ្សេងៗ (ខ) ការដោះស្រាយបញ្ហា និង ការរៀបចំនិងការចាត់ចែង (គ) បច្ចេកទេសកម្រិតមធ្យម និងកម្រិតខ្ពស់។




*រូបភាពទី១*
*ប្រភព៖ WDR2018 (p.103)*

ដោយឡែក សម្រាប់អ្នកសិក្សាកម្មវិធីនេះផ្ទាល់ នឹងទទួលបាន៖

**(១) ចំណេះដឹងឯកទេសរូបវិទ្យាកម្រិតបរិញ្ញាបត្រ**

- ❖ អគ្គិសនីទូទៅ
- ❖ មេកានិច
- ❖ ទែម៉ូឌីណាមិច
- ❖ រលក និងអុបទិច
- ❖ ពិសោធន៍រូបវិទ្យា
- ❖ ចិត្តសង្គម ភាពជាអ្នកដឹកនាំ និងគ្រប់គ្រង
- ❖ សន្លឹកកិច្ចការស្វ័យសិក្សានៅមធ្យមសិក្សា
- ❖ ការសរសេរ និងការពារឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេសរូបវិទ្យា

**(២) ចំណេះដឹងវិធីគរុកោលស្យ សាស្ត្របង្រៀន និងការអប់រំរូបវិទ្យាកម្រិតមធ្យមសិក្សា**

- វិធីសាស្ត្របង្រៀន
- វិធីសាស្ត្រវាយតម្លៃ
- ការស្រាវជ្រាវប្រតិបត្តិ
- ប្រឹក្សាគរុកោសល្យ
- បំណិនឌីជីថលសម្រាប់ការអប់រំ

**(៣) ហ្វឹកហាត់កម្មសិក្សាគរុកោលស្យ និងការអនុវត្តជាក់ស្តែង**

- អនុវត្តស្តង់ដា នៃយុទ្ធសាស្ត្រសហគមន៍សាលារៀន
- ការអនុវត្តកម្មវិធីស្វ័យសិក្សារូបវិទ្យា ពីទីថ្នាក់៧-ទី១២
- របាយការណ៍នៃការអនុវត្តស្តង់ដា នៃយុទ្ធសាស្ត្រសហគមន៍សាលារៀន

លទ្ធផលសិក្សារំពឹងទុកសម្រាប់បរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀននេះ ត្រូវបានកំណត់ដូចខាងក្រោមៈ

***វិជ្ជាសម្បទា***

PLO1- ពន្យល់អំពីទ្រឹស្តី និងគោលការណ៍នៃការអប់រំក្នុងបរិបទសកលលោក និងបរិបទ ប្រទេសដើម្បីឆ្លុះបញ្ចាំងទៅនឹងការអនុវត្តជាក់ស្តែងនៃការបង្រៀន។

PLO2- បកស្រាយអំពីដំណើរការអនុវត្តកិច្ចការសម្រាប់ការបង្វឹកលើការរៀបចំកម្មវិធីសិក្សា និងការបង្រៀនរូបវិទ្យាប្រកបដោយប្រសិទ្ធភាព។

***បំណិនសម្បទា***

PLO3- អនុវត្តបំណិនចិត្តសង្គម និងបច្ចេកវិទ្យាឌីជីថលសម្រាប់បង្កើនការប្រាស្រ័យទាក់ទងគ្នាក្នុងការងារ និងជីវភាពប្រកបដោយវិជ្ជាជីវៈ និងដោះស្រាយបញ្ហាប្រកបដោយភាពច្នៃ ប្រឌិត និងការទទួលខុសត្រូវ។

PLO4- បង្កើតគន្លឹះ និងទម្រង់សម្រាប់ដឹកនាំ និងគ្រប់គ្រងការបង្រៀនដោយផ្តោតលើផលសម្រេចនៃការសិក្សារបស់សិស្សឆ្ពោះទៅកែស្តង់ដាសាលារៀនមានប្រសិទ្ធភាព និងនិរន្តភាពសាលារៀនតាមរយៈការសិក្សា ការអនុវត្តជាក់ស្តែង និងការស្រាវជ្រាវ។

PLO5- អនុវត្តការងារអភិវឌ្ឍកម្មវិធីសិក្សា ការរៀននិងការបង្រៀនរូបវិទ្យា និងការសិក្សាបែបគម្រោងភ្ជាប់នឹងបំណិនរកចំណូលសម្រាប់សាលារៀនប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។

***ចរិយាសម្បទា***

PLO6- អភិវឌ្ឍឥរិយាបថវិជ្ជមាន និងវប្បធម៌រៀនពេញមួយជីវិតសម្រាប់បំពេញការងារ និងទាក់ទងជាមួយអ្នកដទៃប្រកបដោយគុណតម្លៃ មនុស្សធម៌ សាមគ្គីភាព និងការចែករំលែកគ្នា។

PLO7- បង្កើត/បង្ហាញការដឹកនាំបណ្តាញសម្រាប់កសាងភ្នាក់ងារពង្រីកឧត្តមានុវត្តន៍សម្រាប់ការរៀន និងការបង្រៀន។

សម្គាល់៖ Program Learning Outcome (PLO) លទ្ធផលសិក្សាកម្មវិធីអប់រំ

## កញ្ចប់សមត្ថភាព និង រចនាសម្ព័ន្ធកម្មវិធីសិក្សា

កម្មវិធីបរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀននេះ តម្រូវឱ្យអ្នកសិក្សាសិក្សាចំនួន ៦៣ ក្រេឌីតដែលមានរយៈពេលចន្លោះពី ១២ ទៅ ១៨ខែ។ ការសិក្សានិងធ្វើឡើងតាមរយៈការរៀនពីចម្ងាយ (ភាគច្រើនចន្លោះពី ៦០% ទៅ ៧០%) និងសិក្សាផ្ទាល់នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញនិង សាលាហាត់ការ (ភាគតិចចន្លោះពី ៤០% ទៅ ៣០%)។ ការសិក្សាផ្តោតលើបណ្តុំមុខវិជ្ជា (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៣៦ ក្រេឌីត) (២)ចំណេះដឹងគរុកោសល្យ វិធីសាស្ត្របង្រៀន និងការអប់រំមធ្យមសិក្សា (១២ (+៣) ក្រេឌីត) (៣) ហ្វឹកហាត់កម្មសិក្សាគរុកោសល្យ និងការអនុវត្តជាក់ស្តែង(១២ ក្រេឌីត)។ បន្ថែមពីលើនេះទៀតអ្នកសិក្សាត្រូវអនុវត្តខ្លឹមសារមេរៀនដែលបានសិក្សាក្នុងកម្មវិធីនៅសាលាសាមីផ្ទាល់តែម្តងដោយមានការណែនាំពីគ្រូបង្វឹក ប្រឹក្សាគរុកោសល្យ គ្រូបង្រៀននៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងមន្ត្រីអប់រំមកពីនាយកដ្ឋានជំនាញផ្សេងៗរបស់ក្រសួងអប់រំ យុវជន និងកីឡាដែលមានបទពិសោធន៍អនុវត្តជាក់ស្តែងកន្លងមក ។

| បណ្តុំមុខវិជ្ជា | ចំនួនក្រេឌីត |
|---|---|
| (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៦០%) | ៣៦ |
| (២)ចំណេះដឹងគរុកោសល្យ វិធីសាស្ត្របង្រៀន និងការអប់រំមធ្យមសិក្សា (២០%) | ១២ (+៣) |
| (៣)ហ្វឹកហាត់កម្មសិក្សាគរុកោសល្យ និងការអនុវត្តជាក់ស្តែង (២០%) | ១២ |
| សរុប | ៦០ (+៣) |

***សម្គាល់៖*** *សម្រាប់កញ្ចប់សមត្ថភាពចំណេះដឹងគរុកោសល្យ វិធីសាស្ត្របង្រៀន និងការអប់រំមធ្យមសិក្សាបានបន្ថែមមុខវិជ្ជាបំណិនឌីជីថលសម្រាប់ការអប់រំចំនួន ៣ក្រេឌីត*

## លក្ខណៈទូទៅនៃមុខវិជ្ជាសិក្សា

មុខវិជ្ជាសិក្សាសម្រាប់កម្រិតបរិញ្ញាបត្រអប់រំនេះនឹងជួយឱ្យអ្នកសិក្សាបំពេញកញ្ចប់សមត្ថភាពដូចខាងក្រោម ដើម្បីឆ្លើយតបនឹងលទ្ធផលសិក្សាកម្មវិធីអប់រំហើយឱ្យអ្នកសិក្សាមានសមត្ថភាពសម្រាប់បំពេញការងារប្រកបដោយវិជ្ជាជីវៈ។

| បណ្តុំមុខវិជ្ជា | មុខវិជ្ជាសិក្សា | ក្រេឌីត |
|---|---|---|
| (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៦០%) | អគ្គិសនីទូទៅ | ៣ |
| | មេកានិច | ៣ |
| | ទែម៉ូឌីណាមិច | ៣ |
| | រលក និងអុបទិច | ៣ |
| | ពិសោធន៍រូបវិទ្យា | ៣ |
| | ការអនុវត្តសន្លឹកកិច្ចការរូបវិទ្យាសម្រាប់សិស្សស្វ័យសិក្សាកម្រិត១ (ចងចាំ) | ៣ |
| | ការអនុវត្តសន្លឹកកិច្ចការរូបវិទ្យាសម្រាប់សិស្សស្វ័យសិក្សាកម្រិត២ (យល់ដឹង) | ៣ |
| | សន្លឹកកិច្ចការរូបវិទ្យាសម្រាប់សិស្សស្វ័យសិក្សាកម្រិត៣ (ហ្វឹកហាត់) | ៣ |
| | សន្លឹកកិច្ចការរូបវិទ្យាសម្រាប់សិស្សស្វ័យសិក្សាកម្រិត៤ (វាយតម្លៃ) | ៣ |
| | ការសរសេរ និងការពារឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេស | ៩ |
| (៣)ចំណេះដឹងគរុកោសល្យ វិធីសាស្ត្របង្រៀន និង | វិធីសាស្ត្របង្រៀន បត់បែនតាមសមត្ថភាពសិស្ស និងទស្សនទានអប់រំថ្មីៗ | ៣ |
| | ប្រឹក្សា និងហ្វឹកហ្វឺនគរុសល្យលើយុទ្ធសាស្ត្រសហគមន៍សាលារៀន | ៣ |

| | | |
|---|---|---|
| ការអប់រំមធ្យមសិក្សា (២០%) | មូលដ្ឋានគ្រឹះវង្វាយតម្លៃអប់រំ | ៣ |
| | មូលដ្ឋានគ្រឹះនៃការស្រាវជ្រាវប្រតិបត្តិ | ៣ |
| | បំណិនឌីជីថលសម្រាប់ការអប់រំ* | ៣ |
| (៤)ហ្វឹកហាត់កម្មសិក្សាគរុកោសល្យ និងការអនុវត្តជាក់ស្តែង (២០%) | ការអនុវត្ត ស្តង់ដាយុទ្ធសាស្រ្តសហគមន៍សាលារៀន (ស្តង់ដាទី១) | ៣ |
| | ការអនុវត្ត ស្តង់ដានៃយុទ្ធសាស្រ្តសហគមន៍សាលារៀន (ស្តង់ដាទី២) | ៦ |
| | របាយការណ៍និងការការពារស្តីពីការអនុវត្តស្តង់ដាយុទ្ធសាស្រ្តសហគមន៍សាលារៀន | ៣ |
| **សរុប** | | **៦៣** |

## លំហូរបង្រៀន និងរៀន

**លំហូរបង្រៀននិងរៀន ១មេរៀន ឬកិច្ចការមួយ រួមជាមួយបំណិនមួយ និងចរិយាមួយ**




## ការវាយតម្លៃលើការសិក្សា

ការវាយតម្លៃលើការសិក្សារបស់អ្នកសិក្សាគឺផ្តោតលើលទ្ធផលសិក្សាជាគោល។ ការវាយតម្លៃលើការសិក្សាមានបីដំណាក់កាលធំៗ គឺ (១) ការវាយតម្លៃលើការសិក្សាមុខវិជ្ជា (២) ការវាយតម្លៃលើការសរសេរ ឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេស និង (៣) ការវាយតម្លៃសរុបដោយពិនិត្យលើការបំពេញគ្រប់លក្ខខណ្ឌសម្រាប់បញ្ចប់ការសិក្សា។

### ៦.៤.១ គោលការណ៍វាយតម្លៃ

គោលការណ៍រួមសម្រាប់ការវាយតម្លៃលើការសិក្សារបស់អ្នកសិក្សាមានដូចតទៅ៖

១) អ្នកសិក្សាតម្រូវឱ្យមានវត្តមានក្នុងការសិក្សាតាមមុខវិជ្ជានីមួយៗ មិនតិចជាង៧០%។ ក្នុងករណីអ្នកសិក្សាមានវត្តមានតិចជាង៧០% នឹងមិនត្រូវបានអនុញ្ញាតឱ្យប្រឡងបញ្ចប់មុខវិជ្ជានោះទេ
២) ក្នុងករណីដែលអ្នកសិក្សាធ្លាក់មុខវិជ្ជាណាមួយក្នុងឆមាស នឹងមិនអនុញ្ញាតឱ្យបន្តការសិក្សាទៅឆ្នាំបន្ទាប់ និងប្រឡងបញ្ចប់ឡើយ

៣) អ្នកសិក្សាទាំងអស់ត្រូវធ្វើកិច្ចការស្រាវជ្រាវសំខាន់ៗតាមមុខវិជ្ជានីមួយៗ និងប្រគល់ជូនគ្រូឧទ្ទេសតាមមុខវិជ្ជាដែលបានកំណត់

៤) អ្នកសិក្សាត្រូវប្រឡងបញ្ចប់ការសិក្សាដែលធ្វើឡើងបន្ទាប់ពីចប់ឆមាសនីមួយៗ តាមការកំណត់ក្នុងកម្មវិធីសិក្សា

៥) អ្នកសិក្សាត្រូវចងក្រងឯកសារវឌ្ឍនភាពនៃកិច្ចការស្នូលរួមមានការហាត់ការ និងកម្មសិក្សាដែលផ្តោតលើ (ក) សកម្មភាពប្រតិបត្តិ (ខ) លទ្ធផលដែលសម្រេចបាន និង (គ) ការឆ្លុះបញ្ចាំង និងមេរៀនបទពិសោធន៍ និង

៦) អ្នកសិក្សាត្រូវតែជាប់មធ្យមភាគនៃការសិក្សាមុខវិជ្ជានិងការធ្វើកម្មសិក្សា ដើម្បីទទួលការអនុញ្ញាតឱ្យការពារឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេស។

## ការផ្តល់ពិន្ទុ និងប្រព័ន្ធចំណាត់ថ្នាក់

អ្នកសិក្សាអាចទទួលពិន្ទុចាប់ពី 00 ដល់ 100 ទៅតាមការវាយតម្លៃផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានកំណត់ក្នុងការសិក្សាមុខវិជ្ជា ការបំពេញកម្មសិក្សា និងការសរសេរនិងការការពារឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេស។ ពិន្ទុដែលជាប់ត្រូវចាប់ផ្តើមពីមធ្យមភាគពិន្ទុ 50% ឬពិន្ទុនិទ្ទេស 2.00 ឡើងទៅ។

ពិន្ទុគឺកំណត់ពី 00.00 ដល់ 100 (មធ្យមភាគនៃពិន្ទុនិទ្ទេសសរុប ឬ Grade Point Average–GPA)។ រូបមន្តគណនារកមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) គឺមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) ស្មើផលបូកសរុបរវាងផលគុណនៃពិន្ទុនិទ្ទេស (Grade Point–P) និងតម្លៃក្រេឌីតដែលត្រូវយកនៃមុខវិជ្ជានីមួយៗ (Attempted Credit Value–C) ចែកនឹងផលបូកសរុបនៃតម្លៃក្រេឌីតដែលត្រូវយកគ្រប់មុខវិជ្ជា។

ប្រព័ន្ធចំណាត់ថ្នាក់កម្មវិធី គឺផ្អែកទៅលើតម្លៃនៃពិន្ទុអតិបរមា 100% និង 50% នៃពិន្ទុអប្បបរមា។ ប្រព័ន្ធដាក់ពិន្ទុនេះ ត្រូវបានបកប្រែទៅជា «ពិន្ទុជានិទ្ទេស» និង «ពិន្ទុជាតម្លៃលេខ» ដូចដែលពិពណ៌នាខាងក្រោម៖

| ពិន្ទុជាភាគរយ% | និទ្ទេស | ពិន្ទុនិទ្ទេស | មូលវិចារណ៍ |
|---|---|---|---|
| 85%-100% | A | 4.00 | ល្អប្រសើរ |
| 80%-84% | B+ | 3.50 | ល្អណាស់ |
| 70%-79% | B | 3.00 | ល្អ |
| 65%-69% | C+ | 2.50 | ល្អបង្គួរ |
| 50%-64% | C | 2.00 | មធ្យម |
| <49% | F | 1.50 | ធ្លាក់ |

## ៦.៥ គោលការណ៍ប្រតិបត្តិ

ដើម្បីជានានូវការផ្តល់សេវាអប់រំប្រកបដោយគុណភាព និងភាពស័ក្តិសិទ្ធិ មហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញអនុវត្តតាមគោលការណ៍ បទបញ្ញត្តិ និងបទដ្ឋានគតិយុត្តិរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងគោលការណ៍ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ជាមួយគ្នានេះដែរ អ្នកសិក្សាម្នាក់ៗ ត្រូវគោរពតាមបទបញ្ញាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងឈរលើស្មារតីស្មោះត្រង់ ទទួលខុសត្រូវខ្ពស់ និងភាពម្ចាស់ការ និងគោលការណ៍សុចរិតភាពនៃការសិក្សា។ សម្រាប់គោលការណ៍សុចរិតភាពនៃការសិក្សា អ្នកសិក្សាម្នាក់ៗត្រូវបានវាយតម្លៃលើចំណុចសំខាន់ៗដូចខាងក្រោម៖

### ៦.៥.១ ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយា

ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់អ្នកសិក្សាម្នាក់ៗ ត្រូវបានប្រមូលផ្ដុំលើការគោរពវិន័យ ចាត់តាំង ការមករៀនទៀងទាត់ ការយកចិត្តទុកដាក់ក្នុងការសិក្សា ការខិតខំស្រាវជ្រាវ ការអនុវត្តភារកិច្ច និងស្មារតីសាមគ្គីភាពនៅក្នុងថ្នាក់ ក្នុងគ្រឹះស្ថានសិក្សា និងក្រៅគ្រឹះស្ថានសិក្សា។ ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់អ្នកសិក្សាម្នាក់ៗ ត្រូវបានធ្វើឡើងតាមរយៈយោបល់ឯកភាពពីមតិភាគច្រើនដាច់ខាតរបស់ក្រុមប្រឹក្សាវិន័យ ដោយផ្អែកលើលក្ខណសម្បត្តិជាក់ស្តែងរបស់អ្នកសិក្សាម្នាក់ៗ និងបទបញ្ញាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

### ៦.៥.២ ការក្លែងបន្លំឯកសារ

អ្នកសិក្សាដែលក្លែងបន្លំឯកសារ នឹងត្រូវលុបឈ្មោះចេញពីបញ្ជីនិស្សិតដោយស្វ័យប្រវត្តិ ព្រមទាំងទទួលទោសតាមច្បាប់ជាធរមាន។ អ្នកសិក្សាត្រូវចាំថា ការលួចចម្លងស្នាដៃ ការលួចកម្មសិទ្ធិបញ្ញា និងគំនិតរបស់អ្នកដទៃគឺជាបទល្មើសសិក្សាធ្ងន់ធ្ងរ ដែលអាចឈានដល់ការបញ្ឈប់បុគ្គលដែលប្រព្រឹត្តបទល្មើសពីកម្មវិធី។ ត្រូវសម្រេចឱ្យធ្លាក់ជាស្ថាពរ បើអ្នកសិក្សារូបណាចម្លងដោយផ្ទាល់ពីអ្នកសិក្សាដទៃទៀត ឬប្រភពផ្សេងៗ ឬការប្រើសម្ភារៈ ឬឯកសារផ្សេងទៀត ដែលមិនត្រូវបានអនុញ្ញាតក្នុងការប្រឡង។

### ៦.៥.៣ ឯកសារជំនួយស្មារតី/របាយការណ៍/កិច្ចការស្រាវជ្រាវ

អ្នកសិក្សាត្រូវបង្ហាញនូវសុចរិតភាពនៃការស្រាវជ្រាវរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួន ចាប់តាំងពីពេលចូលរៀនរហូតដល់ចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាល។ រាល់សំណេរការងារសិក្សាទាំងអស់ មិនត្រូវដកស្រង់គំនិត សរសេរ ឬចម្លងស្នាដៃផ្សេងៗរបស់អ្នកដទៃមកធ្វើជាគំនិត ជាស្នាដៃ ឬជាកម្មសិទ្ធិរបស់ខ្លួនដោយគ្មានការបញ្ជាក់ពីប្រភពច្បាស់លាស់នៃឯកសារយោង ឯកសារពិគ្រោះ ឬការអនុញ្ញាតពីម្ចាស់ប្រភព។

ក្នុងករណីរកឃើញមានការលួចចម្លងស្នាដៃអ្នកដទៃ អ្នកសិក្សានឹងត្រូវប្រឈមមុខចំពោះក្រុមប្រឹក្សា បច្ចេកទេស និងក្រុមប្រឹក្សាវិន័យរបស់មហាវិទ្យាល័យអប់រំ ឬសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដោយត្រូវទទួលពិន័យឱ្យរៀនត្រួតថ្នាក់ ឬអាចត្រូវបញ្ឈប់ពីកម្មវិធីដោយគ្មានសំណងប្រាក់សិក្សាដែលបានបង់រួចហើយ និងមិនមានការចេញលិខិតស្នាមបញ្ជាក់ការសិក្សាអ្វីដែរ។

**សម្គាល់៖** កម្មវិធីបណ្តុះបណ្តាលសូមរក្សាសិទ្ធិក្នុងការកែប្រែការអនុវត្តជាក់ស្តែងឱ្យឆ្លើយតបទៅនឹង វឌ្ឍនភាពការរៀននិងបង្រៀន សមត្ថភាពរៀននិងការអនុវត្តជាក់ស្តែង និង ស្ថានភាពរៀននិងបង្រៀនជាក់ស្តែង ដើម្បីសម្រេចបានលទ្ធផលសិក្សាល្អបំផុត និងសម្រេចស្តង់ដាសហគមន៍សាលារៀននៃគម្រោងកែលម្អការអប់រំចំណេះទូទៅ (GEIP) ។

# មេរៀនទី១ សីតុណ្ហភាព និង កម្ដៅ



Image by freepik

ក្រុម សុណា 2024

## សីតុណ្ហភាព ? កម្ដៅ ?



Image by freepik

ជាទូទៅពេលអ្នកក្ដៅខ្លួនហើយទៅមន្ទីរពេទ្យ លោកគ្រូ/អ្នកគ្រូពេទ្យវាស់**កម្ដៅ**ខ្លួនរបស់អ្នក។

កម្ដៅ ?

ដូចម្ដេចដែលហៅថា សីតុណ្ហភាព ?
ដូចម្ដេចដែលហៅថា កម្ដៅ ?

## ១.១ សីតុណ្ហភាព និង លំនឹងកម្ដៅ (Thermal Equilibrium)

សីតុណ្ហភាពជាទំហំមួយកំណត់ដោយកម្រិតក្ដៅ ឬត្រជាក់នៃអង្គធាតុមួយ ឬ តំបន់មួយ។ ថ្នាក់ទី៧




*សីតុណ្ហភាពនៃអង្គធាតុមួយជាទំហំមួយកំណត់ថាមពលស៊ីនេទិចនៃម៉ូលេគុលរបស់អង្គធាតុនោះ។ ថ្នាក់ទី១១*

កម្ដៅ( ថាមពលកម្ដៅ ) ជាថាមពលដែលផ្ទេររវាងអង្គធាតុពីរដែលមានសីតុណ្ហភាពខុសគ្នា។




## ១.១ សីតុណ្ហភាព និង លំនឹងកម្ដៅ (Thermal Equilibrium)




ញាណរបស់មនុស្សមិនសុក្រិតទេ ហើយពេលខ្លះគឺខុសទាំងស្រុង។

ឧទាហរណ៍៖ កំណាត់លោហៈ និង កំណាត់ឈើ មានសីតុណ្ហភាព 20 °C ដូចគ្នា។ ប៉ុន្តែ ពេលដែលអ្នកប៉ះវាទាំងពីរ អ្នកមានអារម្មណ៍ថាកំណាត់លោហៈត្រជាក់ជាង។ ហេតុអ្វី ?[នឹងសិក្សានៅ 1.7]

ដើម្បីអោយសុក្រិត គេត្រូវប្រើឧបករណ៍សម្រាប់វាស់។ ឧបករណ៍វាស់សីតុណ្ហភាព គឺ ទែម៉ូម៉ែត។

ទែម៉ូម៉ែតសារធាតុរាវខាងក្នុង
Liquid-in-thermometer




Image by dreamstime

## ១.១ សីតុណ្ហភាព និង លំនឹងកម្ដៅ (Thermal Equilibrium)




ក្រោយមានលំនឹងកម្ដៅ កម្ពស់អង្គធាតុរាវឈប់ប្រែប្រួល។

គេអាចវាស់សីតុណ្ហភាពរបស់អង្គធាតុណាមួយបានតាមរបៀបណា?

លំនឹងកម្ដៅ ជាស្ថានភាពដែលមិនមានការផ្ទេរកម្ដៅរវាងអង្គធាតុពីរ។

លក្ខណ្ឌលំនឹងកម្ដៅ៖ អង្គធាតុ A និង B មានសីតុណ្ហភាពដូចគ្នា។




លំនឹងកម្ដៅ $T_A = T_B$

## ១.១ សីតុណ្ហភាព និង លំនឹងកម្ដៅ (Thermal Equilibrium)







### ច្បាប់ទី 0 ទែម៉ូឌីណាមិច

ប្រសិនបើទាំងអង្គធាតុ A និង អង្គធាតុ B សុទ្ធតែមានលំនឹង កម្ដៅជាមួយ អង្គធាតុ C នោះ អង្គធាតុ A និង អង្គធាតុ B ក៏មានលំនឹងកម្ដៅជាមួយគ្នាដែរ។

# ១.១ សីតុណ្ហភាព និង លំនឹងកម្ដៅ (Thermal Equilibrium)




### តេស្តសាកល្បង

គេយកទែម៉ូម៉ែតទៅដាក់ប៉ះនឹងអង្គធាតុក្តៅមួយ ហើយគេកត់ត្រាតម្លៃសីតុណ្ហភាពដែលប្រែប្រួល តើវាជាសីតុណ្ហភាពរបស់វត្ថុមួយណា?

ក. សីតុណ្ហភាពរបស់អង្គធាតុ
ខ. សីតុណ្ហភាពរបស់ទែម៉ូម៉ែត
គ. សីតុណ្ហភាពមធ្យមរបស់ អង្គធាតុ និង ទែម៉ូម៉ែត។

# ១.២ ទែម៉ូម៉ែត និង មាត្រដ្ឋានសីតុណ្ហភាព

ប្រភេទទែម៉ូម៉ែត៖ ប្រើប្រាស់លក្ខណៈរបស់រូបធាតុ




សារធាតុរាវខាងក្នុង




ឧស្ម័នមានមាឌថេរ




បន្ទះទ្វេលោហៈ

បន្សាយកាំរស្មី






រេស៊ីស្តង់អាស្រ័យ $T$

# ១.២ ទែម៉ូម៉ែត និង មាត្រដ្ឋានសីតុណ្ហភាព




ក្រិតពី 0 (ចំណុចទឹកកករលាយ) ទៅ 100 (ចំណុចទឹកពុះ) ដោយ 100 ប្រឡោះក្រិត។ ក្រិតនីមួយៗហៅថា ដឺក្រេ។

- មាត្រដ្ឋានសីតុណ្ហភាព សែលស្យុស (°C)
- មាត្រដ្ឋានសីតុណ្ហភាព ផារិនហៃ (°F)

ទំនាក់ទំនង $T_F = \frac{9}{5}T_C + 32$

ទំនាក់ទំនង $T_C = \frac{5}{9}(T_F - 32)$

} ទទួលបានមកតាមរបៀបណា?

- មាត្រដ្ឋានសីតុណ្ហភាព សែលស្យុស (K)

# ១.៣ ទែម៉ូម៉ែតឧស្ម័ន និង មាត្រដ្ឋានកែលវិន






ប្រយ័ត្ន

$T = 273.15$ K ◄ RIGHT!

$T = 273.15$ °K ◄ WRONG

មាត្រដ្ឋានដែលមិនអាស្រ័យនឹងលក្ខណៈរបស់សារធាតុ។

- មាត្រដ្ឋានសីតុណ្ហភាព សែលស្យុស (K)

ទំនាក់ទំនង $T_K = T_C + 273.15$

$$\frac{T_2}{T_1} = \frac{p_2}{p_1}$$

ចំណុចប្រសព្វបីរបស់ទឹក (រឹង រាវ និង ឧស្ម័ន)

$$T_{triple} = 0.01\ ^\circ\text{C} = 273.16\ \text{K}$$

$$p_{triple} = 610\ \text{Pa} \sim 0.006\ \text{atm}$$

# ១.៣ ទែម៉ូម៉ែត្រឧស្ម័ន និង មាត្រដ្ឋានកែលវិន

## តេស្តសាកល្បង

ចូរតម្រៀបសីតុណ្ហភាពខាងក្រោមនេះ ពីធំទៅតូច

a. 0.00 ℃

b. 0.00 ℉

c. 260.00 K

d. 77.00 K

e. −180.00 ℃

# ១.៤ ការរីកកម្ដៅ







ចំងាយមធ្យមកើនឡើង ពេលសីតុណ្ហភាពកើនឡើង



ការរីកលីនេអ៊ែរ ( ការរីកបណ្ដោយ )

នៅសីតុណ្ហភាព $T_1 = T_0$ វាមានប្រវែង $L_1 = L_0$

នៅសីតុណ្ហភាព $T_2 = T_0 + \Delta T$ វាមានប្រវែង $L_2 = L_0 + \Delta L$

$$\Delta L = \alpha L_0 \Delta T$$

( សម្រាប់តែ បម្រែបម្រួលសីតុណ្ហភាពតូច 0℃ → 100℃ )

$\Delta L \rightarrow m, L_0 \rightarrow m, \Delta T \rightarrow$ K ឬ ℃, $\alpha \rightarrow$ K$^{-1}$ ឬ (℃)$^{-1}$

# ១.៤ ការរីកកម្ដៅ




មេគុណរីកបណ្ដោយ

| ប្រភេទសារធាតុ | $\alpha$ [K$^{-1}$ or (C°)$^{-1}$] |
|---|---|
| អាលុយមីញ៉ូម | $2.4 \times 10^{-5}$ |
| ស្ពាន់ (សំលោហៈ ទង់ដែង-ស័ង្កសី) | $2.0 \times 10^{-5}$ |
| ទង់ដែង | $1.7 \times 10^{-5}$ |
| កែវ | $0.4–0.9 \times 10^{-5}$ |
| អាំងវ៉ា (សំលោហៈ នីកែល-ដែក) | $0.09 \times 10^{-5}$ |
| ក្វាត(មិនគ្រីស្តាល់) | $0.04 \times 10^{-5}$ |
| ដែកថែប (សំលោហៈ ដែក-កាបូន) | $1.2 \times 10^{-5}$ |

# ១.៤ ការរីកកម្ដៅ




មេគុណរីកមាឌ

| អង្គធាតុរឹង | $\beta$ [K$^{-1}$ or (C°)$^{-1}$] | អង្គធាតុរាវ | $\beta$ [K$^{-1}$ or (C°)$^{-1}$] |
|---|---|---|---|
| អាលុយមីញ៉ូម | $7.2 \times 10^{-5}$ | អេតាណុល | $75 \times 10^{-5}$ |
| ស្ពាន់ (សំលោហៈ ទង់ដែង-ស័ង្កសី) | $6.0 \times 10^{-5}$ | កាបូនឌីស៊ុលភីត | $115 \times 10^{-5}$ |
| ទង់ដែង | $5.1 \times 10^{-5}$ | គ្លីសេរីន | $49 \times 10^{-5}$ |
| កែវ | $1.2–2.7 \times 10^{-5}$ | បារ៉ត | $18 \times 10^{-5}$ |
| អាំងវ៉ា (សំលោហៈ នីកែល-ដែក) | $0.27 \times 10^{-5}$ | | |
| ក្វាត(មិនគ្រីស្តាល់) | $0.12 \times 10^{-5}$ | | |
| ដែកថែប (សំលោហៈ ដែក-កាបូន) | $3.6 \times 10^{-5}$ | | |

ការរីកមាឌ (សម្រាប់តែ បម្រែបម្រួលសីតុណ្ហភាពតូច 0°C → 100°C)

នៅសីតុណ្ហភាព $T_1 = T_0$ វាមានមាឌ $V_1 = V_0$

នៅសីតុណ្ហភាព $T_2 = T_0 + \Delta T$ វាមានមាឌ $V_2 = V_0 + \Delta V$

$$\Delta V = \beta V_0 \Delta T$$

$\Delta V \rightarrow \mathrm{m}^3, V_0 \rightarrow \mathrm{m}, \Delta T \rightarrow$ K ឬ °C, $\beta \rightarrow \mathrm{K}^{-1}$ ឬ (°C)$^{-1}$

ជាទូទៅ $\beta = 3\alpha$

កិច្ចការ៖ ស្រាយបញ្ជាក់ ថា $\beta = 3\alpha$

# ១.៤ ការរីកកម្ដៅ

ភាពចម្លែកនៃការរីកមាឌទឹក




ប្រហែលជាគ្មានជីវិតលើផែនដីទេ បើទឹកកកលិចក្នុងទឹក




# តេស្តសាកល្បង




ប្រសិនបើបន្ទះទី 1 ជា ទង់ដែង តើបន្ទះទី2 គួរតែធ្វើពីសារធាតុណា( ចម្លើយអាចលើសពីមួយ ) ?

ក. ដែកថែប

ខ. ស្ពាន់

គ. អាលុយមីញ៉ូម

មេគុណរីកបណ្ដោយ

| ប្រភេទសារធាតុ | $\alpha$ [$K^{-1}$ or $(C°)^{-1}$] |
|---|---|
| អាលុយមីញ៉ូម | $2.4 \times 10^{-5}$ |
| ស្ពាន់ ( សំលោហៈ ទង់ដែង-ស័ង្កសី ) | $2.0 \times 10^{-5}$ |
| ទង់ដែង | $1.7 \times 10^{-5}$ |
| កែវ | $0.4–0.9 \times 10^{-5}$ |
| អាំងវ៉ា ( សំលោហៈ នីកែល-ដែក ) | $0.09 \times 10^{-5}$ |
| ក្វាត( មិនគ្រីស្តាល់ ) | $0.04 \times 10^{-5}$ |
| ដែកថែប ( សំលោហៈ ដែក-កាបូន ) | $1.2 \times 10^{-5}$ |

# ១.៥ បរិមាណកម្ដៅ

- កម្ដៅ( $Q$ )ជាថាមពលផ្ទេររវាងអង្គធាតុដែលមានសីតុណ្ហភាពខ្ពស់ និងអង្គធាតុដែលមានសីតុណ្ហភាពទាប។

- 1 cal (= 4.190 J ) ជាបរិមាណកម្ដៅដែលទឹក 1 g ស្រូបឬបញ្ចេញដើម្បីតម្លើងសីតុណ្ហភាព 1 °C ឬ បន្ថយ 1 °C ។

- កម្ដៅម៉ាស( $c$, specific heat ) ជាបរិមាណកម្ដៅដែលត្រូវផ្ដល់អោយអង្គធាតុមួយដែលមានម៉ាស 1 g ដើម្បីតម្លើងសីតុណ្ហភាពរបស់វា 1 °C។

- អង្គធាតុមានម៉ាស $m$ កម្ដៅម៉ាស $c$ កើនសីតុណ្ហភាពបាន $\Delta T = T_2(\text{ស្រេច}) - T_1\left(\text{ដើម}\right)$ ពេលវាស្រូបកម្ដៅ $Q = mc\Delta T$

<u>ករណីគ្មានកំហាតកម្ដៅ</u>

កម្ដៅស្រូប = កម្ដៅបញ្ចេញ ឬ ផលបូកពិជគណិតនៃកម្ដៅស្មើសូន្យ។

| ខ្នាត | |
|---|---|
| $Q \rightarrow$ cal | $Q \rightarrow$J |
| $m \rightarrow$ g | $m \rightarrow$ kg |
| $c \rightarrow$ cal/g · °C | $c \rightarrow$J/kg · K |
| $\Delta T \rightarrow$ °C | $\Delta T \rightarrow$ K |




# ១.៥ បរិមាណកម្ដៅ

ចំណុះកម្ដៅ ជាកម្ដៅចាំបាច់សម្រាប់តម្លើងឬបន្ថយសីតុណ្ហភាព 1 K ឬ 1 °Cនៃអង្គធាតុមួយ។ (រូបវិទ្យាថ្នាក់ទី ១០ តាង ចំណុះកម្ដៅ $C = \frac{Q}{\Delta T}$)

ចំណុះកម្ដៅម៉ូល ឬ កម្ដៅម៉ាសម៉ូល ( $C$ )

$M$ ជាម៉ាសម៉ូល kg/mol និង $m$ ជាម៉ាស នោះចំនួនម៉ូល $n = \frac{m}{M}$

$$C = Mc \quad \text{ដែល } C \rightarrow \text{J/mol} \cdot \text{K}$$

នោះកម្ដៅ $Q = nC\Delta T$ ។

សូមពិចារណា៖ទឹកត្រូវការយៈពេលច្រើននាទីដើម្បីពុះ ខណៈដែលសីតុណ្ហភាពរបស់ផ្ទាំងកើនឡើងយ៉ាងរហ័ស។ ហេតុអ្វី?



# ១.៥ បរិមាណកម្តៅ

| ប្រភេទសារធាតុ | Specific Heat, $c$ (J/kg · K) | Molar Mass, $M$ (kg/mol) | Molar Heat Capacity, $C$ (J/mol · K) |
|---|---|---|---|
| អាលុយមីញ៉ូម | 910 | 0.0270 | 24.6 |
| បេរីល្យូម | 1970 | 0.00901 | 17.7 |
| ទង់ដែង | 390 | 0.0635 | 24.8 |
| អេតាណុល | 2428 | 0.0461 | 111.9 |
| អេទីឡែន គ្លីកុល | 2386 | 0.0620 | 148.0 |
| ទឹកកក (ក្បែរ 0°C) | 2100 | 0.0180 | 37.8 |
| ដែក | 470 | 0.0559 | 26.3 |
| សំណ | 130 | 0.207 | 26.9 |
| ថ្មម៉ាប ($CaCO_3$) | 879 | 0.100 | 87.9 |
| បារ៉ត | 138 | 0.201 | 27.7 |
| អំបិល (NaCl) | 879 | 0.0585 | 51.4 |
| ប្រាក់ | 234 | 0.108 | 25.3 |
| ទឹក (រាវ) | 4190 | 0.0180 | 75.4 |

# ១.៦ កាឡូរីម៉ែត និង បម្រែបម្រួលភាព

- កាឡូរីម៉ែត ជាឧបករណ៍សម្រាប់វាស់កម្តៅ (ប៉ុន្មាន J ប៉ុន្មាន cal)។
- ភាព ជាលក្ខណៈជារឹង រាវ ឬ ឧស្ម័ននៃរូបធាតុ (ភាពរឹង ភាពរាវ ភាពឧស្ម័ន)។
- កម្តៅរលាយ (heat of fusion) ឬ កម្តៅឡាតង់រលាយ ឬ កម្តៅម៉ាសរលាយ

$$L_f = \frac{Q}{m}$$

- កម្តៅឡាតង់បង្ហួត (heat of vaporization) ឬ កម្តៅម៉ាសបង្ហួត

$$L_v = \frac{Q}{m}$$

ទម្រង់ទូទៅ $Q = \pm mL$

$L$: កម្តៅម៉ាសឡាតង់រលាយ បង្កក បង្ហួត កំណជាញើស

$Q$: កម្តៅផ្ទេរដែលធ្វើអោយមានបម្លាស់ប្តូរភាព

$\pm$: កម្តៅផ្ទេរអោយអង្គធាតុ + កម្តៅផ្ទេរចេញពីអង្គធាតុ –

ចំណាំ

$L_f$ ក្នុងសៀវភៅរូបវិទ្យាថ្នាក់ទី ១០ → $Q$ ក្នុងស្លាយនេះ
$\ell_f$ ក្នុងសៀវភៅរូបវិទ្យាថ្នាក់ទី ១០ → $L_f$ ក្នុងស្លាយនេះ

ទឹកកក 0°C ⇄ ទឹក 0°C

ទឹក 100°C ⇄ ចំហាយទឹក 100°C

# ១.៦ កាឡូរីម៉ែត និង បម្រែបម្រួលភាពនៃរូបធាតុ

ទឹក 1 kg ត្រូវស្រូបកម្ដៅប្រហែល $4.19 \times 10^5$J ដើម្បីបង្កើនសីតុណ្ហភាពពី 0 °C ដល់ 100 °C ។ ទឹកដែលពុះនេះត្រូវស្រូបកម្ដៅប្រហែល $2.256 \times 10^6$J ដើម្បីក្លាយទៅជាចំហាយទឹក។ តើវាត្រូវនឹងបទពិសោធន៍ប្រចាំថ្ងៃរបស់អ្នកទេ? រយៈពេលដើម្បីរំហួតទឹក គឺយូរជាងរយៈពេលដើម្បីដាំទឹកអោយពុះ។ (កិច្ចការៈ សូមព្យាយាមគណនាដើម្បីផ្ទៀងផ្ទាត់តម្លៃកម្ដៅទាំងពីរខាងលើ)

ទឹកកក 0°C ⇄ ទឹក 0°C

ទឹក 100°C ⇄ ចំហាយទឹក 100°C



# ១.៦ កាឡូរីម៉ែត និង បម្រែបម្រួលភាព




ដ្យាក្រាមសីតុណ្ហភាពប្រែប្រួលតាមពេលដែលពិពណ៌នាអំពីបម្លែងភាពនៃទឹកពីរឹងទៅជាចំហាយទឹក

# ១.៦ កាឡូរីម៉ែត និង បម្រែបម្រួលភាព

ត្រូវការសំពាធខ្ពស់ដើម្បីក្លាយជាអង្គធាតុរឹង

| Substance | ចំណុចរលាយធម្មតា K | ចំណុចរលាយធម្មតា °C | កម្តៅម៉ាសឡាតង់រលាយ (J/kg) | ចំណុចរលាយធម្មតា K | ចំណុចរលាយធម្មតា °C | កម្តៅម៉ាសឡាតង់រំហួត (J/kg) |
|---|---|---|---|---|---|---|
| អេល្យូម | * | * | * | 4.216 | −268.93 | $20.9 \times 10^3$ |
| អ៊ីដ្រូសែន | 13.84 | −259.31 | $58.6 \times 10^3$ | 20.26 | −252.89 | $452 \times 10^3$ |
| អាសូត | 63.18 | −209.97 | $25.5 \times 10^3$ | 77.34 | −195.8 | $201 \times 10^3$ |
| អុកស៊ីសែន | 54.36 | −218.79 | $13.8 \times 10^3$ | 90.18 | −183.0 | $213 \times 10^3$ |
| អេតាណុល | 159 | −114 | $104.2 \times 10^3$ | 351 | 78 | $854 \times 10^3$ |
| បារ៉ត | 234 | −39 | $11.8 \times 10^3$ | 630 | 357 | $272 \times 10^3$ |
| ទឹក | 273.15 | 0.00 | $334 \times 10^3$ | 373.15 | 100.00 | $2256 \times 10^3$ |
| ស៊ុលផួរ | 392 | 119 | $38.1 \times 10^3$ | 717.75 | 444.60 | $326 \times 10^3$ |
| សំណ | 600.5 | 327.3 | $24.5 \times 10^3$ | 2023 | 1750 | $871 \times 10^3$ |
| អង់ទីម៉ូនី | 903.65 | 630.50 | $165 \times 10^3$ | 1713 | 1440 | $561 \times 10^3$ |
| ប្រាក់ | 1233.95 | 960.80 | $88.3 \times 10^3$ | 2466 | 2193 | $2336 \times 10^3$ |
| មាស | 1336.15 | 1063.00 | $64.5 \times 10^3$ | 2933 | 2660 | $1578 \times 10^3$ |
| ទង់ដែង | 1356 | 1083 | $134 \times 10^3$ | 1460 | 1187 | $5069 \times 10^3$ |



លោហៈ កាល្យូម (Metal Gallium) ស្ថិតនៅភាពរាវនៅសីតុណ្ហភាព 29.8 °C ។ កម្តៅម៉ាសឡាតង់រលាយ $8.04 \times 10^4$ J/kg

# ១.៧ យន្តការនៃការបញ្ជូនកម្តៅ

យន្តការទាំងបីនៃការបញ្ជូនកម្តៅ

- ការចម្លងកម្តៅ ជាការបញ្ជូនថាមពលកម្តៅតាមរយៈការប៉ះផ្ទាល់នៃអង្គធាតុ ពីតំបន់មានសីតុណ្ហភាពខ្ពស់ទៅតំបន់មួយទៀតដែលមានសីតុណ្ហភាពទាប។
- ចរន្តវិលវល់ ជាយន្តការបញ្ជូនថាមពលកម្តៅដែលកើតមានឡើងដោយមានលំហូរម៉ាសនៃសន្ទនីយពីតំបន់មួយទៅតំបន់មួយទៀត។
- ការបញ្ចេញរស្មី ជាយន្តការបញ្ជូនកម្តៅរវាងអង្គធាតុតាមរយៈកាំរស្មីអេឡិចត្រូម៉ាញេទិចដែលមិនត្រូវការវត្តមានរូបធាតុនៅចន្លោះអង្គធាតុទាំងនោះ។






ដាំទឹក



# ១.៧ យន្តការនៃការបញ្ជូនកម្ដៅ

ការចម្លងកម្ដៅ




- ចរន្តកម្ដៅ ឬ អត្រាកម្ដៅ (H គិតជា W)

$$H=\frac{dQ}{dt}=kA\frac{T_H-T_C}{L}$$

$k$ ជាមេគុណចម្លងកម្ដៅ ($W/m\cdot K$)

$L$ ចំងាយរវាងអង្គធាតុក្ដៅ និង អង្គធាតុត្រជាក់ ($m$)

$A$ ផ្ទៃមុខកាត់ ($m^2$)

$\frac{T_H-T_C}{L}$ ហៅថា ក្រាដ្យង់សីតុណ្ហភាព

$T_H$ និង $T_C$ គិតជា K

- រេស៊ីស្តង់កម្ដៅ $R=\frac{L}{k}=A\frac{T_H-T_C}{H}$ គិតជា $m^2K/W$

តារាងមេគុណចម្លងកម្ដៅ ($k\rightarrow W/m\cdot K$)

| | | | |
|---|---|---|---|
| លោហៈ | | ក្រណាត់ | 0.04 |
| អាលុយមីញ៉ូម | 205.0 | ខ្សែកែវ ឬ ខ្សែប្លាស្ទិច | 0.04 |
| ស្ពាន់ | 109.0 | កែវ | 0.8 |
| ទង់ដែង | 385.0 | ទឹកកក | 1.6 |
| សំណ | 34.7 | ក្រណាត់ rockwool | 0.04 |
| បារ៉ត | 8.3 | ស្ទីរ៉ូហ្វូម | 0.027 |
| ប្រាក់ | 406.0 | ឈើ | 0.12–0.04 |
| ដែកថែប | 50.2 | ឧស្ម័ន | |
| អង្គធាតុរឹង (តម្លៃតំណាង) | | ខ្យល់ | 0.024 |
| ដុំឥត(អ៊ីសូឡង់) | 0.15 | អាកុង | 0.016 |
| ដុំឥត(ក្រហម) | 0.6 | អេល្យូម | 0.14 |
| បេតុង | 0.8 | អ៊ីដ្រូសែន | 0.14 |
| cork(សំបកឈើផ្នកស្រា ទំពាំងបាយជូរ) | 0.04 | អុកស៊ីសែន | 0.023 |

១.៧ យន្តការនៃការបញ្ជូនកម្ដៅ

ចរន្តវិលវល់ បែងចែកជាពីរ៖

- *ចរន្តវិលវល់សេរី* ជាចរន្តវិលវល់ដែលកើតឡើងដោយមានលំហូរម៉ាសបណ្ដាលមកពីដង់ស៊ីតេខុសគ្នា(មកពីការរីកនៃមាឌ)។ ឧ. ចរន្តវិលវល់នៃខ្យល់ ធ្វើអោយមានធាតុអាកាសផ្លាស់ប្ដូរ ចរន្តវិលវល់ក្នុងសមុទ្រ។
- *ចរន្តវិលវល់បង្ខំ* ជាចរន្តវិលវល់ដែលកើតឡើងដោយមានលំហូរម៉ាសបណ្ដាលមកពីឧបករណ៍ផ្លុំ ឬ ស្នប់។ ឧ. ចរន្តវិលវល់នៃឈាមកើតឡើងដោយមានបេះដូងជាស្នប់។

ចរន្តវិលវល់ជាដំណើរការដ៏ស្មុគស្មាញមួយ ដែលមិនមានសមីការងាយណាមួយសម្រាប់ពិពណ៌នាវាបានទេ។



ដែកក្ដៅក្នុងទឹក



ដាំទឹក

# ១.៧ យន្តការនៃការបញ្ជូនកម្ដៅ

## ការបញ្ចេញរស្មី

ស្ទើរតែគ្រប់អង្គធាតុទាំងអស់ដែលមានសីតុណ្ហភាព ~20 ℃ បញ្ចេញកាំរស្មីអេឡិចត្រូម៉ាញេទិចក្រហមអាំងប្រា។ ពេលសីតុណ្ហភាពកើនឡើង ជំហានរលកនៃកាំរស្មីអេឡិចត្រូម៉ាញេទិចនឹងថយចុះ។




ចរន្តកម្ដៅដែលបន្សាយចេញពីអង្គធាតុដែលមានសីតុណ្ហភាព $T \to \mathrm{K}$ មេគុណបន្សាយកម្ដៅ $e$(គ្មានខ្នាត) ផ្ទៃ $A \to \mathrm{m}^2$ អោយដោយ

$$H = Ae\sigma T^4$$

(ច្បាប់ស្ទេហ្វិនបុលស្មាន់)

$\sigma$ ជាថេរស្ទេហ្វិនបុលស្មាន់ ($= 5.67 \times 10^{-8}\ \mathrm{W/m^2 \cdot K^4}$)

$e$ មានតម្លៃធំសម្រាប់ផ្ទៃខ្មៅជាងផ្ទៃស។ ផ្ទៃរលោងមាន $e$ តូចជាងផ្ទៃគ្រើម។

បន្សាយកាំរស្មី





# ១.៧ យន្តការនៃការបញ្ជូនកម្ដៅ

## ការបញ្ចេញរស្មី និង ការស្រូបរស្មី

អង្គធាតុមានសីតុណ្ហភាព $T$ បញ្ចេញរស្មី ខណៈនេះវាក៏ស្រូបរស្មីពីមជ្ឈដ្ឋាន(ដែលមានសីតុណ្ហភាព $T_s$)។ អត្រាស្រូប

$$H = Ae\sigma T_s^4$$

ដូចនេះបន្សាយកាំរស្មីសរុប ដោយអង្គធាតុដែលមានសីតុណ្ហភាព $T$ ទៅមជ្ឈដ្ឋានដែលមានសីតុណ្ហភាព $T_s$ គឺ

$$H_{\mathrm{net}} = Ae\sigma(T^4 - T_s^4)$$

$H_{\mathrm{net}} > 0$ កម្ដៅហូរចេញពីអង្គធាតុ។

## អនុវត្តន៍ការបញ្ចេញរស្មី




ដបទែម៉ូស




$e = 1$



# ១.៧ យន្តការនៃការបញ្ជូនកម្ដៅ




ប្រភព : ការប្រែប្រួលអាកាសធាតុ និងយន្តការអភិវឌ្ឍន៍ស្អាត ២០១០

# ១.៧ យន្តការនៃការបញ្ជូនកម្ដៅ

## ការបញ្ចេញរស្មី អាកាសធាតុ និង បម្រែបម្រួលអាកាសធាតុ



# មេរៀនទី១ សីតុណ្ហភាព និង កម្ដៅ

## លំហាត់សម្រាប់ការពិភាក្សាក្រុម

**ក្រុម សុណា** 2024

## ឧទាហរណ៍សម្រាប់ ១.១ ដល់ ១.៣ [មាត្រដ្ឋានសីតុណ្ហភាព]

១. ចូរសរសេរទំនាក់ទំនងមាត្រដ្ឋានផារិនហៃ និងមាត្រដ្ឋានកែលវិន។

២. អ្នកដាក់ទឹកកកមួយដុំចូលក្នុងមាត់របស់អ្នក។ ពេលនោះទឹកកករលាយពីសីតុណ្ហភាព $T_1 = 32.00\ ^\circ\text{F}$ រហូតដល់ក្លាយជាទឹកដែលមានសីតុណ្ហភាព $T_2 = 98.60\ ^\circ\text{F}$។ ចូរគណនាសីតុណ្ហភាពទាំងនេះគិតជា °C និង K បន្ទាប់មកគណនាបម្រែបម្រួលសីតុណ្ហភាពគិតជា °F °C និង K។

## ឧទាហរណ៍សម្រាប់ ១.៤ [ការរីកកម្ដៅ]

៣. ជាងសំណង់ម្នាក់ប្រើម៉ែត្រធ្វើពីដែកថែបមួយដែលមានប្រវែង 50.000 m នៅសីតុណ្ហភាព 20 °C។ គេបានក្រិតម៉ែតនេះនៅសីតុណ្ហភាពដូចបានប្រាប់ខាងលើ។ $\alpha$ របស់ដែកថែបគឺ $1.2 \times 10^{-5}\ \mathrm{K}^{-1}$។

ក. តើម៉ែត្រនេះមានប្រវែងប៉ុន្មាននៅសីតុណ្ហភាព 35 °C ?

ខ. ជាងនេះបានប្រើម៉ែត្រខាងលើទៅវាស់ចំងាយលើដីមួយនៅសីតុណ្ហភាព 35 °C។ តម្លៃដែលគាត់វាស់បានគឺ 35.794 $m$។ តើចម្ងាយពិតប្រាកដមានតម្លៃប៉ុន្មាន ?

៤. ដបកែវមួយដែលមានមាឌ 200 $\mathrm{cm}^3$ ត្រូវបានគេយកមកដាក់បារ៉ាតពេញនៅសីតុណ្ហភាព 20 °C។ តើមានបារ៉ាតប៉ុន្មានហៀរចេញពីកែវនៅសីតុណ្ហភាព 100 °C។ មេគុណរីកបណ្ដោយនៃកែវ គឺ $0.40 \times 10^{-5}\ \mathrm{K}^{-1}$ ហើយមេគុណរីកមាឌនៃបារ៉ាតគឺ $18 \times 10^{-5}\ \mathrm{K}^{-1}$។

## ឧទាហរណ៍សម្រាប់ ១.៥ [បរិមាណកម្ដៅ]

៥. នៅពេលដែលបុរសម្នាក់ដែលមានម៉ាស 80 kg ឈឺគ្រុនក្ដៅ សីតុណ្ហភាពខ្លួនរបស់គាត់បានឡើងពី 98.6 °F ដល់ 102.2 °F។

ក. ចូរគណនាបរិមាណកម្ដៅដែលរាងកាយមនុស្សស្រូប។ សន្មត់ថា រាងកាយមនុស្សគឺពោរពេញដោយទឹកសុទ្ធសាត។

ខ. ការពិតនៅបរិមាណទឹកក្នុងខ្លួនមនុស្សមានប្រហែល 83% នៃម៉ាសសរុប។ ចូរធ្វើសំណួរ ក ឡើងវិញ បើសារធាតុផ្សេងៗក្រៅពីទឹកមានកម្ដៅម៉ាសប្រហែល 3480 J/kg · K។

៦. ឧបមាថាអ្នកឱសាញសៀគ្វីអគ្គីសនីមួយដែលធ្វើអំពីស៊ីលីស្យូម 23 g។ អានុភាពនៃចរន្តអគ្គីសនីដែលហូរចូលមានតម្លៃ 7.4 mW។ ប្រសិនបើមិនមានកំហាតថាមពលកម្ដៅទេ តើបន្ទះសៀគ្វីរបស់អ្នកនឹងកើនសីតុណ្ហភាពប៉ុន្មានកែលវិនក្នុងមួយនាទី។ កម្ដៅម៉ាសរបស់ស៊ីលីស្យូម 705 J/kg · K ។

៧. អ្នកលក់ម្នាក់បានចាក់កាហ្វេ 0.300 kg នៅសីតុណ្ហភាព 70.0 °C ចូលទៅក្នុងកែវអាលុយមីញ៉ូមដែលមានម៉ាស 0.120 kg និងសីតុណ្ហភាព 20.0 °C។ សន្មត់ថាគ្មានកំហាតបន្ទេរកម្ដៅ ហើយកាហ្វេមានកម្ដៅម៉ាសដូចទឹកគឺ $c_W = 4190$ J/kg · K និងអាលុយមីញ៉ូមមាន $c_{Al} = 910$ J/kg · K ។ ចូរគណនាសីតុណ្ហភាពប្រព័ន្ធទាំងមូលពេលមានលំនឹងកម្ដៅ។

## ឧទាហរណ៍សម្រាប់ ១.៦ [កាឡូរីម៉ែត និង បម្រែបម្រួលភាពនៃរូបធាតុ]

៨. កែវមានកូកាកូឡា 0.25 kg (ចាត់ទុកថាដូចទឹកសុទ្ធ)ដែលមានសីតុណ្ហភាពដើម 25 °C។ តើគេត្រូវដាក់ទឹកកកប៉ុន្មានចូលទៅក្នុងកែវនេះដើម្បីអោយវារលាយទាំងអស់ហើយមានសីតុណ្ហភាពស្រេច 0 °C? មិនគិតកំហាតកម្តៅផ្សេងៗ រួមទាំងកម្តៅស្រូបដោយកែវផងដែរ។

៩. ផ្ទាំងទង់ដែងក្តៅមួយមានម៉ាស 2.0 kg (បូកទាំងម៉ាសគម្រប)និង សីតុណ្ហភាព 150 °C។ អ្នកបានចាក់ទឹក 0.1 kg នៅសីតុណ្ហភាព 25 °C ចូលក្នុងផ្ទាំងនេះ បន្ទាប់មកបិតគម្របយ៉ាងរហ័ស។ ចូរគណនាសីតុណ្ហភាពស្រេចរបស់ផ្ទាំង និង ម៉ាសទឹក និង ម៉ាសចំហាយទឹក (បើមាន)។ សន្មត់ថាគ្មានកំហាតបន្ទេរកម្តៅ។

១០. នៅក្នុងការដាំទឹកដោយការដុតឥន្ធនៈ មានតែ 30% នៃថាមពលដែលបានមកពីការដុតឥន្ធនៈនោះទេដែលប្រើការបាន។ តើគេត្រូវការឥន្ធនៈប៉ុន្មានក្រាមដើម្បីដាំទឹក 1.00 kg ពីសីតុណ្ហភាព 20 °C អោយពុះរហូតដល់ហួតអស់ 0.25 kg? ឥន្ធនៈ 1 g ផ្តល់ថាមពល 46 000J។

## ឧទាហរណ៍សម្រាប់ ១.៧ [យន្តការនៃការបញ្ជូនកម្តៅ]

១១. ស្ទីរ៉ូហ្វូមក្លាស់សេមួយមានផ្ទៃជញ្ជាំងសរុប(រួមទាំងគម្រប) 0.80 $m^2$ និង មានកម្រាស់ជញ្ជាំង 2.0 cm ។ វាត្រូវបានគេដាក់យ៉ាងពេញលេញដោយទឹកកក ទឹក និងកំប៉ុងកូកាកូឡា នៅសីតុណ្ហភាព 0 °C។ ចូរគណនាចរន្តកម្តៅដែលហូរចូលធុងក្លាសសេនេះ បើសីតុណ្ហភាពខាងក្រៅគឺ 30 °C ។ តើមានទឹកកកប៉ុន្មាន kg រលាយក្នុងរយៈពេល 3h?




១២. របាដែកថែបមួយត្រូវបានគេផ្សារភ្ជាប់ចុងម្ខាងទៅនឹងចុងម្ខាងនៃរបារទង់ដែងមួយផ្សេងទៀត។ ប្រវែងទទឹងនៃរបារទាំងពីរនេះគឺ 2.00 cm ចុងម្ខាងនៃរបារដែកថែបត្រូវបានគេដាក់ក្នុងចំហាយទឹកដែលមានសីតុណ្ហភាព 100 °C ហើយចុងម្ខាងនៃរបារទង់ដែង គឺគេដាក់អោយប៉ះទឹកកកដែលមានសីតុណ្ហភាព 0 °C ។ ចូរគណនាសីតុណ្ហភាពត្រង់តំណនៅលក្ខណ្ឌលំហូរថេរ។ គណនាចរន្តកម្តៅក្នុងរបារទាំងពីរ។



# ១.៧ យន្តការនៃការបញ្ជូនកម្ដៅ




១៣. ចុះបើគេដាក់របារទាំងពីរដូចរូបខាងស្ដាំវិញ ចូរគណនាចរន្តកម្ដៅសរុប។

១៤. បន្ទះដែកថែបស្តើងរាងការ៉េ(ជ្រុងប្រវែង 10 cm) ត្រូវបានគេដុតកម្ដៅរហូតដល់ 800 °C។ ប្រសិនបើមេគុណបន្សាយរស្មី គឺ 0.60 ចូរគណនាអត្រាបន្សាយកាំរស្មីពីបន្ទះនេះ។

១៥. ចូរគណនាអត្រាបន្សាយកាំរស្មីនៃរាងកាយរបស់មនុស្សដែលមានផ្ទៃសរុប 1.20 $m^2$ និង សីតុណ្ហភាពលើស្បែក 30 °C។ ប្រសិនបើសីតុណ្ហភាពខាងក្រៅគឺ 20 °C ចូរគណនាតម្លៃសរុបនៃអត្រាកម្ដៅដែលហូរចេញពីខ្លួនមនុស្ស។ មេគុណបន្សាយរស្មីគឺ 1។

# មេរៀនទី១ សីតុណ្ហភាព និង កម្ដៅ

## លំហាត់សម្រាប់ការពិភាក្សាក្រុម

ក្រុម សុណា 2024

## ឧទាហរណ៍សម្រាប់ ១.១ ដល់ ១.៣ [មាត្រដ្ឋានសីតុណ្ហភាព]

១. ចូរសរសេរទំនាក់ទំនងមាត្រដ្ឋានផារិនហៃ និងមាត្រដ្ឋានកែលវិន។

១- សរសេរទំនាក់ទំនងរវាងមាត្រដ្ឋានផារិនហៃ និងមាត្រដ្ឋានកែលវិន

គេបាន $T_F = 1.8 \times T_C + 32$

តែ $T_C = T_K - 273$

$=> T_F = 1.8(T_K - 273) + 32$

# ឧទាហរណ៍សម្រាប់ ១.១ ដល់ ១.៣ [មាត្រដ្ឋានសីតុណ្ហភាព]

២. អ្នកដាក់ទឹកកកមួយដុំចូលក្នុងមាត់របស់អ្នក។ ពេលនោះទឹកកករលាយពីសីតុណ្ហភាព $T_1 = 32.00$ °F រហូតដល់ក្លាយជាទឹកដែលមានសីតុណ្ហភាព $T_2 = 98.60$ °F ។ ចូរគណនាសីតុណ្ហភាពទាំងនេះគិតជា °C និង K បន្ទាប់មកគណនាបម្រែបម្រួលសីតុណ្ហភាពគិតជា °F °C និង K។

២. គណនាសីតុណ្ហភាពគិតជា °C និង K

+ចំពោះ: $T_1 = 32.00$ °F

- $T_C = \frac{5}{9}(T_F - 32) = \frac{5}{9}(32-32) = 0°C$ ។
- $T_K = T_C + 273.15 = 0 + 273.15 = 273.17K$ ។

+ចំពោះ: $T_2 = 98.60$ °F

- $T_C = \frac{5}{9}(T_F - 32) = \frac{5}{9}(98.60-32) = 37°C$
- $T_K = T_C + 273.15 = 37 + 273.15 = 310.15K$

គណនាបម្រែបម្រួលសីតុណ្ហភាព គិតជា °C °F K

តាម:

$\Delta T_C = T_{C_2} - T_{C_1}$ តែ $T_{C_1} = 0°C$, $T_{C_2} = 37°C$

$\boxed{\Delta T_C = 37 - 0 = 37°C}$

តាម:

$\Delta T_F = T_{F_2} - T_{F_1}$ តែ $T_{F_1} = 32.00°F$, $T_{F_2} = 98.60°F$

$\boxed{\Delta T_F = 98.60 - 32.00 = 66.60°F}$

តាម:

$\Delta T_K = T_{K_2} - T_{K_1}$ តែ $T_{K_1} = 273.15K$, $T_{K_2} = 310.15K$

$\boxed{\Delta T_K = 310.15 - 273.15 = 37K}$

# ឧទាហរណ៍សម្រាប់ ១.៤ [ការរីកកម្តៅ]

៣. ជាងសំណង់ម្នាក់ប្រើម៉ែត្រធ្វើពីដែកថែបមួយដែលមានប្រវែង 50.000 m នៅសីតុណ្ហភាព 20 °C។ គេបានក្រិតម៉ែតនេះនៅសីតុណ្ហភាពដូចបានប្រាប់ខាងលើ។ $\alpha$ របស់ដែកថែបគឺ $1.2 \times 10^{-5}$ K$^{-1}$។

ក. តើម៉ែត្រនេះមានប្រវែងប៉ុន្មាននៅសីតុណ្ហភាព 35 °C?

ខ. ជាងនេះបានប្រើម៉ែត្រខាងលើទៅវាស់ចំងាយលើដីមួយនៅសីតុណ្ហភាព 35 °C។ តម្លៃដែលគាត់វាស់បានគឺ 35.794 $m$។ តើចម្ងាយពិតប្រាកដមានតម្លៃប៉ុន្មាន?




សូមចុចម៉ាស៊ីនគិតលេខដើម្បីបានចម្លើយចុងក្រោយ

# ឧទាហរណ៍សម្រាប់ ១.៤ [ការរីកកម្ដៅ]

៣. ជាងសំណង់ម្នាក់ប្រើម៉ែត្រធ្វើពីដែកថែបមួយដែលមានប្រវែង 50.000 m នៅសីតុណ្ហភាព 20 °C។ គេបានក្រិតម៉ែតនេះនៅសីតុណ្ហភាពដូចបានប្រាប់ខាងលើ។ $\alpha$ របស់ដែកថែបគឺ $1.2\times10^{-5}\ K^{-1}$។

ក. តើម៉ែត្រនេះមានប្រវែងប៉ុន្មាននៅសីតុណ្ហភាព 35 °C?

ខ. ជាងនេះបានប្រើម៉ែត្រខាងលើទៅវាស់ចំងាយលើដីមួយនៅសីតុណ្ហភាព 35 °C។ តម្លៃដែលគាត់វាស់បានគឺ 35.794 $m$។ តើចម្ងាយពិតប្រាកដមានតម្លៃប៉ុន្មាន?

រូបតំណាងពន្យល់បន្ថែម



# ឧទាហរណ៍សម្រាប់ ១.៤ [ការរីកកម្ដៅ]

៤. ដបកែវមួយដែលមានមាឌ 200 $cm^3$ ត្រូវបានគេយកមកដាក់បារ៉តពេញនៅសីតុណ្ហភាព 20 °C។ តើមានប៉ារតប៉ុន្មានហៀរចេញពីកែវនៅសីតុណ្ហភាព 100 °C។ មេគុណរីកបណ្ដោយនៃកែវ គឺ $0.40\times10^{-5}\ K^{-1}$ ហើយមេគុណរីកមាឌនៃបារ៉តគឺ $18\times10^{-5}\ K^{-1}$។

៤.គណនាម៉ាសបារ៉តដែលហៀរចេញពីកែវ

នៅ $t=20°C$ ឬ $t=293.15K$

$$V_{Hg}=V_{\text{កែវ}}=200cm^3=2\times10^{-4}m^3$$

+រកមាឌកែវ និងបារ៉តនៅ 100°C ឬ $t'=373.15K$

តាង $V'_{Hg}$ មាឌបារ៉ាតនៅសីតុណ្ហភាព $t'$

$V'_{កែវ}$ មាឌកែវនៅសីតុណ្ហភាព $t'$

តាមរូបមន្ត $V'_{កែវ}=V_{កែវ}(1+\beta_{កែវ}\Delta t)$

ដោយ $V_{កែវ}=2\times10^{-4}m^3$

$\beta_{កែវ}=3\alpha=3\times0.4\times10^{-5}K^{-1}=1.2\times10^{-5}K^{-1}$

$\Delta t=t'-t=373.15K-293.15K=80K$

$\Rightarrow V'_{កែវ}=2\times10^{-4}(1+1.2\times10^{-5}\times80)=200.192\times10^{-6}m^3$

+រកមាឌបារ៉ាត $V'_{Hg}$

តាមរូបមន្ត $V'_{Hg}=V_{Hg}(1+\beta_{Hg}\Delta t)$

ដោយ $\beta_{Hg}=18\times10^{-5}K^{-1};\Delta t=80K$

## ឧទាហរណ៍សម្រាប់ ១.៤ [ការរីកកម្តៅ]

$$\Rightarrow V'_{Hg}=2\times10^{-4}(1+18\times10^{-5}\times80)=202.88\times10^{-6}m^3$$

គេបានមាឌបារ៉ាតហៀរ $V''_{Hg}=V'_{Hg}-V'_{កែវ}$

$$=202.88\times10^{-6}-200.192\times10^{-6}=2.688\times10^{-6}m^3$$

ដូចនេះ $V''_{Hg}=2.688\times10^{-6}m^3$ ។


4 មាឌបារតដែលហៀរចេញ
+ កំណើនមាឌកែវ
$\Delta V_{កែវ} = 3\alpha V_0 \Delta t$
ដោយ $\alpha = 0.40\times10^{-5}\,K^{-1}$
$V_0 = 200\,cm^3 = 2\times10^{-4}\,m^3$
$\Delta t = 100°C - 20°C = 80°C$
គេបាន $\Delta V_{កែវ} = 3\times 0.40\times10^{-5}\,K^{-1}\times 2\times10^{-4}\,m^3\times 80°C = 192\times10^{-9}\,m^3$
+ កំណើនមាឌបារត
$\Delta V_{Hg} = \beta V_0 \Delta t$
ដោយ $\beta = 18\times10^{-5}\,K^{-1}$
គេបាន $\Delta V_{Hg} = 18\times10^{-5}\,K^{-1}\times 2\times10^{-4}\,m^3\times 80°C = 288\times10^{-9}\,m^3$
+ មាឌបារតដែលហៀរចេញ
$\Delta V' = \Delta V_{Hg} - \Delta V_{កែវ} = (288\times10^{-9} - 192\times10^{-9})\,m^3 = 96\times10^{-9}\,m^3$
ចម្លើយ៖ $\Delta V' = 96\times10^{-9}\,m^3$

របៀបផ្សេងគ្នា (មាន កំហុសគណនាលេខ សូម ត្រួតពិនិត្យដោយខ្លួនឯង)

## ឧទាហរណ៍សម្រាប់ ១.៥ [បរិមាណកម្តៅ]

៥. នៅពេលដែលបុរសម្នាក់ដែលមានម៉ាស 80 kg ឈឺគ្រុនក្តៅ សីតុណ្ហភាពខ្លួនរបស់គាត់បានឡើងពី 98.6 °F ដល់ 102.2 °F។

ក. ចូរគណនាបរិមាណកម្តៅដែលរាងកាយមនុស្សស្រូប។ សន្មត់ថា រាងកាយមនុស្សគឺពោរពេញដោយទឹកសុទ្ធសាត។

ខ. ការពិតនៅបរិមាណទឹកក្នុងខ្លួនមនុស្សមានប្រហែល 83% នៃម៉ាសសរុប។ ចូរធ្វើសំណួរ ក ឡើងវិញ បើសារធាតុផ្សេងៗក្រៅពីទឹកមានកម្តៅម៉ាសប្រហែល 3480 J/kg · K។


ឧទាហរណ៍ 1.5 (បរិមាណកម្តៅ)
5. ក. គណនាបរិមាណកម្តៅ
តាមរូបមន្ត $Q = mc\Delta t$
ដោយ $m = 80\,Kg$, $c = 4190\,J/kg°C$
$\Delta t = 102.2°F - 98.60°F = 3.6°F = 3.6°C$
គេបាន $Q = 80\,kg\times 4190\,J/kg°C\times 3.6°C = 1206720\,J$
ចម្លើយ៖ $Q = 1206720\,J$

*សំណួរ ខ*

$$Q = Q_1 + Q_2$$

$Q_1 = m_1 c_1 \Delta t$, $m_1 = 83\%$ នៃ 80 kg ហើយ $c_1 = 4190$ J/kg °C

$Q_2 = m_2 c_2 \Delta t$, $m_2 = (100\% - 83\%)$ នៃ 80 kg ហើយ $c_2 = 3480$ J/kg °C

# ឧទាហរណ៍សម្រាប់ ១.៥ [បរិមាណកម្ដៅ]

៦. ឧបមាថាអ្នកឱសាញសៀគ្វីអគ្គិសនីមួយដែលធ្វើអំពីស៊ីលីស្យូម 23 g។ អានុភាពនៃចរន្តអគ្គិសនីដែលហូរចូលមានតម្លៃ 7.4 mW។ ប្រសិនបើមិនមានកំហាតថាមពលកម្ដៅទេ តើបន្ទះសៀគ្វីរបស់អ្នកនឹងកើនសីតុណ្ហភាពប៉ុន្មានកែលវិនក្នុងមួយនាទី។ កម្ដៅម៉ាសរបស់ស៊ីលីស្យូម 705 J/kg · K ។


6, រកកំណើនសីតុណ្ហភាពក្នុង 1នាទី
+ ថាមពលអគ្គិសនី $W = Pt$
+ បរិមាណកម្ដៅ $Q = mc\Delta t$
តាមច្បាប់រក្សាថាមពល
$Q = W$
$mc\Delta t = Pt \Rightarrow \Delta t = \frac{Pt}{mc}$
ដោយ $P = 7{,}4\ mW = 74\times10^{-4}\ W$
$t = 1mn = 60s$
$c = 705\ J/kg.K$
$m = 23g = 23\times10^{-3}\ kg$
ដូចនេះ $\Delta t = \frac{74\times10^{-4}\times60}{23\times705\times10^{-3}} = 2{,}73\times10^{-2}\ K$
ចម្លើយ: $\Delta t = 2{,}73\times10^{-2}\ K$

# ឧទាហរណ៍សម្រាប់ ១.៥ [បរិមាណកម្ដៅ]

៧. អ្នកលក់ម្នាក់បានចាក់កាហ្វេ 0.300 kg នៅសីតុណ្ហភាព 70.0 °C ចូលទៅក្នុងកែវអាលុយមីញ៉ូមដែលមានម៉ាស 0.120 kg និងសីតុណ្ហភាព 20.0 °C។ សន្មត់ថាគ្មានកំហាតបន្ទេរកម្ដៅ ហើយកាហ្វេមានកម្ដៅម៉ាសដូចទឹកគឺ $c_W = 4190$ J/kg · K និងអាលុយមីញ៉ូមមាន $c_{Al} = 910$ J/kg · K ។ ចូរគណនាសីតុណ្ហភាពប្រព័ន្ធទាំងមូលពេលមានលំនឹងកម្ដៅ។

# ឧទាហរណ៍សម្រាប់ ១.៦ [កាឡូរីម៉ែត និង បម្រែបម្រួលភាពនៃរូបធាតុ]

៨. កែវមានកូកាកូឡា 0.25 kg (ចាត់ទុកថាដូចទឹកសុទ្ធ)ដែលមានសីតុណ្ហភាពដើម 25 °C។ តើគេត្រូវដាក់ទឹកកកប៉ុន្មានចូលទៅក្នុងកែវនេះដើម្បីអោយវារលាយទាំងអស់ហើយមានសីតុណ្ហភាពស្រេច 0 °C? មិនគិតកំហាតកម្តៅផ្សេងៗ រួមទាំងកម្តៅស្រូបដោយកែវផងដែរ។

៩. ផ្ទាំងទង់ដែងក្តៅមួយមានម៉ាស 2.0 kg (បូកទាំងម៉ាសគម្រប)និង សីតុណ្ហភាព 150 °C។ អ្នកបានចាក់ទឹក 0.1 kg នៅសីតុណ្ហភាព 25 °C ចូលក្នុងផ្ទាំងនេះ បន្ទាប់មកបិតគម្របយ៉ាងរហ័ស។ ចូរគណនាសីតុណ្ហភាពស្រេចរបស់ផ្ទាំង និង ម៉ាសទឹក និង ម៉ាសចំហាយទឹក (បើមាន)។ សន្មត់ថាគ្មានកំហាតបន្ទេរកម្តៅ។

១០. នៅក្នុងការដាំទឹកដោយការដុតឥន្ធនៈ មានតែ 30% នៃថាមពលដែលបានមកពីការដុតឥន្ធនៈនោះទេដែលប្រើការបាន។ តើគេត្រូវការឥន្ធនៈប៉ុន្មានក្រាមដើម្បីដាំទឹក 1.00 kg ពីសីតុណ្ហភាព 20 °C អោយពុះរហូតដល់ហួតអស់ 0.25 kg? ឥន្ធនៈ 1 g ផ្តល់ថាមពល 46 000J។

# ឧទាហរណ៍សម្រាប់ ១.៧ [យន្តការនៃការបញ្ជូនកម្តៅ]




១១. ស្ទីរ៉ូហ្វូមក្លាស់សេមួយមានផ្ទៃជញ្ជាំងសរុប(រួមទាំងគម្រប) 0.80 m$^2$ និង មានកម្រាស់ជញ្ជាំង 2.0 cm ។ វាត្រូវបានគេដាក់យ៉ាងពេញលេញដោយទឹកកក ទឹក និងកំប៉ុងកូកាកូឡា នៅសីតុណ្ហភាព 0 °C។ ចូរគណនាចរន្តកម្តៅដែលហូរចូលធុងក្លាសសេនេះ បើសីតុណ្ហភាពខាងក្រៅគឺ 30 °C ។ តើមានទឹកកកប៉ុន្មាន kg រលាយក្នុងរយៈពេល 3h?




១២. របាដែកថែបមួយត្រូវបានគេផ្សារភ្ជាប់ចុងម្ខាងទៅនឹងចុងម្ខាងនៃរបារទង់ដែងមួយផ្សេងទៀត។ ប្រវែងទទឹងនៃរបារទាំងពីរនេះគឺ 2.00 cm ចុងម្ខាងនៃរបារដែកថែបត្រូវបានគេដាក់ក្នុងចំហាយទឹកដែលមានសីតុណ្ហភាព 100 °C ហើយចុងម្ខាងនៃរបារទង់ដែង គឺគេដាក់អោយប៉ះទឹកកកដែលមានសីតុណ្ហភាព 0 °C ។ ចូរគណនាសីតុណ្ហភាពត្រង់តំណនៅលក្ខណ្ឌលំហូរថេរ។ គណនាចរន្តកម្តៅក្នុងរបារទាំងពីរ។

# ១.៧ យន្តការនៃការបញ្ជូនកម្ដៅ




១៣. ចុះបើគេដាក់របារទាំងពីរដូចរូបខាងស្ដាំវិញ ចូរគណនាចរន្តកម្ដៅសរុប។

១៤. បន្ទះដែកថែបស្តើងរាងការ៉េ( ជ្រុងប្រវែង 10 cm ) ត្រូវបានគេដុតកម្ដៅរហូតដល់ 800 °C។ ប្រសិនបើមេគុណបន្សាយរស្មី គឺ 0.60 ចូរគណនាអត្រាបន្សាយកាំរស្មីពីបន្ទះនេះ។

១៥. ចូរគណនាអត្រាបន្សាយកាំរស្មីនៃរាងកាយរបស់មនុស្សដែលមានផ្ទៃសរុប 1.20 $m^2$ និង សីតុណ្ហភាពលើស្បែក 30 °C។ ប្រសិនបើសីតុណ្ហភាពខាងក្រៅគឺ 20 °C ចូរគណនាតម្លៃសរុបនៃអត្រាកម្ដៅដែលហូរចេញពីខ្លួនមនុស្ស។ មេគុណបន្សាយរស្មីគឺ 1។

# មេរៀនទី២ លក្ខណៈកម្ដៅនៃរូបធាតុ



ក្រុម សុណា 2024

## សេចក្ដីផ្ដើម ៖ ទំហំម៉ាក្រូ និង ទំហំមីក្រូ

ទំហំម៉ាក្រូ (ធំៗ)បង្ហាញពីលក្ខណៈរបស់រូបធាតុ៖

- សំពាធ
- សីតុណ្ហភាព
- មាឌ
- ម៉ាសសរុប។

ទំហំមីក្រូ (តូចៗ)បង្ហាញពីលក្ខណៈរបស់រូបធាតុ៖

- ល្បឿន នៃភាគល្អិតនីមួយៗ
- ថាមពលស៊ីនេទិច នៃភាគល្អិតនីមួយៗ
- បរិមាណចលនា នៃភាគល្អិតនីមួយៗ
- ម៉ាសនៃភាគល្អិតនីមួយៗ។



នៅសំពាធបរិយាកាស $1.01 \times 10^5$ Pa មានប្រហែល $10^{32}$ ម៉ូលេគុល ដែលផ្លាស់ទីដោយល្បឿន 1700 km/h ទៅទង្គិចនឹងស្បែករបស់អ្នក។

# ២.១ សមីការភាពនៃឧស្ម័ន (Equations of state)

ភាព (state) ជាអ្វី?

អថេរនៃភាព (state variables): សំពាធ មាឌ សីតុណ្ហភាព




→ ទំនាក់ទំនង $n$, $m$, $m_{total}$, $M$, $N$, $N_A$

$m_{\text{total}} = nM$, $n = \frac{N}{N_A}$ [$N_A$ ចំនួនអាវ៉ូកាដ្រូ $6.022 \times 10^{23}$ ម៉ូលេគុល ឬ អាតូម/mol, $n \to$ mol, $M \to$ g/mol, $m \to$ g]

→ម៉ាសមួយម៉ូលេគុល $m = M/N_A = m_{total}/N$ ។

យោងតាមលទ្ធផលពិសោធន៍

១. មាឌ $V$ សមាមាត្រនឹងចំនួនម៉ូល $n$។ $p$ និង $T$ ថេរហើយ $n \uparrow$ 2ដង នោះ $V \uparrow$ 2ដង។

២. មាឌ $V$ ប្រាសសមាមាត្រនឹងចំនួនម៉ូល $p$។ $n$ និង $T$ ថេរហើយ $p \uparrow$ 2ដង នោះ $V \downarrow$ 2ដង។

៣. សំពាធ $p$ សមាមាត្រនឹងសីតុណ្ហភាព $T$។ $V$ និង $T$ ថេរហើយ $p \uparrow$ 2ដង នោះ $T \uparrow$ 2ដង។

# ២.១ សមីការភាពនៃឧស្ម័ន (Equations of state)




សមីការឧស្ម័នបរិសុទ្ធ (គម្រូឧស្ម័ន)

$$pV = nRT$$

→ កិច្ចការ៖ បង្ហាញថាម៉ាសមាឌឧស្ម័ន

$$\rho = \frac{m_{total}}{V} = \frac{pM}{RT}$$

$R$ ថេរឧស្ម័នបរិសុទ្ធ = 8.31 J/(mol · K)

$p$ សំពាធគិតជា Pa (ប៉ាស្កាល់)

$V$ មាឌគិតជា $m^3$

$n$ ចំនួនម៉ូលគិតជា mol

$T$ សីតុណ្ហភាពគិតជា K

ការអនុវត្តន៍






## ២.១ សមីការភាពនៃឧស្ម័ន (Equations of state)




→ ម៉ូលេគុលឧស្ម័នមានអន្តរកម្មទំនាញ

សមីការវ៉ាន់ដឺវ៉ាល់ ( The van der Waals Equation )

$$\left(p + \frac{an^2}{V^2}\right)(V - nb) = nRT$$

$a$ និង $b$ មានតម្លៃខុសគ្នាចំពោះឧស្ម័នផ្សេងៗ

$b$ ជាមាឌឧស្ម័នក្នុងមួយម៉ូល

## ២.១ សមីការភាពនៃឧស្ម័ន (Equations of state)

ដ្យាក្រាម $pV$




ខ្សែកោងអ៊ីសូទែម $pV$ ឧស្ម័នបរិសុទ្ធ




ខ្សែកោងអ៊ីសូទែម $pV$ នៃឧស្ម័នមិនមែនឧស្ម័នបរិសុទ្ធ

# ២.២ លក្ខណៈម៉ូលេគុលនៃរូបធាតុ (Molecular properties of matter)

## ម៉ូលេគុល និង កម្លាំងរវាងម៉ូលេគុល( intermolecular force )

-ម៉ូលេគុលដែលមានអាតូម១ មានទំហំប្រហែល $10^{-10}$ m
-ម៉ូលេគុលដែលមានអាតូមច្រើនបំផុត មានទំហំប្រហែល $10^{-7}$ m
-ម៉ូលេគុលឧស្ម័នអាចផ្លាស់ទីដោយសេរី តែម៉ូលេគុលក្នុងអង្គធាតុរាវនិងរឹងគឺត្រូវបានចង់ភ្ជាប់ដោយកម្លាំងរវាងម៉ូលេគុល( intermolecular force )។

(b) Interactions between point charges







# ២.២ លក្ខណៈម៉ូលេគុលនៃរូបធាតុ (Molecular properties of matter)

## ម៉ូលេគុល និង កម្លាំងរវាងម៉ូលេគុល( intermolecular force )







គ្រីស្តាល់នៃ NaCl




Scanning tunneling microscope of a silicon crystal 9.0 nm x 9.0 nm



## ២.៣ លក្ខណៈម៉ូលេគុលនៃរូបធាតុ (Molecular properties of matter)




### ការសន្មត់ក្នុងឧស្ម័នគម្រូ

១. ធុងមានមាឌ $V$ ផ្ទុកនូវម៉ូលេគុលឧស្ម័នមានម៉ាសដូចៗគ្នា $m$ និងចំនួនសរុប $N$ (មានតម្លៃធំ)

២. វិមាត្រម៉ូលេគុលតូចខ្លាំងបើធៀបនឹងទំហំធុង និង ចំងាយមធ្យមរវាងម៉ូលេគុល

៣. ម៉ូលេគុលទង្គិច(ជាទង្គិចខ្ទាត)តែជាមួយជញ្ជាំង ហើយចលនារបស់ម៉ូលេគុលគឺត្រង់ស្មើ ពេលមុននិងក្រោយទង្គិច។

៤. ជញ្ជាំងធុងគឺរឹងមាំល្អ មានម៉ាសធំខ្លាំង និង មិនផ្លាស់ទី។

## ២.៣ លក្ខណៈម៉ូលេគុលនៃរូបធាតុ (Molecular properties of matter)




### ទង្គិច និង សំពាធឧស្ម័ន

សំពាធ $p=\frac{F}{A}$ , រកកម្លាំងតាមណា? $\vec{F}' = m_{សរុប}\vec{a} = \frac{d\vec{P}}{dt} = \lim_{\Delta t\to 0}\frac{\Delta\vec{P}}{\Delta t}$

-សិក្សាទៅលើភាគល្អិតមួយដែលមានម៉ាស $m$

$$m|v_x| - (-m|v_x|) = 2m|v_x|$$

-ចំនួនម៉ូលេគុល $\frac{1}{2}\left(\frac{N}{V}\right)(A|v_x|dt)$

-បម្រែបម្រួលបរិមាណចលនាសរុបក្នុងរយៈពេល $dt$

$$dP_x = \frac{1}{2}\left(\frac{N}{V}\right)(A|v_x|dt)\,(2m|v_x|)$$

$$p = \frac{F}{A} = \frac{dP_x}{A\,dt} = \frac{Nmv_x^2}{V}$$




All molecules are assumed to have the same magnitude $|v_x|$ of $x$-velocity.

## ២.៣ លក្ខណៈម៉ូលេគុលនៃរូបធាតុ (Molecular properties of matter)




សំពាធ និង ថាមពលស៊ីនេទិចនៃម៉ូលេគុល

ល្បឿនម៉ូលេគុល $v^2 = v_x^2 + v_y^2 + v_z^2$

ល្បឿនម៉ូលេគុលជាមធ្យម $(v^2)_{av} = (v_x^2)_{av} + (v_y^2)_{av} + (v_z^2)_{av} = 3(v_x^2)_{av}$

$$p = \frac{Nmv_x^2}{V} \rightarrow pV = \frac{2}{3}N\left[\frac{1}{2}m(v^2)_{av}\right]$$

កន្សោម $\frac{1}{2}Nm(v^2)_{av} = K_{tr}$ ជាតម្លៃសរុបនៃថាមពលស៊ីនេទិចរំកិលឥតសណ្តាប់ធ្នាប់។

$$\left.\begin{array}{l} pV = \frac{2}{3}K_{tr} \\ pV = nRT \end{array}\right\} K_{tr} = \frac{3}{2}nRT = \frac{3}{2}NkT \rightarrow pV = NkT$$

$$k = \frac{R}{N_A} = \frac{8.134\ \text{J/mol}\cdot\text{K}}{6.022\times10^{23}\ \text{ម៉ូលេគុល/mol}} = 1.381\times10^{-23}\ \text{J/ម៉ូលេគុល}\cdot\text{K}$$

## ២.៣ លក្ខណៈម៉ូលេគុលនៃរូបធាតុ (Molecular properties of matter)




ល្បឿននៃម៉ូលេគុល

ល្បឿនប្រសិទ្ធ $v_{rms} = \sqrt{(v^2)_{av}} = \sqrt{\frac{3kT}{m}} = \sqrt{\frac{3RT}{M}}$

១. លើកជាការ៉េ
២. គិតមធ្យម
៣. បំពាក់ឫសការ៉េ

$M = N_A m$

$m$ ជាម៉ាសមួយម៉ូលេគុល

$M$ ជាម៉ាសម៉ូល = ម៉ាសមួយម៉ូលនៃម៉ូលេគុលឧស្ម័ន។

# ២.៤ ចំណុះកម្តៅ (Heat Capacities)




មាឌថេរ

ចំណុះកម្តៅនៃឧស្ម័ន

ចំណុះកម្តៅនៅមាឌថេរ $C_V$

$$K_{tr} = \frac{3}{2}nRT \quad \rightarrow dK_{tr} = \frac{3}{2}nR\,dT$$

$$Q = nC\Delta T \quad \rightarrow dQ = nC_V\,dT$$

កម្តៅដែលផ្ទេរទៅអោយឧស្ម័នមានមាឌថេរ ស្មើនឹង កំណើនថាមពលស៊ីនេទិច

$$dQ = dK_{tr}$$

$C_V = \frac{3}{2}R$ ចំណុះកម្តៅរបស់ឧស្ម័នម៉ូណូអាតូម

(ឧស្ម័នមានតែចលនារំកិល)

# ២.៤ ចំណុះកម្តៅ (Heat Capacities)

ចំណុះកម្តៅនៃឧស្ម័ន

$C_V = \frac{3}{2}R$ ចំណុះកម្តៅរបស់ឧស្ម័នម៉ូណូអាតូម

(ឧស្ម័នមានតែចលនារំកិល)

$C_V = \frac{5}{2}R$ ចំណុះកម្តៅរបស់ឧស្ម័នឌីអាតូម

(ឧស្ម័នមានតែចលនារំកិល+រង្វិល)

$C_V = \frac{7}{2}R$ ចំណុះកម្តៅរបស់ឧស្ម័នឌីអាតូម

(ឧស្ម័នមានតែចលនារំកិល+រង្វិល+រំញ័រ)

**TABLE 18.1** Molar Heat Capacities of Gases

| Type of Gas | Gas | $C_V$ (J/mol · K) |
|---|---|---|
| ម៉ូណូអាតូម | He | 12.47 |
| | Ar | 12.47 |
| ឌីអាតូម | $H_2$ | 20.42 |
| | $N_2$ | 20.76 |
| | $O_2$ | 20.85 |
| | CO | 20.85 |
| ប៉ូលីអាតូម | $CO_2$ | 28.46 |
| | $SO_2$ | 31.39 |
| | $H_2S$ | 25.95 |




រំកិល

រង្វិល

រំញ័រ

# ២.៤ ចំណុះកម្ដៅ (Heat Capacities)

ចំណុះកម្ដៅនៃឧស្ម័នអ៊ីដ្រូសែន






សាច់ដុំកន្ទ្រាក់ពេល
$T \geq 29$°C

# ២.៤ ចំណុះកម្ដៅ (Heat Capacities)

ចំណុះកម្ដៅនៃអង្គធាតុរឹង (សុពលភាពនៃគម្រូឧស្ម័នបរិសុទ្ធ)

$C_V = 3R = 24.9$ J/mol · K →





## ២.៥ ល្បឿននៃម៉ូលេគុល (Molecular Speeds)




ឧបករណ៍វាស់ល្បឿនភាគល្អិត




របាយនៃចំនួនឧស្ម័នតាមល្បឿន
និងឥទ្ធិពលនៃសីតុណ្ហភាព
( The Maxwell-Boltzmann Distributions )

## ២.៦ ភាពនៃរូបធាតុ (Phases of matter)



ចំណុចប្រសព្វទាំងបី

| Substance | Temperature (K) | Pressure (Pa) |
|---|---|---|
| អ៊ីដ្រូសែន | 13.80 | $0.0704 \times 10^5$ |
| ទឹកធ្ងន់ | 18.63 | $0.171 \times 10^5$ |
| ណេអុង | 24.56 | $0.432 \times 10^5$ |
| អាសូត | 63.18 | $0.125 \times 10^5$ |
| អុកស៊ីសែន | 54.36 | $0.00152 \times 10^5$ |
| អាម៉ូញ៉ាក់ | 195.40 | $0.0607 \times 10^5$ |
| កាបូនឌីអុកស៊ីត | 216.55 | $5.17 \times 10^5$ |
| ស៊ុលផួរឌីអុកស៊ីត | 197.68 | $0.00167 \times 10^5$ |
| ទឹក | 273.16 | $0.00610 \times 10^5$ |



## ២.៦ ភាពនៃរូបធាតុ (Phases of matter)

ដ្យាក្រាម *pVT*




គម្រូឧស្ម័នបរិសុទ្ធ




មិនគោរពតាមគម្រូឧស្ម័នបរិសុទ្ធ

# មេរៀនទី២ លក្ខណៈកម្ដៅនៃរូបធាតុ

# លំហាត់ឧទាហរណ៍

# (សៀវភៅក្រសួងអប់រំ)

គ្រេម សុណា 2024

## ២.១ សមីការភាពនៃឧស្ម័ន (Equations of state)

រូបវិទ្យាថ្នាក់ទី១១ ជំពូក ២ មេរៀនទី ២ ទំព័រ ១៣៩

***ឧទាហរណ៍ :*** គេយកបំពង់ខ្យល់មួយមានមាឌ $1.0m^3$ នៅសីតុណ្ហភាព $18°C$ ក្នុងសម្ពាធបរិយាកាស $p_1 = 1.0atm$ ទៅបណ្ណែននៅសីតុណ្ហភាពដដែល តែក្នុងសម្ពាធ $p_2 = 3.5atm$ ។ គណនាមាឌសម្រេចនៃខ្យល់ ?

✍ ដំណោះស្រាយ

នៅក្នុងភាពដើម $p_1 = 1atm$ និង $V_1 = 1m^3$

នៅក្នុងភាពស្រេច $p_2 = 3.5atm$

តាមរូបមន្ត $p_1V_1 = p_2V_2 \Rightarrow V_2 = V_1\frac{p_1}{p_2} \Rightarrow V_2 = 1 \times \frac{1}{3.5} = 0.286m^3$

ដូចនេះមាឌសម្រេចនៃខ្យល់គឺ $V_2 = 0.286m^3$ ។

## ២.១ សមីការភាពនៃឧស្ម័ន (Equations of state)

រូបវិទ្យាថ្នាក់ទី១១ ជំពូក ២ មេរៀនទី ២ ទំព័រ ១៤១

***ឧទាហរណ៍ :*** គេបូមខ្យល់បញ្ចូលកង់រថយន្តមួយឱ្យមានសម្ពាធ $2.5atm$ នៅសីតុណ្ហភាព $20°C$ ។ គណនាសម្ពាធខ្យល់នោះនៅសីតុណ្ហភាព $60°C$ (សន្មតថាមាឌខ្យល់ថេរ) ។

✍ ដំណោះស្រាយ

នៅក្នុងភាពដើម យើងមាន $T_1 = 20°C = 293K$ និង $p_1 = 2.5atm$

នៅក្នុងភាពស្រេច យើងមាន $T_2 = 60°C = 333K$

យើងបាន $\frac{p_2}{T_2} = \frac{p_1}{T_1} \Rightarrow p_2 = \frac{p_1}{T_1} \times T_2 = (2.5atm) \times \frac{333K}{293K} \approx 2.8atm$

$\boxed{p_2 = 2.8atm}$ ។

# ២.១ សមីការភាពនៃឧស្ម័ន (Equations of state)

រូបវិទ្យាថ្នាក់ទី១១ ជំពូក ២ មេរៀនទី ២ ទំព័រ ១៤២

***ឧទាហរណ៍ :*** គេយកបំពង់អ៊ីដ្រូសែនមានមាឌ $10\ell$ ក្រោមសម្ពាធ $p_1 = 200\text{atm}$ នៅសីតុណ្ហភាព $t_1 = 27°\text{C}$ ។ គេយកឧស្ម័នអ៊ីដ្រូសែននោះទៅបញ្ចូលក្នុងបាឡុងកៅស៊ូស្តើងមួយ ។ គណនាមាឌបាឡុង ។ បើមាឌឧស្ម័នក្នុងបាឡុង $p_2 = 1\text{atm}$ និង $t_2 = 7°\text{C}$ ។

✍ ដំណោះស្រាយ

គណនាមាឌបាឡុង

ក្នុងភាពដើម $T_1 = (273+27)\text{K}$ , $p_1 = 200\text{atm}$ , $V_1 = 10\ell$

ក្នុងភាពស្រេច $T_2 = (273+7)\text{K}$ , $p_2 = 1.0\text{atm}$

តាមសមីការ $\dfrac{p_2V_2}{T_2} = \dfrac{P_1V_1}{T_1} \Rightarrow V_2 = V_1\dfrac{p_1}{p_2}\cdot\dfrac{T_2}{T_1}$

$$\Rightarrow V_2 = 0.01\text{m}^3 \times \frac{200\text{atm}}{1\text{atm}} \times \frac{280\text{K}}{300\text{K}} \approx 1.87\text{m}^3 \Rightarrow V_2 = 1.87\text{m}^3$$

$\boxed{V_2 = 1.87\text{m}^3}$ ។

# ២.១ សមីការភាពនៃឧស្ម័ន (Equations of state)

រូបវិទ្យាថ្នាក់ទី១១ ជំពូក ២ មេរៀនទី ២ ទំព័រ ១៤៣

***ឧទាហរណ៍ :*** កែវបាឡុងមួយផ្ទុកអុកស៊ីសែនចំណុះ $1.0\ell$ នៅសីតុណ្ហភាព $t_1 = 27°\text{C}$ ក្រោមសម្ពាធ $p_0 = 1.0\text{atm}$ , $p = 2.0\text{atm}$ និងម៉ាសអាតូម $0 = 16$ ។ គណនាម៉ាសអុកស៊ីសែនក្នុងកែវបាឡុង ។

✍ ដំណោះស្រាយ

គណនាម៉ាសអុកស៊ីសែន ក្នុងកែវបាឡុង

តាមសម្មតិកម្ម $V = 1.0\ell$ , $\dfrac{p}{p_0} = \dfrac{2.0\text{atm}}{1.0\text{atm}} = 2.0$

ម្យ៉ាងទៀត $\dfrac{1}{1+\alpha t} = \dfrac{1}{1+\dfrac{27}{273}} = \dfrac{273}{300} = 0.91\ell$ $\left(\alpha = \dfrac{1}{273}\right)$

យើងមាន $pV = p_0V_0(1+\alpha t) \Rightarrow V_0 = V\dfrac{p}{p_0}\cdot\dfrac{1}{1+\alpha t} = 2\times\dfrac{1.0\ell}{0.91\ell} = 2.20\ell$

$V_0$ ជាមាឌរបស់ឧស្ម័ននៅក្នុងសីតុណ្ហភាព $t_1 = 27°\text{C}$ ដូចនេះ នៅក្នុងលក្ខខណ្ឌធម្មតា ឧស្ម័នបរិសុទ្ធក្នុងមួយម៉ូលមានមាឌស្មើនឹង $V = 22.41\ell$ ។

ចំនួនម៉ូលនៃឧស្ម័នអុកស៊ីសែននៅក្នុងកែវបាឡុងគឺ $n = \dfrac{2.20}{22.41}\text{mol}$ ដោយអាតូមអុកស៊ីសែនមួយម៉ូលស្មើ $M(O_2) = 16\times 2\text{g/mol} = 32\text{g/mol}$ ដូចនេះម៉ាសអុកស៊ីសែនក្នុងកែវបាឡុង $m = 32\text{g/mol}\times\dfrac{2.20}{22.41}\text{mol} = 3.13\text{g}$ ។

## ២.១ សមីការភាពនៃឧស្ម័ន (Equations of state)

រូបវិទ្យាថ្នាក់ទី១១ ជំពូក ២ មេរៀនទី ២ ទំព័រ ១៤៧

***ឧទាហរណ៍ :*** ប្រអប់មួយផ្ទុកឧស្ម័នបរិសុទ្ធមាន $V = 100cm^3$ និងសម្ពាធ $P = 100Pa$ នៅសីតុណ្ហភាព $t_1 = 20°C$ ។ គណនាចំនួនម៉ូលេគុលនៅក្នុងប្រអប់ ?

✍ ដំណោះស្រាយ

តាមសម្មតិកម្ម $P = 100Pa$ , $t_1 = 20°C$ , $V = 100cm^3$

តាមរូបមន្ត $PV = nRT \Rightarrow n = \frac{PV}{RT}$

យើងបាន $n = \frac{(100Pa)(10^{-4}m^3)}{(8.315J/molK)(273+20)K} = 4.10\times10^{-6}mol$

$n = 4.10\times10^{-6}mol$

ដូចនេះ $\boxed{n = 4.10\times10^{-6}\ mol}$ ។

## ២.១ សមីការភាពនៃឧស្ម័ន (Equations of state)

រូបវិទ្យាថ្នាក់ទី១២ ជំពូក ១ មេរៀនទី ១ ទំព័រ ៥

***ឧទាហរណ៍ :*** ផង់នីមួយៗមានម៉ាស $m_0$ និងផ្លាស់ទីដោយល្បឿន $\vec{v}$ តាមបណ្តោយអ័ក្សOx ។ គេដឹងថាក្នុងផ្ទៃ $1mm^2$ និងក្នុងមួយវិនាទីមានផង់ចំនួន $1\times10^{15}$ ទៅទង្គិចនឹងផ្ទៃនោះ ។ ចូររកសម្ពាធរបស់ផង់លើផ្ទៃប៉ះ ។ គេឱ្យ $m_0 = 9.1\times10^{-31}kg$ និង $v = 8\times10^7 m/s$ ។ គេសន្មតទង្គិចរវាងផង់នឹងផ្ទៃប៉ះជាទង្គិចស្ទក់ ។

# ២.១ សមីការភាពនៃឧស្ម័ន (Equations of state)

រូបវិទ្យាថ្នាក់ទី១២ ជំពូក ១ មេរៀនទី ១ ទំព័រ ៥

ដំណោះស្រាយ

សម្ពាធដែលផង់មានលើផ្ទៃដោយទង្គិចរវាងផង់ជាមួយនិងផ្ទៃខាង ជាទង្គិចស្ទក់បម្រែបម្រួលបរិមាណចលនាគឺ

$$\Delta\vec{P} = 0 - m_o\vec{v} = -m_o\vec{v}$$

កម្លាំងដែលផ្ទៃបញ្ចេញលើផង់

$$\vec{F'} = \frac{\Delta\vec{P}}{\Delta t} = -m_o\vec{v} \quad \text{តែ } \Delta t = 1\text{s}$$

$$\Rightarrow F' = m_o v$$

កម្លាំងដែលផង់ចំនួន N មានលើផ្ទៃគឺ

$$NF = Nm_o v$$

សម្ពាធដែល N ផង់មានលើផ្ទៃនោះ

$$P = \frac{NF}{A} = \frac{N}{A} \times m_o v$$

ដោយ $N = 1 \times 10^{15}$ , $A = 1\text{mm}^2 = 10^{-6}\text{m}^2$

$m_0 = 9.1 \times 10^{-31}\text{kg}$ , $v = 8 \times 10^7\text{m/s}$

យើងបាន $P = \dfrac{1 \times 10^{15} \times 9.1 \times 10^{-31}\text{kg} \times 8 \times 10^7\text{m/s}}{10^{-6}\text{m}^2}$

ដូចនេះ $\boxed{P = 7.3 \times 10^{-2}\text{Pa}}$ ។

# ២.១ សមីការភាពនៃឧស្ម័ន (Equations of state)

រូបវិទ្យាថ្នាក់ទី១២ ជំពូក ១ មេរៀនទី ១ ទំព័រ ៧

***ឧទាហរណ៍*** : ឧស្ម័នបរិសុទ្ធមួយមានមាឌ $V = 100\text{cm}^3$ ស្ថិតក្រោមសម្ពាធ $2.00 \times 10^5\text{Pa}$ នៅសីតុណ្ហភាព 20°C ។ តើឧស្ម័ននោះមានប៉ុន្មានម៉ូល ? ( $R = 8.31\text{J/(molK)}$ )

ដំណោះស្រាយ

ចំនួនម៉ូលនៃឧស្ម័ន

តាមសមីការឧស្ម័នបរិសុទ្ធ : $PV = nRT$

យើងទាញបាន $n = \dfrac{PV}{RT}$

ដោយ $P = 2.00 \times 10^5\text{Pa}$ , $V = 100\text{cm}^3 = 100 \times 10^{-6}\text{m}^3$

$R = 8.31\text{J/(molK)}$ , $T = t + 273 = 27°\text{C} + 273 = 300\text{K}$

យើងបាន $n = \dfrac{(2.00 \times 10^5\text{Pa}) \times (100 \times 10^{-6}\text{m}^3)}{8.31\text{J/(molK)}300\text{K}}$

$$\boxed{n = 0.08 \times 10^{-1}\text{mol}}$$

## ២.១ សមីការភាពនៃឧស្ម័ន (Equations of state)

រូបវិទ្យាថ្នាក់ទី១២ ជំពូក ១ មេរៀនទី ១ ទំព័រ ៨

***ឧទាហរណ៍ :*** ធុងមួយមានផ្ទុកអេល្យូម 2.00mol នៅសីតុណ្ហភាព 27°C ។ គេសន្មតថាអេល្យូមជាឧស្ម័នបរិសុទ្ធ ។

ក. គណនាតម្លៃមធ្យមនៃថាមពលស៊ីនេទិចរបស់ម៉ូលេគុលនីមួយៗ

ខ. គណនាថាមពលស៊ីនេទិចសរុបរបស់ម៉ូលេគុលទាំងអស់ ។

គេឱ្យ $k = 1.38\times10^{-23}\mathrm{J/K}$ , $R = 8.31\mathrm{J/(molK)}$

✍ ដំណោះស្រាយ

ក. តម្លៃមធ្យមនៃថាមពលស៊ីនេទិចរបស់ម៉ូលេគុលនីមួយៗ

តាមសមីការ

$K_{av} = \frac{3}{2}kT$ ដោយ $T = 273+27 = 300\mathrm{K}$

យើងបាន $K_{av} = \frac{3}{2}\times(1.38\times10^{-23}\mathrm{J/K})(300\mathrm{K})$

ដូចនេះ $\boxed{K_{av} = 6.21\times10^{-21}\mathrm{J}}$

ខ. ថាមពលស៊ីនេទិចសរុប

តាមសមីការ

$K = \frac{3}{2}nRT$ ដោយ $n = 2.00\mathrm{mol}$

យើងបាន $K = \frac{3}{2}\times(2.00\mathrm{mol})(8.31\mathrm{J/molK})(300\mathrm{K})$

ដូចនេះ $\boxed{K = 7.48\times10^{3}\mathrm{J}}$

## ២.១ សមីការភាពនៃឧស្ម័ន (Equations of state)

រូបវិទ្យាថ្នាក់ទី១២ ជំពូក ១ មេរៀនទី ១ ទំព័រ ៩

***ឧទាហរណ៍ :*** ចូរគណនាឫសការេនៃមធ្យមល្បឿនការេរបស់អាតូមអេល្យូមនៅសីតុណ្ហភាព 20.0°C ។ ម៉ាសម៉ូលអេល្យូមគឺ $4.00\times10^{-3}\mathrm{kg/mol}$ ។ គេឱ្យ $R = 8.31\mathrm{J/(molK)}$ ។

✍ ដំណោះស្រាយ

ឫសការេនៃមធ្យមល្បឿនការេរបស់អាតូម

តាមសមីការ $v_{rms} = \sqrt{\frac{3RT}{M}}$

ដោយ $R = 8.31\mathrm{J/(molK)}$ , $T = 273+20.0°\mathrm{C} = 293\mathrm{K}$ , $M = 4.00\times10^{-3}\mathrm{kg/mol}$

យើងបាន $v_{rms} = \sqrt{\frac{3\times8.31\mathrm{J/(molK)}(293\mathrm{K})}{4.00\times10^{-3}\mathrm{kg/mol}}}$

ដូចនេះ $\boxed{v_{rms} = 1.35\times10^{3}(\mathrm{m/s})}$ ។

# មេរៀនទី២ លក្ខណៈកម្ដៅនៃរូបធាតុ

## លំហាត់ពិភាក្សាក្រុម

**ក្រុម សុណា** 2024

## ២.១ សមីការភាពនៃឧស្ម័ន (Equations of state)

១.ស្តង់ដាសីតុណ្ហភាព និង សំពាធ (STP) គឺ $T = 0℃ = 273.15\ \mathrm{K}$ និង សំពាធ $p = 1\ \mathrm{atm} = 1.013 \times 10^5\ \mathrm{Pa}$។ ចូរគណនាមាឌនៃធុងដែលផ្ទុកឧស្ម័ននេះ ១ម៉ូល។ បើវាមានរាងជាគូប ចូរគណនាប្រវែងជ្រុងធុងនេះ។

ចម្លើយៈ

## ២.១ សមីការភាពនៃឧស្ម័ន (Equations of state)

២.ម៉ាស៊ីនរថយន្តមួយមានផ្ទុកនូវល្បាយនៃខ្យល់និងចំហាយសាំងដែលត្រូវបានបណ្ណែនក្នុងស៊ីឡាំងមុនពេលបញ្ឆេះ។ ម៉ាស៊ីនទូទៅគឺមានការបណ្ណែនឧស្ម័នក្នុងស៊ីឡាំងទៅ $\frac{1}{9.00}$ នៃមាឌដើមរបស់វា។ វ៉ាល់ខ្យល់ចូលនិងចេញគឺត្រូវបានបិទក្នុងពេលបណ្ណែនដូចនេះមិនមានឧស្ម័នលេចចេញទេ។ ចូរគណនាសីតុណ្ហភាពស្រេចរបស់ឧស្ម័ន ប្រសិនបើសីតុណ្ហភាពដើមគឺ 27.0 °C ហើយសំពាធមុននិងក្រោយគឺ 1.00 atm និង 21.7 atm រៀងគ្នា។

ចម្លើយៈ

## ២.១ សមីការភាពនៃឧស្ម័ន (Equations of state)

៣.ចូររៀបតាមលំដាប់លំដោយពីធំទៅតូចនៃចំនួនម៉ូលរបស់ឧស្ម័នខាងក្រោម។

(i) $p = 1$ atm, $V = 1$ L, $T = 300$ K។

(ii) $p = 2$ atm, $V = 1$ L, $T = 300$ K។

(iii) $p = 1$ atm, $V = 2$ L, $T = 300$ K។

(iv) $p = 1$ atm, $V = 1$ L, $T = 600$ K។

(v) $p = 2$ atm, $V = 1$ L, $T = 600$ K។

ចម្លើយៈ

## ២.១ សមីការភាពនៃឧស្ម័ន (Equations of state)

៤.ចូរគណនាម៉ាសរបស់អាតូមអ៊ីដ្រូសែនមួយ និង ម៉ាសរបស់ឧស្ម័នអុកស៊ីសែនមួយ។ $M(\mathrm{H}) = 1.008$ g/mol និង $M(\mathrm{O}) = 15.999$ g/mol។

ចម្លើយ៖

## ២.២ លក្ខណៈម៉ូលេគុលនៃរូបធាតុ (Molecular properties of matter)

៥.ឧបមាថាអ្នកអាចកែប្រែចម្ងាយរវាងម៉ូលេគុល $r_0$។ តើម៉ាសមាឌវានឹងកើនដល់ប៉ុន្មានដងនៃម៉ាសមាឌដើម បើអ្នកធ្វើអោយ $r_0$ កើនដល់ 2 ដងនៃតម្លៃដើម?

ចម្លើយ៖



## ២.៣ លក្ខណៈម៉ូលេគុលនៃរូបធាតុ (Molecular properties of matter)

៦.

(a) ចូរគណនាតម្លៃមធ្យមនៃថាមពលស៊ីនេទិចរំកិលរបស់មួយម៉ូលេគុលនៃឧស្ម័នបរិសុទ្ធដែលមានសីតុណ្ហភាព 27℃។

(b) ចូរគណនាតម្លៃសរុបនៃថាមពលស៊ីនេទិចរំកិលរបស់ម៉ូលេគុលឧស្ម័នមួយម៉ូល។

(c) កំណត់តម្លៃល្បឿនប្រសិទ្ធនៃម៉ូលេគុលអុកស៊ីសែននៅសីតុណ្ហភាពខាងលើ។ $M(\mathrm{O}) = 15.999\ \mathrm{g/mol}$។

ចម្លើយ៖

## ២.៣ លក្ខណៈម៉ូលេគុលនៃរូបធាតុ (Molecular properties of matter)

៧.ម៉ូលេគុលឧស្ម័នចំនួនប្រាំមានល្បឿន $500, 600, 700, 800,$ និង $900\ \mathrm{m/s}$ ។ ចូរគណនាតម្លៃល្បឿនប្រសិទ្ធ និង តម្លៃល្បឿនមធ្យម។

ចម្លើយ៖

## ២.៣ លក្ខណៈម៉ូលេគុលនៃរូបធាតុ (Molecular properties of matter)

៨.ចូររៀបតាមលំដាប់ពីធំទៅតូចនូវ (a) តម្លៃល្បឿនប្រសិទ្ធ (b) តម្លៃមធ្យមនៃថាមពលស៊ីនេទិចរំកិលរបស់មួយម៉ូលេគុល។ (i) ឧស្ម័នអុកស៊ីសែន($M = 32.0$ g/mol) នៅ 300 K។ (ii) ឧស្ម័ននីត្រូសែន($M = 28.0$ g/mol) នៅ 300 K។ (iii) ឧស្ម័នអុកស៊ីសែននៅ 330 K។ (iv) ឧស្ម័ននីត្រូសែននៅ 330 K។

ចម្លើយ៖

## ២.៤ ចំណុះកម្ដៅ (Heat Capacities)

៩.ធុងស៊ីឡាំងមួយមានមាឌថេរ និង ផ្ទុកនូវឧស្ម័នអ៊ីដ្រូសែន ($H_2$) នៅ 25 K។ អ្នកបានបញ្ជូនកម្ដៅទៅអោយធុងដោយអត្រាថេររហូតដល់វាមានសីតុណ្ហភាព 500 K ។ តើសីតុណ្ហភាពរបស់ឧស្ម័នកើនដោយអត្រាថេរ? ហេតុអ្វី? ប្រសិនបើអត់ទេ តើសីតុណ្ហភាពកើនលឿននៅម្ដុំចំណុចដើមនៃដំណើរការ ឬ ម្ដុំចំណុចបញ្ចប់នៃដំណើរការ?

ចម្លើយ៖

## ២.៦ ភាពនៃរូបធាតុ (Phases of matter)

១០.តម្លៃមធ្យមនៃសំពាធនៅភពអង្គារគឺ $6.0 \times 10^2$ Pa។ តើវាអាចមានវត្ថុមានស្រះទឹក(រាវ)នៅលើផ្ទៃនៃភពអង្គារសព្វថ្ងៃនេះដែរឬទេ? ចុះក្នុងអតីតកាល បើ*អ្នកវិទ្យាសាស្ត្រជំនាញអំពីភព*ប៉ាន់ស្មានថាសំពាធមានតម្លៃធំជាងនេះគួរសមដែរ?

ចម្លើយ៖

# មេរៀនទី២ លក្ខណៈកម្ដៅនៃរូបធាតុ

# លំហាត់ស្រាវជ្រាវបន្ថែម

# (សៀវភៅក្រសួងអប់រំ)

## ២.១ សមីការភាពនៃឧស្ម័ន (Equations of state)

រូបវិទ្យាថ្នាក់ទី១១ ជំពូក ២ មេរៀនទី ២ ទំព័រ ១៤៨

6. ដបមួយផ្ទុកឧស្ម័នមានមាឌថេរក្រោមសម្ពាធ $p_0 = 1.0\text{atm}$ នៅសីតុណ្ហភាព $t = 17°C$ ។ តើគេត្រូវកម្តៅឧស្ម័ននេះដល់សីតុណ្ហភាពប៉ុន្មានអង្សាសេលស្យុស ដើម្បីឱ្យសម្ពាធវាមានតម្លៃ $1.5\text{atm}$ ?

7. គេបញ្ចូលឧស្ម័នអ៊ីដ្រូសែនទៅក្នុងបាឡុងមួយដែលមានមាឌ $100\text{m}^3$ នៅសីតុណ្ហភាព $7°C$ ។ ក្រោមសម្ពាធ $0.7\text{atm}$ ។ ដើម្បីបំប៉ោងបាឡុងនេះគេប្រើបំពង់អ៊ីដ្រូសែនប៉ុន្មាន ? បើបំពង់មួយមានអ៊ីដ្រូសែន $20\ell$ ក្រោមសម្ពាធ $1.50\text{atm}$ នៅសីតុណ្ហភាព $27°C$ គេសន្មតថាឧស្ម័ននៅក្នុងបំពង់ត្រូវបានបញ្ចូលទៅក្នុងបាឡុងទាំងអស់ ។

## ២.១ សមីការភាពនៃឧស្ម័ន (Equations of state)

រូបវិទ្យាថ្នាក់ទី១១ ជំពូក ២ មេរៀនទី ២ ទំព័រ ១៤៩

8. គេយកបំពង់អុកស៊ីសែនមួយមានចំណុះ $20\ell$ នៅសម្ពាធ $P_1 = 200\text{atm}$ និងសីតុណ្ហភាព $t = 20°C$ ទៅបញ្ចូលឧស្ម័នក្នុងបាឡុងកៅស៊ូស្តើងមួយ ។ គណនាមាឌបាឡុង ។ ដោយដឹងថាឧស្ម័នក្នុងបាឡុង $P_2 = 1\text{atm}$ ។

9. បាឡុងមួយចំណុះ $20\ell$ មានសម្ពាធឧស្ម័នអ៊ីដ្រូសែន $P_o = 10\text{atm}$ នៅសីតុណ្ហភាព $t = 27°C$ និងសម្ពាធ $P = 20\text{atm}$ ។ នៅក្នុងលក្ខខណ្ឌធម្មតាឧស្ម័នក្នុងមួយម៉ូលមានមាឌ $V_{gas} = 22.4\ell$ និង $M_{(H_2)} = 2.0\text{g/mol}$ ។ គណនាម៉ាសអ៊ីដ្រូសែនក្នុងបាឡុង ។

10. ប្រអប់មួយផ្ទុកឧស្ម័នបរិសុទ្ធមានមាឌ $V = 200\text{cm}^3$ និងសម្ពាធ $P = 10\text{atm}$ នៅសីតុណ្ហភាព $t = 27°C$ ។ គណនាចំនួនម៉ូលេគុលនៅក្នុងប្រអប់ ?

## ២.១ សមីការភាពនៃឧស្ម័ន (Equations of state)

រូបវិទ្យាថ្នាក់ទី១១ ជំពូក ២ មេរៀនទី ២ ទំព័រ ១៤៩

11. គណនាម៉ាសឧស្ម័នក្នុងពោះវៀនកង់មួយមានមាឌ 200ℓ នៅសីតុណ្ហភាព 27°C ។ គេឱ្យឧស្ម័នមានម៉ាសម៉ូល $M = 2.0g/mol$ និងសម្ពាធបរិយាកាស $P = 100Pa$ ។

12. បាល់មូលមួយផ្ទុកអ៊ីដ្រូសែនត្រូវបានបណ្ណែននៅសម្ពាធ $P_1 = 15MPa$ និងនៅសីតុណ្ហភាព 37°C មានម៉ាស $M_1 = 50kg$ ។ មួយរយៈក្រោយសម្ពាធ $P_2 = 5.0MPa$ នៅសីតុណ្ហភាព 7°C ម៉ាសរបស់កែវបាឡុងនិងឧស្ម័ន $M_2 = 49kg$ ។

    ក. គណនាម៉ាសអ៊ីដ្រូសែននៅសល់ក្នុងកែវបាឡុង ។

    ខ. គណនាមាឌ V របស់បំពង់ ។ គេឱ្យម៉ាសម៉ូលរបស់អ៊ីដ្រូសែន $M = 2.0g/mol$ ។

## ២.១ សមីការភាពនៃឧស្ម័ន (Equations of state)

រូបវិទ្យាថ្នាក់ទី១១ ជំពូក ២ មេរៀនទី ២ ទំព័រ ១៥១

1. នៅក្រោមសម្ពាធ 1atm នៅសីតុណ្ហភាព 15°C ខ្យល់មានមាឌ 2ℓ ។ ពេលខ្យល់នៅសីតុណ្ហភាព 20°C និងមានមាឌ 2ℓ តើសម្ពាធវាមានតម្លៃប៉ុន្មាន ?

2. តើគេត្រូវកម្តៅឧស្ម័ននេះដល់សីតុណ្ហភាពប៉ុន្មាន ដើម្បីឱ្យសម្ពាធវាថេរ ហើយមាឌរបស់វាធំជាងពីរដង ? គេឱ្យសីតុណ្ហភាពដើម 0°C ។

3. នៅសីតុណ្ហភាព 0°C បរិមាណអ៊ីដ្រូសែនមានមាឌ 3ℓ ។ គណនាមាឌរបស់វានៅសីតុណ្ហភាព 73°C ? ដោយដឹងថាសម្ពាធរបស់វាថេរ ។

4. គេយកបំពង់ខ្យល់មួយមានមាឌ $1m^3$ នៅសីតុណ្ហភាព 18°C ក្រោមសម្ពាធ 3.5atm ទៅបណ្ណែនវាឱ្យចុះពី 3.5atm ទៅ 3.1atm ដោយរក្សាសីតុណ្ហភាពឱ្យនៅដដែល ។ គណនាមាឌសម្រេចនៃខ្យល់ ។

## ២.១ សមីការភាពនៃឧស្ម័ន (Equations of state)

រូបវិទ្យាថ្នាក់ទី១១ ជំពូក ២ មេរៀនទី ២ ទំព័រ ១៥២

5. បំពង់បារ៉ីតមួយមានមុខកាត់តូច មានប្រវែង $\ell = 1m$ ក្បាលទាំងពីររបស់វាបិទជិត ខាងក្នុងបំពង់បារ៉ីតមានប្រវែង $\ell_1 = 20cm$ និងមានសម្ពាធ $P_0 = 50cmHg$ ។ ពេលបញ្ឈរបំពង់នោះត្រង់ទៅលើ តើបារ៉ីតនោះមានកម្ពស់ប៉ុន្មាន ?

6. គេយកបំពង់សាកពីរមានមាឌ $10\ell$ ផ្ទុកឧស្ម័ននៅសីតុណ្ហភាព $0°C$ និងសម្ពាធខ្យល់ $P_o = 1.0atm$ ។ បន្ទាប់មកគេចាក់ទឹកចូលទៅក្នុងបំពង់សាកទី $1$ និងទី $2$ នូវបរិមាណទឹក $m_1 = 3g$ និង $m_2 = 15g$ ក្រោយមកគេដុតកម្តៅវារហូតដល់សីតុណ្ហភាព $100°C$ ។ គណនាសម្ពាធរបស់ឧស្ម័ននៅក្នុងបំពង់នោះ និងម៉ាសទឹកដែលនៅសល់ ។

7. បាល់កៅស៊ូមានមាឌ $3\ell$ ត្រូវបានគេយកទៅសប់ដោយស្នប់ដៃមួយ ស្នប់នោះសប់ខ្យល់បាន $p_1 = 10^5 N/m^2$ ។ ដោយដឹងថាស្នប់នោះមានកម្ពស់ $40cm$ និងមានមុខកាត់ $d = 6cm$ ។ តើត្រូវសប់ប៉ុន្មានដងដើម្បីឱ្យខ្យល់ក្នុងបាល់មានសម្ពាធ $P = 5 \times 10^5 N/m^2$

## ២.១ សមីការភាពនៃឧស្ម័ន (Equations of state)

រូបវិទ្យាថ្នាក់ទី១១ ជំពូក ២ មេរៀនទី ២ ទំព័រ ១៥២

8. ប្រអប់មួយផ្ទុកឧស្ម័នបរិសុទ្ធមានមាឌ $20m^3$ សម្ពាធ $10atm$ នៅសីតុណ្ហភាព $20°C$ ។ គណនាចំនួនម៉ូលេគុលនៅក្នុងប្រអប់ ។

9. បំពង់ឧស្ម័នអុកស៊ីសែនមួយបណ្ដែននូវសម្ពាធ $P = 10^4 MPa$ និងសីតុណ្ហភាព $43°C$ មានម៉ាស $M_1 = 70kg$ ។ នៅពេលគេប្រើប្រាស់បានមួយរយៈ សម្ពាធ $P_2 = 5 \times 10^2 MPa$ នៅសីតុណ្ហភាព $17°C$ ម៉ាសរបស់កែវបាឡុងនិងឧស្ម័ន $M_2 = 59kg$ ។ គណនាម៉ាសអុកស៊ីសែននៅសល់ក្នុងកែវបាឡុង និងមាឌ $V$ របស់បំពង់ ។ គេឱ្យម៉ាសម៉ូលរបស់អុកស៊ីសែន $32g/mol$ ។

10. គណនាបរិមាណឧស្ម័នក្នុងពោងមួយដែលមានមាឌ $500\ell$ នៅសីតុណ្ហភាព $40°C$ ។ គេឱ្យម៉ាសម៉ូលនៃឧស្ម័ន $M = 32g/mol$ និងសម្ពាធបរិយាកាស $P = 20atm$ ។

# ២.១ សមីការភាពនៃឧស្ម័ន (Equations of state)

រូបវិទ្យាថ្នាក់ទី១២ ជំពូក ១ មេរៀនទី ១ ទំព័រ ៧

**លំហាត់ប្រតិបត្តិ**

ឧស្ម័នបរិសុទ្ធមួយមាន $n = 0.08 \times 10^{-1}\text{mol}$ មានសម្ពាធ $P = 5.00 \times 10^{5}\text{Pa}$ នៅសីតុណ្ហភាព $60°C$ ។ តើឧស្ម័ននោះមានមាឌប៉ុន្មាន ?

រូបវិទ្យាថ្នាក់ទី១២ ជំពូក ១ មេរៀនទី ១ ទំព័រ ៨

**លំហាត់ប្រតិបត្តិ**

នៅក្នុងធុងមួយដែលមានមាឌ $2.00\text{ml}$ មានឧស្ម័នដែលមានម៉ាស $50\text{mg}$ និងសម្ពាធ $100\text{kPa}$ ។ ម៉ាសរបស់ម៉ូលេគុលនៃឧស្ម័ននីមួយៗគឺ $8.0 \times 10^{-26}\text{kg}$ ។

ក. រកចំនួនម៉ូលេគុលនៃឧស្ម័ននោះ ។

ខ. រកតម្លៃមធ្យមនៃថាមពលស៊ីនេទិចរបស់ម៉ូលេគុលនីមួយៗ

គេឱ្យ $k = 1.38 \times 10^{-23}\text{J/K}$

# ២.១ សមីការភាពនៃឧស្ម័ន (Equations of state)

រូបវិទ្យាថ្នាក់ទី១២ ជំពូក ១ មេរៀនទី ១ ទំព័រ ១០

**លំហាត់ប្រតិបត្តិ**

រកឫសការេនៃមធ្យមល្បឿនការេរបស់ម៉ូលេគុលអុកស៊ីសែននៅសីតុណ្ហភាព $200°C$ ។ ម៉ាសម៉ូលអុកស៊ីសែន $52 \times 10^{-3}\text{kg/mol}$ និង $R = 8.31\text{J/molK}$ ។

## ២.១ សមីការភាពនៃឧស្ម័ន (Equations of state)

រូបវិទ្យាថ្នាក់ទី១២ ជំពូក ១ មេរៀនទី ១ ទំព័រ ១១

5. នៅសីតុណ្ហភាព 293K និងសម្ពាធ 5atm មេតាន 1kmol មានម៉ាស 16.0kg ។ គណនាម៉ាសមាឌនៃមេតានក្នុងលក្ខខណ្ឌខាងលើ ។

   គេឱ្យ $R = 8.31 J/(mol \cdot K)$ ។ **ចម្លើយ :** $\rho = 3.33 kg/m^3$

6. នៅក្នុងបំពង់បិទជិតដែលមានមាឌ 20ml នៅសីតុណ្ហភាពកំណត់មួយយ៉ាងទាបមានតំណក់នីត្រូសែនរាវមានម៉ាស 50mg ។ គណនាសម្ពាធនីត្រូសែននៅក្នុងបំពង់នោះ កាលណាបំពង់នោះមានសីតុណ្ហភាព 300K ដោយសន្មតថានីត្រូសែននេះជាឧស្ម័នបរិសុទ្ធ ។

   គេឱ្យ $R = 8.31 J/(mol \cdot K)$ ។ **ចម្លើយ :** $P = 2.20 atm$

7. ក. គណនាម៉ាសម៉ូលេគុលនៃអ៊ីដ្រូសែន ។ គេឱ្យម៉ាសម៉ូលគឺ $M = 2.016 \times 10^{-3} kg/mol$ ចំនួនអាវ៉ូកាដ្រូ $N_A = 6.02 \times 10^{23} /mol$ ។

   ខ. គណនាតម្លៃឫសការេនៃមធ្យមល្បឿនការេរបស់ឧស្ម័នអ៊ីដ្រូសែននៅសីតុណ្ហភាព 100°C ។

   គ. គណនាតម្លៃមធ្យមនៃថាមពលស៊ីនេទិចរបស់ម៉ូលេគុលនៃឧស្ម័នអ៊ីដ្រូសែននីមួយៗនៅសីតុណ្ហភាព 100°C ។ គេឱ្យ $k = 1.38 \times 10^{-23} J/K$

   **ចម្លើយ :** ក. $m = 3.35 \times 10^{-27} kg$ ខ. $v_{rms} = 2.15 km/s$ គ. $K_{av} = 7.72 \times 10^{-21} J$

# មេរៀនទី២ លក្ខណៈកម្តៅនៃរូបធាតុ

## លំហាត់ពិភាក្សាក្រុម

ក្រុម សុណា 2024

## ២.១ សមីការភាពនៃឧស្ម័ន (Equations of state)

១.ស្តង់ដាសីតុណ្ហភាព និង សំពាធ (STP) គឺ $T = 0℃ = 273.15\ \mathrm{K}$ និង សំពាធ $p = 1\ \mathrm{atm} = 1.013 \times 10^5\ \mathrm{Pa}$។ ចូរគណនាមាឌនៃធុងដែលផ្ទុកឧស្ម័ននេះ ១ម៉ូល។ បើវាមានរាងជាគូប ចូរគណនាប្រវែងជ្រុងធុងនេះ។

ចម្លើយ៖

## ២.១ សមីការភាពនៃឧស្ម័ន (Equations of state)

២.ម៉ាស៊ីនរថយន្តមួយមានផ្ទុកនូវល្បាយនៃខ្យល់និងចំហាយសាំងដែលត្រូវបានបណ្ណែនក្នុងស៊ីឡាំងមុនពេលបញ្ឆេះ។ ម៉ាស៊ីនទូទៅគឺមានការបណ្ណែនឧស្ម័នក្នុងស៊ីឡាំងទៅ $\frac{1}{9.00}$ នៃមាឌដើមរបស់វា។ វ៉ាល់ខ្យល់ចូលនិងចេញគឺត្រូវបានបិទក្នុងពេលបណ្ណែន ដូចនេះមិនមានឧស្ម័នលេចចេញទេ។ ចូរគណនាសីតុណ្ហភាពស្រេចរបស់ឧស្ម័ន ប្រសិនបើសីតុណ្ហភាពដើមគឺ 27.0 °C ហើយសំពាធមុននិងក្រោយគឺ 1.00 atm និង 21.7 atm រៀងគ្នា។

ចម្លើយ៖

## ២.១ សមីការភាពនៃឧស្ម័ន (Equations of state)

៣.ចូររៀបតាមលំដាប់លំដោយពីធំទៅតូចនៃចំនួនម៉ូលរបស់ឧស្ម័នខាងក្រោម។

(i) $p = 1$ atm, $V = 1$ L, $T = 300$ K។

(ii) $p = 2$ atm, $V = 1$ L, $T = 300$ K។

(iii) $p = 1$ atm, $V = 2$ L, $T = 300$ K។

(iv) $p = 1$ atm, $V = 1$ L, $T = 600$ K។

(v) $p = 2$ atm, $V = 1$ L, $T = 600$ K។

ចម្លើយ៖

## ២.១ សមីការភាពនៃឧស្ម័ន (Equations of state)

៤.ចូរគណនាម៉ាសរបស់អាតូមអ៊ីដ្រូសែនមួយ និង ម៉ាសរបស់ឧស្ម័នអុកស៊ីសែនមួយ។ $M(\mathrm{H}) = 1.008\ \mathrm{g/mol}$ និង $M(\mathrm{O}) = 15.999\ \mathrm{g/mol}$។

ចម្លើយ៖

A. $m_{\mathrm{H}} = 1.647 \times 10^{-24}\ \mathrm{g}$ និង $m_{\mathrm{O_2}} = 51.3 \times 10^{-24}\ \mathrm{g}$។

B. $m_{\mathrm{H}} = 1.647 \times 10^{-24}\ \mathrm{g}$ និង $m_{\mathrm{O_2}} = 53.1 \times 10^{-24}\ \mathrm{g}$។

C. $m_{\mathrm{H}} = 1.674 \times 10^{-24}\ \mathrm{g}$ និង $m_{\mathrm{O_2}} = 51.3 \times 10^{-24}\ \mathrm{g}$។

D. $m_{\mathrm{H}} = 1.674 \times 10^{-24}\ \mathrm{g}$ និង $m_{\mathrm{O_2}} = 53.1 \times 10^{-24}\ \mathrm{g}$។

E. ដោះស្រាយមិនចេញ។

## ២.២ លក្ខណៈម៉ូលេគុលនៃរូបធាតុ (Molecular properties of matter)

៥.ឧបមាថាអ្នកអាចកែប្រែចម្ងាយរវាងម៉ូលេគុល $r_0$។ តើម៉ាសមាឌវានឹងកើនដល់ប៉ុន្មានដងនៃម៉ាសមាឌដើម បើអ្នកធ្វើអោយ $r_0$ កើនដល់ 2 ដងនៃតម្លៃដើម?

ចម្លើយ៖



# ២.៣ លក្ខណៈម៉ូលេគុលនៃរូបធាតុ (Molecular properties of matter)

៦.

(a) ចូរគណនាតម្លៃមធ្យមនៃថាមពលស៊ីនេទិចរំកិលរបស់មួយម៉ូលេគុលនៃឧស្ម័នបរិសុទ្ធដែលមានសីតុណ្ហភាព 27°C។

(b) ចូរគណនាតម្លៃសរុបនៃថាមពលស៊ីនេទិចរំកិលរបស់ម៉ូលេគុលឧស្ម័នមួយម៉ូល។

(c) កំណត់តម្លៃល្បឿនប្រសិទ្ធនៃម៉ូលេគុលអុកស៊ីសែននៅសីតុណ្ហភាពខាងលើ។ $M(O) = 15.999$ g/mol។

ចម្លើយ៖

# ២.៣ លក្ខណៈម៉ូលេគុលនៃរូបធាតុ (Molecular properties of matter)

៧.ម៉ូលេគុលឧស្ម័នចំនួនប្រាំមានល្បឿន 500, 600, 700, 800, និង 900 m/s ។ ចូរគណនាតម្លៃល្បឿនប្រសិទ្ធ និង តម្លៃមធ្យមនៃល្បឿន។

ចម្លើយ៖

## ២.៣ លក្ខណៈម៉ូលេគុលនៃរូបធាតុ (Molecular properties of matter)

៨.ចូររៀបតាមលំដាប់ពីធំទៅតូចនូវ (a) តម្លៃល្បឿនប្រសិទ្ធ (b) តម្លៃមធ្យមនៃថាមពលស៊ីនេទិចរំកិលរបស់មួយម៉ូលេគុល។
(i) ឧស្ម័នអុកស៊ីសែន($M = 32.0$ g/mol) នៅ 300 K។ (ii) ឧស្ម័ននីត្រូសែន ($M = 28.0$ g/mol) នៅ 300 K។ (iii) ឧស្ម័នអុកស៊ីសែននៅ 330 K។ (iv) ឧស្ម័ននីត្រូសែននៅ 330 K។

ចម្លើយ៖

## ២.៤ ចំណុះកម្ដៅ (Heat Capacities)

៩.ធុងស៊ីឡាំងមួយមានមាឌថេរ និង ផ្ទុកនូវឧស្ម័នអ៊ីដ្រូសែន ($H_2$) នៅ 25 K។ អ្នកបានបញ្ជូនកម្ដៅទៅអោយធុងដោយអត្រាថេររហូតដល់វាមានសីតុណ្ហភាព 500 K ។ តើសីតុណ្ហភាពរបស់ឧស្ម័នកើនដោយអត្រាថេរ? ហេតុអ្វី? ប្រសិនបើអត់ទេ តើសីតុណ្ហភាពកើនលឿននៅម្តុំចំណុចដើមនៃដំណើរការ ឬ ម្តុំចំណុចបញ្ចប់នៃដំណើរការ?

ចម្លើយ៖

# ២.៦ ភាពនៃរូបធាតុ (Phases of matter)

១០.តម្លៃមធ្យមនៃសំពាធនៅភពអង្គារគឺ $6.0 \times 10^2$ Pa។ តើវាអាចមានវត្តមានស្រះទឹក(រាវ)នៅលើផ្ទៃនៃភពអង្គារសព្វថ្ងៃនេះដែរឬទេ? ចុះក្នុងអតីតកាល បើ*អ្នកវិទ្យាសាស្ត្រជំនាញអំពីភព*បាន់ស្មានថាសំពាធមានតម្លៃធំជាងនេះគួរសមដែរ?

ចម្លើយ៖

មេរៀនទី

# 2 ច្បាប់ទី១នៃទែម៉ូឌីណាមិច

**ចប់មេរៀននេះ សិស្សអាច**

- ❑ បង្ហាញពីប្រព័ន្ធទែម៉ូឌីណាមិចបានច្បាស់លាស់
- ❑ ពោលច្បាប់ទី I ទែម៉ូឌីណាមិចបានត្រឹមត្រូវ
- ❑ សរសេរទំនាក់ទំនងរវាងកម្មន្ត សម្ពាធនិងមាឌបានត្រឹមត្រូវ
- ❑ សរសេរគោលការណ៍សមមូលបានច្បាស់លាស់
- ❑ មានបម្រុងប្រយ័ត្នក្នុងការប្រើប្រាស់កម្មន្ត កម្ដៅនិងថាមពលក្នុងជីវភាពរស់នៅ ។

## 1. ប្រព័ន្ធនៃទែម៉ូឌីណាមិច

### 1.1. ប្រព័ន្ធ

ឧបមាយើងសិក្សាឧស្ម័ន G ដែលបិតក្នុងស៊ីឡាំង C បិទដោយពីស្តុង P [រូបទី 2.1 (ក)] និងសិក្សាល្បាយទឹកកកនិងទឹកដែលដាក់ក្នុងស៊ីឡាំង C និងបិទដោយពីស្តុង P [រូបទី 2.1 (ខ)] ។



(ក) (ខ)
រូបទី 2.1 (ក) ឧស្ម័ន G (ខ) ល្បាយទឹកកកទឹក

- ប្រព័ន្ធមាន : ឧស្ម័ន G ល្បាយទឹកកក-ទឹក
- មជ្ឈដ្ឋានក្រៅមាន : ស៊ីឡាំង C ពីស្តុង P និងវត្ថុផ្សេងៗទៀត ។

ដូចនេះប្រព័ន្ធ គឺជាវត្ថុ ឬសំណុំវត្ថុដែលយើងលើកមកសិក្សា បើធៀបនិងវត្ថុដទៃ (មជ្ឈដ្ឋានក្រៅ) ។

### 1.2. ភាពនៃប្រព័ន្ធ

ភាពនៃប្រព័ន្ធនៅខណៈមួយជាសំណុំលេខ ដែលវាស់ទំហំរូបវិទ្យាទាំងឡាយសម្រាប់សម្គាល់ប្រព័ន្ធនៅខណៈនោះ ។





***ឧទាហរណ៍*** : តាមរូប 2.1 (ក) នៅខណៈដើម ឧស្ម័ន G មានម៉ាស $m_1$ មាឌ $V_1$ សម្ពាធ $P_1$ និងសីតុណ្ហភាពដាច់ខាត $T_1$ ។ នៅខណៈស្រេចឧស្ម័ននោះមានម៉ាស $m_2$ មាឌ $V_2$ សម្ពាធ $P_2$ និងសីតុណ្ហភាពដាច់ខាត $T_2$ ។ ដូចនេះទំហំ $m_1$ , $V_1$ , $P_1$ និង $T_1$ សម្គាល់ភាពឧស្ម័ននោះនៅខណៈដើមនិងចំនួន $m_2$ $V_2$ $P_2$ និង $T_2$ សម្គាល់ភាពឧស្ម័ននៅខណៈស្រេច ។ ចំពោះប្រព័ន្ធឧស្ម័ននោះ ម៉ាស m ជាទំហំថេរ ឯសម្ពាធ មាឌ និងសីតុណ្ហភាពប្រែប្រួល ។ ដូចនេះមាឌ សម្ពាធនិងសីតុណ្ហភាពជា " **អថេរសម្គាល់ភាពរបស់ប្រព័ន្ធ** " ។

### 1.3. បំលែងទែម៉ូឌីណាមិច

#### ក. បំលែងទែម៉ូឌីណាមិច

ប្រព័ន្ធមួយទទួលបំលែងទែម៉ូឌីណាមិច កាលណាវាផ្លាស់ប្តូរភាពដោយប្តូរតែកម្មន្តនិងកម្ដៅជាមួយមជ្ឈដ្ឋានក្រៅតែប៉ុណ្ណោះ ។

ប្រព័ន្ធចេញពីភាពដើមទៅភាពស្រេច ដោយឆ្លងកាត់ភាពបន្តបន្ទាប់ជាច្រើន ។ ភាពបន្តបន្ទាប់ទាំងនោះហៅថា **ភាពកណ្តាល** ។ បន្សំភាពបន្តបន្ទាប់ដែលភ្ជាប់ភាពដើមទៅភាពស្រេចបានជា "**ដំណើរប្រព្រឹត្តទៅ** " នៃប្រព័ន្ធ ។

#### ខ. បំលែងចំហ-បំលែងបិទ

ប្រព័ន្ធមួយទទួលបំលែងទែម៉ូឌីណាមិចៈ

- បើភាពដើមនិងភាពស្រេចខុសគ្នា ប្រព័ន្ធទទួលបំលែងចំហ ។
- បើភាពដើមនិងភាពស្រេចដូចគ្នា ប្រព័ន្ធទទួលបំលែងបិទ ។

### 1.4. ប្រព័ន្ធទែម៉ូឌីណាមិច

ប្រព័ន្ធទែម៉ូឌីណាមិចមួយ គឺជាប្រព័ន្ធដែលទទួលបំលែងទែម៉ូឌីណាមិច អាចចេញពីភាពដើមមួយទៅភាពស្រេចមួយ តាមដំណើរប្រព្រឹត្តខុសៗគ្នាបាន ។

តាមរូប 2.1 (ក) បើគេផ្តល់កម្ដៅឱ្យប្រព័ន្ធឧស្ម័ន G ប្រព័ន្ធនោះស្រូបកម្ដៅ Q ។ សីតុណ្ហភាព សម្ពាធនិងមាឌឧស្ម័នកើនឡើងធ្វើឱ្យវាច្រានពីស្តុងពី P ទៅ P' ។ ប្រព័ន្ធឧស្ម័នទទួលបំលែងទែម៉ូឌីណាមិចបានស្រូបកម្ដៅ Q ពីមជ្ឈដ្ឋានក្រៅ ហើយបានផ្តល់កម្មន្ត W ទៅមជ្ឈដ្ឋានក្រៅវិញ (កម្មន្តនៃកម្លាំងរុញច្រានពីស្តុងឡើងលើ) ។ គេនឹងថាកម្មន្តនេះស្មើនឹងតម្លៃដាច់ខាតនៃកម្មន្តទប់របស់ខ្យល់ទៅលើពីស្តុង ។

***ឧទាហរណ៍ :*** ឧបមានៅក្នុងស៊ីឡាំង C នៃរូប 2.1 (ក) មានប្រព័ន្ធឧស្ម័នដែលគេសន្មតជាឧស្ម័នបរិសុទ្ធមានមាឌ $100\text{cm}^3$ សម្ពាធ $2.00\times10^5\text{Pa}$ និងសីតុណ្ហភាព 300K ។ គេផ្តល់កម្តៅឱ្យប្រព័ន្ធឧស្ម័នឧស្ម័ននោះទទួលបំលែងទែម៉ូឌីណាមិច មានមាឌ $V_2$ សម្ពាធ $2.10\times10^5\text{Pa}$ និងសីតុណ្ហភាព 333K ។ គណនាមាឌ $V_2$ នោះ ។

✍ ដំណោះស្រាយ

មាឌ $V_2$ នៃឧស្ម័ន

តាមសមីការឧស្ម័នបរិសុទ្ធ

ភាពដើម $P_1V_1 = nRT_1$

ភាពស្រេច $P_2V_2 = nRT_2$

ធ្វើផលធៀប $\dfrac{P_1V_1}{P_2V_2} = \dfrac{T_1}{T_2}$ ឬ $\dfrac{P_1V_1}{T_1} = \dfrac{P_2V_2}{T_2}$

យើងទាញបាន $V_2 = \dfrac{P_1V_1}{P_2T_1}\times T_2$

ដោយ $P_1 = 2.00\times10^5\text{Pa}$ , $V_1 = 100\text{cm}^3$ , $T_1 = 300\text{K}$

$P_2 = 2.10\times10^5\text{Pa}$ , $T_2 = 333\text{K}$

យើងបាន $V_2 = \dfrac{(2.00\times10^5\text{P}_a)(100\text{cm}^3)(333\text{K})}{(2.10\times10^5\text{P}_a)(300\text{K})}$

ដូចនេះ $V_2 = 106\text{cm}^3$ ។

## 2. កម្មន្តបំពេញក្នុងពេលបម្រែបម្រួលមាឌ

### 2.1. ករណីសម្ពាធថេរ-លំនាំអ៊ីសូបា

គេសន្មតមានឧស្ម័នមួយបិតក្នុងស៊ីឡាំងបិទដោយពីស្តុង ។ កកិតរវាងពីស្តុងនិងស៊ីឡាំងតូចអាចចោលបាន ។

នៅភាពដើមឧស្ម័នមានមាឌ $V_1$ សម្ពាធ P និងពីស្តុងបិតត្រង់ទីតាំង $x_i$ ។




រូបទី 2.2 កម្មន្តក្នុងបម្លាស់ទីពីស្តុង

ឧស្ម័នរុញច្រានពីស្តុងដោយកម្លាំង $F = PA$ ដែលជាកម្លាំងធ្វើឱ្យពីស្តុងផ្លាស់ទីពីទីតាំង $x_i$ ទៅទីតាំង $x_f$ ។

ដូចនេះកម្មន្តបំពេញដោយឧស្ម័នគឺ : $W = F\Delta x$ , $\Delta x = x_f - x_i$





យើងបាន $W = F(x_f - x_i)$

ឬ $W = PA(x_f - x_i) = P(Ax_f - Ax_i)$

តែ $A\times x_f = V_2$ និង $Ax_i = V_1$

យើងបាន $W = P(V_2 - V_1)$ (1.23)

ឬ $\boxed{W = P\Delta V}$ (1.24)

ដែល P គិតជា Pa $\Delta V$ គិតជា $\text{m}^3$ W គិតជា J

***ឧទាហរណ៍ :*** នៅសម្ពាធថេរ $150\times10^3\text{Pa}$ ឧស្ម័នមួយរីកមាឌពី $75\times10^4\text{cm}^3$ ទៅ $90\times10^4\text{cm}^3$ ។ គណនាកម្មន្តដែលបំពេញដោយឧស្ម័ននោះ ។

✍ ដំណោះស្រាយ

កម្មន្តដែលបំពេញដោយឧស្ម័ន

តាមសមីការ (1.23) យើងបាន

$W = P(V_2 - V_1)$ តែ $V_1 = 75\times10^4\text{cm}^3 = 0.75\text{m}^3$

$V_2 = 90\times10^4\text{cm}^3 = 0.90\text{m}^3$

$P = 150\times10^3\text{Pa}$

យើងបាន $W = (150\times10^3\text{Pa})(0.90\text{m}^3 - 0.75\text{m}^3)$

ដូចនេះ $\boxed{W = 22.5\text{kJ}}$

**លំហាត់អនុវត្តន៍**

ជាមួយនិងសម្ពាធថេរ 200kPa ឧស្ម័នមួយប្រែប្រួលមាឌពី $0.75\text{m}^3$ ទៅ $1.9\text{m}^3$ ។ គណនាកម្មន្តបំពេញដោយឧស្ម័នក្នុងរយៈពេលរីកមាឌនេះ ។

### 2.2. ករណីសម្ពាធប្រែប្រួលស្មើ

កម្មន្តដែលបំពេញដោយឧស្ម័ន = សម្ពាធនៅភាពដើម × បម្រែបម្រួលមាឌ + ពាក់កណ្តាលបម្រែបម្រួលសម្ពាធ × បម្រែបម្រួលមាឌ

យើងបាន $W = P_1(V_2 - V_1) + \frac{1}{2}(P_2 - P_1)(V_2 - V_1)$ (1.25)

***ឧទាហរណ៍ :*** ឧស្ម័នមួយរីកមាឌពី $0.40\text{m}^3$ ទៅ $0.60\text{m}^3$ និងសម្ពាធកើនស្មើពី $100\times10^3\text{Pa}$ ទៅ $220\times10^3\text{Pa}$ ។ គណនាកម្មន្តដែលបំពេញដោយឧស្ម័ននោះ ។

✍ ដំណោះស្រាយ

កម្មន្តដែលបំពេញដោយឧស្ម័ន

តាមសមីការ (1.25) យើងបាន

$W = P_1(V_2 - V_1) + \frac{1}{2}(P_2 - P_1)(V_2 - V_1)$

ដោយ $P_1 = 100 \times 10^3 \text{Pa}$ $\quad P_2 = 220 \times 10^3 \text{Pa}$

$V_1 = 0.40 \text{m}^3$ $\quad V_2 = 0.60 \text{m}^3$

យើងបាន :

$$W = (100 \times 10^3 \text{Pa})(0.60\text{m}^3 - 0.40\text{m}^3) + \frac{1}{2}(220 \times 10^3 \text{Pa} - 100 \times 10^3 \text{Pa})(0.60\text{m}^3 - 0.40\text{m}^3)$$

ដូចនេះ : $\boxed{W = 3.20 \times 10^4 \text{J}}$ ។

**លំហាត់អនុវត្តន៍**

កាលណាសម្ពាធកើនស្មើពី $1.00 \times 10^5 \text{Pa}$ ទៅ $2.50 \times 10^5 \text{Pa}$ ឧស្ម័នមួយរីកមាឌពី $0.50\text{m}^3$ ទៅ $0.70\text{m}^3$ ។ គណនាកម្មន្តបំពេញដោយឧស្ម័ននោះ ។

## 3. ដ្យាក្រាមបង្ហាញពីភាពនៃថែម៉ូឌីណាមិច

យើងអាចគណនាកម្មន្តបំពេញក្នុងពេលបម្រែបម្រួលមាឌតាមការគូសដ្យាក្រាម P – V

### 3.1. ករណីសម្ពាធថេរ



រូបទី 2.3 ដ្យាក្រាម P-V

តាមដ្យាក្រាម P – V (រូប 2.3) បង្ហាញពីក្រាភិចដែលតាងសម្ពាធជាអនុគមន៍នៃមាឌ ។ ដោយសម្ពាធថេរ ដូចនេះក្រាបជាបន្ទាត់ ។ ដូចនេះផ្ទៃក្រឡាខាងក្រោមនៃខ្សែកោងគឺ :

ផ្ទៃក្រឡា : $P(V_2 - V_1) = P\Delta V$

តែ $W = P\Delta V$ ។ ដូចនេះដើម្បីរកកម្មន្តដែលបំពេញក្នុងពេលម្រែបម្រួលមាឌនិងក្នុងករណីសម្ពាធថេរ គេគណនាផ្ទៃក្រឡាចតុកោណកែងមួយដែលមានជ្រុងមួយ P និងជ្រុងមួយទៀត $V_2 - V_1$ ។





### 3.2. ករណីសម្ពាធកើនស្មើ



រូបទី 2.4 ដ្យាក្រាម P-V

ក្នុងករណីសម្ពាធកើនស្មើនិងមានប្រែប្រួល កម្មន្តបំពេញដោយឧស្ម័នស្មើនិងផ្ទៃក្រោមក្រាបដែលបានគូសឆ្នូតៗ ។ យើងអាចគណនាផ្ទៃនេះ គឺស្មើនិងផ្ទៃចតុកោណកែងដែលមានជ្រុង $(V_2 - V_1)$ និងជ្រុងមួយទៀត $P_1$ បូកនិងផ្ទៃត្រីកោណដែលមានបាត $(V_2 - V_1)$ និងកម្ពស់ $(P_2 - P_1)$ ។

***ឧទាហរណ៍*** : តាមដ្យាក្រាមខាងក្រោម ចូរគណនាកម្មន្តដែលធ្វើដោយឧស្ម័នមួយ ។

✍ ដំណោះស្រាយ



រូបទី 2.5 ដ្យាក្រាម P-V

ផ្ទៃចតុកោណកែង

$A_1 = P_1(V_2 - V_1)$

$A_1 = (100 \times 10^3 \text{Pa})(0.60\text{m}^3 - 0.40\text{m}^3)$

$A_1 = 20 \times 10^3 \text{J}$

ផ្ទៃក្រឡាត្រីកោណ

$A_2 = \frac{1}{2}(P_2 - P_1)(V_2 - V_1)$

$A_2 = \frac{1}{2}(220 \times 10^3 \text{Pa} - 100 \times 10^3 \text{Pa})(0.60\text{m}^3 - 0.40\text{m}^3)$

$A_2 = 12 \times 10^3 \text{J}$

សរុបផ្ទៃក្រោមក្រាប ដើម្បីគណនាកម្មន្តធ្វើដោយឧស្ម័ននោះ

$\Delta W = (A_1 + A_2) \Rightarrow \Delta W = (20 \times 10^3 \text{J} + 12 \times 10^3 \text{J})$

ដូចនេះ $\boxed{W = 32 \times 10^3 \text{J}}$

★ **កំណត់សម្គាល់**

ក្នុងករណីសម្ពាធកើនស្មើ យើងអាចគណនាតម្លៃមធ្យមនៃសម្ពាធ $P_{av} = \frac{P_1 + P_2}{2}$ ។ បន្ទាប់មកយើងអាចគណនាកម្មន្តបំពេញដោយឧស្ម័ននោះគឺ :

$$W = P_{av}\Delta V = \frac{100 \times 10^3 \text{Pa} + 220 \times 10^3 \text{Pa}}{2}(0.60\text{m}^3 - 0.40\text{m}^3) = 32 \times 10^3 \text{J}$$

### 3.3. ករណីសីតុណ្ហភាពថេរ-លំនាំអ៊ីសូទែម

ដូចខាងលើដែរ កាលណាសីតុណ្ហភាពថេរមានប្រែប្រួលពី $V_1$ ទៅ $V_2$ កម្មន្តបំពេញដោយឧស្ម័នស្មើនឹងផ្ទៃក្រោមក្រាប(ផ្ទៃដែលគូសឆ្នូតៗ) ។

តាមសមីការ (1.6) នៃមេរៀនមុនយើងមាន :

$PV = kNT$ ដោយ T ជាចំនួនថេរ

យើងបាន $PV = kNT = \text{ថេរ}$

ឬ $P = \frac{kNT}{V} = \frac{\text{ថេរ}}{V}$




*រូបទី 2.6 ដ្យាក្រាម P-V ករណីសីតុណ្ហភាពថេរ*

តាមដ្យាក្រាម P – V រូប (2.6) បង្ហាញឱ្យឃើញថាកម្មន្តបំពេញក្នុងបម្រែបម្រួលមានឧស្ម័នស្មើនិងផ្ទៃក្រោមខ្សែកោង ។

ជាពិសេសកម្មន្តដែលធ្វើក្នុងបម្រែបម្រួលមានពី $V_1$ ទៅ $V_2$ គឺស្មើនិងផ្ទៃដែលគូសឆ្នូតៗ (រូប 2.6) ។ យើងរកផ្ទៃនេះដោយទាញយកពីវិធីគណនា ។ លទ្ធផលដែលបានរកឃើញ :

$$W = NkT\ \ell n\left(\frac{V_2}{V_1}\right) = nRT\ \ell n\left(\frac{V_2}{V_1}\right) \quad (1.26)$$

N ចំនួនម៉ូលេគុល $k = 1.38 \times 10^{-23} J/K$ T គិតជា K

n ចំនួនម៉ូល គិតជា mol $R = 8.31 J/(molK)$ $V_1$ និង $V_2$ គិតជា $m^3$

***ឧទាហរណ៍*** : ឧស្ម័នបរិសុទ្ធ 1.0mol មានសីតុណ្ហភាពថេរ 0.0°C ក្នុងរយៈពេលបម្រែបម្រួលមាន $3.0\ell$ ទៅ $10.0\ell$ ។ គណនាកម្មន្តដែលបំពេញដោយឧស្ម័ននោះ ក្នុងរយៈពេលបម្រែបម្រួលមាននោះ ។

✍ ដំណោះស្រាយ

កម្មន្តបំពេញដោយឧស្ម័នក្នុងរយៈពេលបម្រែបម្រួលមាន

តាមសមីការ (1.26)

យើងបាន $W = nRT\ \ell n\left(\frac{V_2}{V_1}\right)$

$n = 1.0mol$ $R = 8.31J/(molK)$ $T = 273K$ $V_1 = 3.0\ell$ $V_2 = 10.0\ell$

$W = (1.0mol) \times (8.31 \times J/molK) \times (273K)\ell n\left(\frac{10.0\ell}{3.0\ell}\right)$

ដូចនេះ $\boxed{W = 27.2 \times 10^2 J}$ ។





**លំហាត់អនុវត្តន៍**

ឧស្ម័នបរិសុទ្ធមួយមានសីតុណ្ហភាពថេរ $T = 300K$ ក្នុងរយៈពេលបម្រែបម្រួលមានពី $V_1 = 0.31m^3$ ទៅ $V_2 = 0.45m^3$ ។ គេដឹងថាឧស្ម័នមាន $n = 0.50mol$ ។ គណនាកម្មន្តបំពេញដោយឧស្ម័នក្នុងពេលបម្រែបម្រួលមាននោះ ។

## 4. ថាមពលក្នុងនៃច្បាប់ទី១ នៃទែម៉ូឌីណាមិច

### 4.1. កម្ដៅនិងកម្មន្ត

យើងពិនិត្យទំហំកម្ដៅនិងកម្មន្តក្នុងឧទាហរណ៍ខាងក្រោម

- មនុស្សម្នាក់ជិះកង់ចុះចំណោតនៃឫងទេរមួយដោយគ្មានកកិត ។ គាត់មិនធាក់ឈ្នាន់ទេ គាត់ចាប់ប្រាំងទប់ដើម្បីឱ្យចលនារបស់គាត់មានល្បឿនថេរ ។ ក្នុងដំណើរចុះចំណោត ទម្ងន់របស់ប្រព័ន្ធ " **មនុស្ស-កង់** " បង្កើតកម្មន្តចលករ ។ កម្មន្តនេះបានក្លាយជាកម្ដៅ ព្រោះប្រាំងនិងខ្នងកង់ឡើងក្ដៅជាងមុន ។
- ក្នុងម៉ាស៊ីនរថយន្តមួយ ចំហេះល្បាយ " សាំង-ខ្យល់ " ក្នុងស៊ីឡាំងនាំឱ្យបានកម្ដៅ ។ កម្ដៅនេះបង្កើតសីតុណ្ហភាពនិងសម្ពាធល្បាយឧស្ម័ន ជាហេតុនាំឱ្យបង្កើតបានកម្មន្ត គឺធាក់ច្រានពីស្ដុងដើម្បីបង្វិលកង់រថយន្តឱ្យទៅមុខ ។

ដូចនេះកម្ដៅក៏ដូចកម្មន្តដែរជាទំហំដែលបំលែងជាថាមពលប៉ុន្តែគេអាចញែកទំហំទាំងពីរបាន ។ ក្នុងមេកានិចយើងកំណត់កម្មន្តជាទំហំស្កាលែ ដែលស្មើនិងផលគុណស្កាលែរវាងកម្លាំងនិងបម្លាស់ទី ។ សីតុណ្ហភាពមានទំនាក់ទំនងនឹងកម្ដៅ ម្យ៉ាងទៀតថាមពលអាចផ្ទេរពីអង្គធាតុមួយទៅអង្គធាតុមួយទៀតកាលណាអង្គធាតុទាំងពីរមានសីតុណ្ហភាពខុសគ្នា ។

- សីតុណ្ហភាពខុសគ្នាជាលក្ខខណ្ឌចាំបាច់សម្រាប់ផ្ទេរកម្ដៅ ។
- បម្លាស់ទីជាលក្ខខណ្ឌចាំបាច់សម្រាប់បង្កើតកម្មន្ត ។

### 4.2. ច្បាប់ទី១ទែម៉ូឌីណាមិច

បញ្ញត្តិ " **ថាមពលក្នុងនៃលំនាំទែម៉ូឌីណាមិច** " អាចមានទស្សនៈផ្សេងៗគ្នា ជួនកាលងាយ ជួនកាលស្មុគ្រស្មាញ ។ យើងចាប់ផ្ដើមពីទស្សនៈងាយ : យើងដឹងថារូបធាតុផ្សំឡើងពីម៉ូលេគុល ឬអាតូម ហើយអាតូម ឬម៉ូលេគុលផ្សំឡើងពីផង់ដែលមានថាមពលស៊ីនេទិច និងថាមពលប៉ូតង់ស្យែល ។

យើងកំណត់និយមន័យថាមពលក្នុងនៃប្រព័ន្ធ គឺថាមពលសរុបនៃថាមពលស៊ីនេទិចនិងថាមពលប៉ូតង់ស្យែលរបស់ផង់ទាំងអស់ដែលបង្កើតបានជាប្រព័ន្ធ ។

យើងតាងថាមពលក្នុងនៃប្រព័ន្ធដោយ U ។ ក្នុងរយៈពេលបម្រែបម្រួលភាពនៃប្រព័ន្ធថាមពលក្នុងប្រែប្រួលពីភាពដើម $U_1$ ទៅភាពស្រេច $U_2$ ។ បម្រែបម្រួលថាមពលក្នុងនៃប្រព័ន្ធគឺ

$\Delta U = U_2 - U_1$ ។

យើងបានដឹងរួចមកហើយកម្ដៅ គឺជាថាមពល ។ កាលណាគេបន្ថែមបរិមាណកម្ដៅ Q ទៅឱ្យប្រព័ន្ធ នោះថាមពលក្នុងនៃប្រព័ន្ធប្រែប្រួល $\Delta U$ ។

ដូចនេះ $\Delta U = Q$

កាលណាប្រព័ន្ធធ្វើកម្មន្តក្នុងការពង្រីកមាឌប្រឆាំងនឹងមជ្ឈដ្ឋានក្រៅ ថាមពលក្នុងនៃប្រព័ន្ធថយ ។បើ W វិជ្ជមាន យើងបាន $\Delta U$ អវិជ្ជមាន ។

ដូចនេះ $\Delta U = -W$

កាលណាមានករណីទាំងពីរកើតឡើងព្រមគ្នា : កម្ដៅបានផ្ទេរនិងកម្មន្តកើតឡើង នោះបម្រែបម្រួលថាមពលក្នុងសរុបគឺ :

$$\Delta U = Q - W \qquad (1.27)$$

ឬ $$Q = \Delta U + W \qquad (1.28)$$

សមីការ (1.27) និង (1.28) ជាច្បាប់ទី I ទែម៉ូឌីណាមិច ។

ច្បាប់ទី I ទែម៉ូឌីណាមិច ជាអំណះអំណាងរបស់ច្បាប់រក្សាថាមពល ។

ថាមពលមិនមែនកើតឡើងដោយឯកឯង ហើយក៏មិនបាត់ទៅវិញសូន្យនោះទេ គឺវាប្លែងពីថាមពលមួយទៅថាមពលមួយបែបទៀត ។

ច្បាប់ទី១ ទែម៉ូឌីណាមិច : ក្នុងលំនាំទែម៉ូឌីណាមិច កម្ដៅស្រូបដោយប្រព័ន្ធស្មើនឹងផលបូកនៃកម្មន្តដែលបង្កើតឡើងដោយប្រព័ន្ធ និងបម្រែបម្រួលថាមពលក្នុងនៃប្រព័ន្ធ ។

ដើម្បីអនុវត្តច្បាប់ទី១ ទែម៉ូឌីណាមិច យើងត្រូវដឹងពីសញ្ញារបស់ទំហំទាំងបីខាងលើ ។

- បើកម្ដៅផ្ដល់ឱ្យប្រព័ន្ធ ⇒ Q វិជ្ជមាន តែបើកម្ដៅបញ្ចេញដោយប្រព័ន្ធ ⇒ Q អវិជ្ជមាន
- បើកម្មន្តបំពេញដោយប្រព័ន្ធ ⇒ W វិជ្ជមាន បើកម្មន្តបំពេញទៅលើប្រព័ន្ធ ⇒ W អវិជ្ជមាន
- បើថាមពលក្នុងកើន ⇒ $\Delta U$ វិជ្ជមាន បើថាមពលក្នុងថយ ⇒ $\Delta U$ អវិជ្ជមាន

***ឧទាហរណ៍*** : ឧស្ម័នមួយស្រូបកម្ដៅ 800J និងបំពេញកម្មន្ត 200J ក្នុងពេលលំនាំនេះវាបានបញ្ចេញកម្ដៅទៅវិញ 300J ។ ចូរគណនាបម្រែបម្រួលថាមពលក្នុងរបស់ឧស្ម័ននោះ ។





✍ ដំណោះស្រាយ

បម្រែបម្រួលថាមពលក្នុងនៃឧស្ម័ន

តាមរូបមន្ត : $\Delta U = Q - W$

តែ $Q = 800J - 300J = 500J$

ហើយ $W = 200J$

យើងបាន $\Delta U = 500J - 200J$

ដូចនេះ $\Delta U = 300J$

តាមចម្លើយនេះបង្ហាញឱ្យឃើញថា ថាមពលក្នុងរបស់ឧស្ម័នកើន ។

**លំហាត់អនុវត្តន៍**

ម៉ាស៊ីនកម្ដៅមួយបានបំពេញកម្មន្ត 250J ក្នុងរយៈពេលដែលថាមពលក្នុងរបស់ម៉ាស៊ីនថយចុះ 500J ។ ក្នុងលំនាំនេះ កម្ដៅរបស់ម៉ាស៊ីនមានតម្លៃប៉ុន្មាន ?

យើងកំណត់ន័យនៃបម្រែបម្រួលថាមពលក្នុងនៃប្រព័ន្ធតាមសមីការ (1.26) ឬ (1.27) ។ យើងមិនអាចវាស់ $\Delta U$ ដោយផ្ទាល់បានទេ តែគេអាចកំណត់តម្លៃ $\Delta U$ តាមការវាស់កម្មន្ត W និងបរិមាណកម្ដៅ Q ។

ឧបមាប្រព័ន្ធមួយចេញពីភាពដើមទៅភាពស្រេចតាមបំលែងពីរផ្សេងគ្នា តើបម្រែបម្រួលថាមពលក្នុងនៃប្រព័ន្ធអាស្រ័យនឹងរាងនៃបំលែងដែរឬទេ ?

ក្នុងពិសោធន៍គេវាស់ $Q_1$ និង $W_1$ កាលណាប្រព័ន្ធប្ដូរភាពពីភាពដើមទៅភាពស្រេច តាមបំលែងផ្សេងៗ បន្ទាប់មកគេសិក្សាបម្រែបម្រួលថាមពលក្នុងនៃប្រព័ន្ធតាមបំលែងនីមួយៗនោះ ។



*រូបទី 2.7 បំលែងភាពតាមរាងផ្សេងៗ*

តាមលទ្ធផលពិសោធន៍បង្ហាញឱ្យឃើញថា បម្រែបម្រួលថាមពលក្នុងនៃប្រព័ន្ធតាមបំលែង I បំលែង II និងបំលែង III មានតម្លៃស្មើគ្នា ។ ហេតុនេះគេទាញបានគោលការណ៍មួយហៅថា **គោលការណ៍ភាពដើម និងភាពស្រេច** ។

គោលការណ៍ភាពដើមនិងភាពស្រេចបានថែងដូចតទៅ :

កាលណាប្រព័ន្ធមួយចេញពីភាពដើមទៅភាពស្រេច ដោយប្តូរតែកម្មន្ត $W$ និងកម្តៅ $Q$ ជាមួយមជ្ឈដ្ឋានក្រៅ ផលបូកពីជគណិត $Q-W$ អាស្រ័យតែនឹងភាពដើមនិងភាពស្រេច វាមិនអាស្រ័យនឹងរាងនៃបំលែងទេ ។

យើងបាន $$\boxed{\Delta U = Q_1 - W_1 = Q_2 - W_2 = Q_3 - W_3} \quad (1.29)$$

**សម្គាល់**

ជាទូទៅ ថាមពលក្នុងរបស់ឧស្ម័នបរិសុទ្ធឱ្យដោយរូបមន្ត $U = \frac{3}{2}nRT$ ។

ថាមពលក្នុងនៃឧស្ម័នបរិសុទ្ធមួយ គឺជាថាមពលស៊ីនេទិចនៃម៉ូលេគុលរបស់ឧស្ម័ននោះទាំងអស់ ។ តាមសមីការ (1.21) ថាមពលក្នុងមួយម៉ូលនៃឧស្ម័នបរិសុទ្ធម៉ូណូអាតូមគឺ

$$\boxed{U = \frac{3}{2}RT} \quad (1.30)$$

កាលណាសីតុណ្ហភាពនៃប្រព័ន្ធកើន ថាមពលក្នុងនៃប្រព័ន្ធក៏កើនដែរ

ដូចនេះបម្រែបម្រួលថាមពលក្នុង ក្នុងមួយម៉ូលនៃឧស្ម័នបរិសុទ្ធម៉ូណូអាតូមសរសេរ

$$\boxed{\Delta U = \frac{3}{2}R\Delta T} \quad (1.31)$$

## 5. ករណីបំលែងបិទ-គោលការណ៍សមមូល

ឧបមានៅភាព 1 ថាមពលក្នុងនៃប្រព័ន្ធ គឺ $U_1$ និងនៅភាព 2 ថាមពលក្នុងនៃប្រព័ន្ធ គឺ $U_2$ (គេមិនដឹងតម្លៃ $U_1$ និង $U_2$ ទេ)

ប្រព័ន្ធទែម៉ូឌីណាមិចមួយចេញពីភាព 1 ទៅភាព 2 តាមបំលែង I បន្ទាប់មកប្រព័ន្ធនេះចេញពីភាព 2 ទៅភាព 1 តាមបំលែង II ។




*រូបទី 2.8 បំលែងបិទ*

- បម្រែបម្រួលថាមពលក្នុងនៃប្រព័ន្ធ ក្នុងបំលែង I សរសេរ :
  $\Delta U_I = U_2 - U_1 = Q_1 - W_1$
- បម្រែបម្រួលថាមពលក្នុងនៃប្រព័ន្ធ ក្នុងបំលែង II សរសេរ :
  $\Delta U_{II} = U_1 - U_2 = Q_2 - W_2$
- សរុបបំលែង I + II
  យើងបាន $\Delta U_I + \Delta U_{II} = (U_2 - U_1) + (U_1 - U_2) = 0$





យើងបាន $(Q_1 - W_1) + (Q_2 - W_2) = 0$ ឬ $(Q_1 + Q_2) - (W_1 + W_2) = 0$

តាង $Q = Q_1 + Q_2$ និង $W = W_1 + W_2$

ដូចនេះ $$\boxed{\Delta U = Q - W = 0} \quad (1.32)$$

ពំនោលគោលការណ៍សមមូល កាលណាប្រព័ន្ធមួយទទួលបំលែងបិទ(ធ្វើស៊ិចមួយ) ដោយប្តូរតែកម្មន្តនិងកម្តៅជាមួយមជ្ឈដ្ឋានក្រៅ :

- បើវាធ្វើ (ឬបំពេញ) កម្មន្ត ($W > 0$) វាផ្តល់កម្តៅ $Q < 0$
- បើវាទទួលនូវកម្មន្ត ($W < 0$) វាស្រូបកម្តៅ $Q > 0$
- បរិមាណកម្តៅនិងកម្មន្តដែលប្រព័ន្ធបានប្តូរជាមួយមជ្ឈដ្ឋានក្រៅមានតម្លៃដាច់ខាតស្មើគ្នា ។

## 6. លំនាំអ៊ីសូករ

លំនាំអ៊ីសូករ គឺជាលំនាំមួយដែលមាឌនៃប្រព័ន្ធក្នុងបំលែងទែម៉ូឌីណាមិចមានតម្លៃថេរ ។

អនុវត្តច្បាប់ទី 1 នៃទែម៉ូឌីណាមិចក្នុងលំនាំនេះយើងបាន : $\Delta W = 0$ ដូចនេះ $\Delta Q = \Delta U$

***ឧទាហរណ៍*** : ដ្យាក្រាម $P \cdot V$ តាងស៊ិចមួយនៃម៉ូលេគុល ឧស្ម័នបរិសុទ្ធមួយម៉ូល :

ក្នុងបំលែងពី $A \rightarrow B$ សម្ពាធថេរ

ក្នុងបំលែងពី $B \rightarrow C$ មាឌថេរ

ក្នុងបំលែងពី $C \rightarrow A$ សម្ពាធប្រែប្រួលស្មើ

ចូរគណនា :

ក. កម្មន្ត $W_{AB}$ ក្នុងបំលែង $A \rightarrow B$

ខ. កម្មន្ត $W_{BC}$ ក្នុងបំលែង $B \rightarrow C$

គ. កម្មន្ត $W_{CA}$ ក្នុងបំលែង $C \rightarrow A$

ឃ. កម្មន្តសរុបក្នុងបំលែងបិទ

ង. កម្តៅសរុបក្នុងបំលែងបិទ




*រូបទី 2.9 បំលែងបិទ*

✍ ដំណោះស្រាយ

ក. កម្មន្ត $W_{AB}$ ក្នុងបំលែង $A \rightarrow B$

ដោយសម្ពាធថេរ $W_{AB} = P_A \Delta V$ យើងបាន $W_{AB} = 10^5 Pa(0.0125m^3 - 0.02m^3)$

ដូចនេះ $W_{AB} = -7.5 \times 10^2 J$

ខ. កម្មន្ត $W_{BC}$ ដោយ $\Delta V = 0 \Rightarrow W_{BC} = 0$

គ. កម្មន្តធ្វើពី $C \rightarrow A$

$$W_{CA} = P_C(V_A - V_C) + \frac{1}{2}(P_A - P_C)(V_A - V_C) \text{ ឬ } W_{CA} = \left(\frac{P_A + P_C}{2}\right)(V_A - V_C)$$

$$W_{CA} = 10^5\text{Pa}(0.02\text{m}^3 - 0.0125\text{m}^3) + \frac{1}{2}(10^5\text{Pa} - 2 \times 10^5\text{Pa})(0.02\text{m}^3 - 0.0125\text{m}^3)$$

$$W_{CA} = -375\text{J}$$

ឃ. កម្មន្តសរុបធ្វើក្នុងបំលែងបិទ

$W = W_{AB} + W_{BC} + W_{CA}$ នោះ $W = 750\text{J} + 0 + (+375\text{J})$ ដូចនេះ $\boxed{W = 1125\text{J}}$

ង. កម្តៅសរុបក្នុងបំលែងបិទនេះ

តាមគោលការណ៍សមមូល យើងបាន $Q - W = 0$ នោះ $Q = W = 1125\text{J}$

ដូចនេះ $\boxed{Q = 1125\text{J}}$

**សម្គាល់** : តាមន័យទែម៉ូឌីណាមិចប្រព័ន្ធមួយជាប្រព័ន្ធត្រមោច កាលណាវាមិនអាចប្តូរកម្មន្តនិងកម្តៅជាមួយមជ្ឈដ្ឋានក្រៅ ។ ហេតុនេះយើងបាន $W = Q = 0$

ដូចនេះ $\Delta U = 0$ យើងបាន $U_1 = U_2$ ដូច្នេះថាមពលក្នុងនៃប្រព័ន្ធត្រមោចមិនប្រែប្រួលទេ ។

**មេរៀនសង្ខេប**

- ប្រព័ន្ធគឺជាវត្ថុ ឬសំណុំវត្ថុដែលលើកយកមកសិក្សា បើធៀបនឹងវត្ថុដទៃ ។
- កាលណាប្រព័ន្ធមួយផ្លាស់ប្តូរភាពដោយប្តូរតែកម្មន្តនិងកម្តៅជាមួយមជ្ឈដ្ឋានក្រៅ គេថាប្រព័ន្ធនោះទទួលបំលែងទែម៉ូឌីណាមិច ។
- ករណីសម្ពាធថេរ កម្មន្តដែលធ្វើឱ្យមានបម្រែបម្រួលមាឌឧស្ម័នមានរូបមន្ត $W = P\Delta V$ ។
- ករណីសម្ពាធប្រែប្រួលស្មើ កម្មន្តដែលធ្វើឱ្យមានបម្រែបម្រួលមាឌឧស្ម័នមានរូបមន្ត : $W = P_1\Delta V + \frac{1}{2}(P_2 - P_1)\Delta V$ ។
- កម្មន្តក្នុងករណីអ៊ីសូទែម : $W = nRT\ell n\left(\frac{V_2}{V_1}\right)$ ។
- ច្បាប់ទី 1 ទែម៉ូឌីណាមិច : ក្នុងបំលែងទែម៉ូឌីណាមិច កម្តៅស្រូបដោយប្រព័ន្ធស្មើនឹងផលបូកកម្មន្តដែលបង្កើតឡើងដោយប្រព័ន្ធនិងបម្រែបម្រួលថាមពលក្នុងនៃប្រព័ន្ធ $Q = \Delta U + W$
- ថាមពលក្នុងនៃឧស្ម័នបរិសុទ្ធ គឺជាថាមពលស៊ីនេទិចសរុបរបស់ម៉ូលេគុលនៃឧស្ម័ននោះ ។
- ថាមពលក្នុងមួយម៉ូលនៃឧស្ម័នបរិសុទ្ធម៉ូណូអាតូម $U = \frac{3}{2}RT$
- បម្រែបម្រួលថាមពលក្នុង ក្នុងមួយម៉ូលនៃឧស្ម័នបរិសុទ្ធម៉ូណូអាតូម $\Delta U = \frac{3}{2}R\Delta T$ ។





## ? សំណួរនិងលំហាត់

1. ដូចម្តេចដែលហៅថាប្រព័ន្ធទែម៉ូឌីណាមិច ?
2. ដូចម្តេចដែលហៅថាបំលែងទែម៉ូឌីណាមិច ?
3. ចូរពោលគោលការណ៍ភាពដើម និងភាពស្រេច ។
4. ចូរពោលគោលការណ៍សមមូល ។
5. គេសន្មតថា ឧស្ម័នមួយនៅក្នុងស៊ីឡាំងដែលបិទដោយពីស្តុងអាចរីកមាឌក្រោមសម្ពាធថេរ $200\text{kPa}$ ពី $2\text{dm}^3$ ទៅ $5\text{dm}^3$ ។ តើកម្មន្តធ្វើដោយឧស្ម័ននោះមានតម្លៃប៉ុន្មាន ?

   **ចម្លើយ** : $W = 600\text{J}$
6. ក្នុងលំនាំនៃឧស្សាហកម្មគីមីមួយ បានផ្តល់កម្តៅ $600\text{J}$ ទៅឱ្យប្រព័ន្ធ និងប្រព័ន្ធបានបំពេញកម្មន្ត $200\text{J}$ ។ តើថាមពលក្នុងនៃប្រព័ន្ធកើនបានប៉ុន្មាន ? **ចម្លើយ** : $\Delta U = 400\text{J}$
7. ក. ពិសីរត់ត្រឹកៗតាមបណ្តោយឆ្នេរសមុទ្រ ។ ក្នុងមួយថ្ងៃនាងបានបំពេញកម្មន្ត $4.3 \times 10^5\text{J}$ និងបញ្ចេញកម្តៅបាន $3.8 \times 10^5\text{J}$ ។ គណនាបម្រែបម្រួលថាមពលក្នុងរបស់នាង ។

   ខ. នាងបានប្តូរពីរត់មកដើរវិញនិងបានបញ្ចេញកម្តៅ $1.2 \times 10^5\text{J}$ និងថាមពលក្នុងរបស់នាងថយចុះ $2.6 \times 10^5\text{J}$ ។ ក្នុងករណីនេះ តើនាងធ្វើកម្មន្តបានប៉ុន្មានស៊ូល ?

   **ចម្លើយ** : ក. $\Delta U = -8.1 \times 10^5\text{J}$ ខ. $W = 1.4 \times 10^5\text{J}$
8. ក្នុងស៊ីឡាំងមួយមានឧស្ម័នបរិសុទ្ធម៉ូណូអាតូម $0.5\text{mol}$ នៅសីតុណ្ហភាព $310\text{K}$ ។ ដោយរក្សាសីតុណ្ហភាពឱ្យនៅដដែល ឧស្ម័ននេះបានរីកមាឌពី $310\text{dm}^3$ ទៅ $450\text{dm}^3$ ។

   គេឱ្យ $R = 8.31\text{J/molK}$

   ក. គណនាកម្មន្តដែលបានធ្វើក្នុងរយៈពេលបម្រែបម្រួលមាឌនេះ ។

   ខ. គណនាបម្រែបម្រួលថាមពលក្នុងនៃឧស្ម័ន ។

   គ. គណនាកម្តៅដែលស្រូបដោយប្រព័ន្ធក្នុងរយៈពេលនៃបម្រែបម្រួលមាឌនេះ ។

   **ចម្លើយ** : ក. $W = 480\text{J}$ ខ. $\Delta U = \frac{3}{2}R(T_2 - T_1) = 0$ គ. $Q = 480\text{J}$

# មេរៀនទី៣ ច្បាប់ទី១នៃម៉ូឌីណាមិច







គ្រុម សុណា 2024

## សេចក្តីផ្តើម ៖ រថភ្លើងដើរដោយចំហាយទឹក



រថភ្លើងដើរដោយចំហាយទឹក គឺប្រើប្រាស់ច្បាប់ទី១ទែម៉ូឌីណាមិច៖ គេដុតកម្តៅទឹករហូតដល់វាពុះក្លាយជាចំហាយទឹក។ ចំហាយទឹកដែលរីកមាឌនេះធ្វើកម្មន្តដើម្បីរុញច្រានរថភ្លើងនេះ។ តើវាអាចទៅរួចដែរឬទេដែលចំហាយទឹកអាចរុញច្រានរថភ្លើងដោយធ្វើកម្មន្តនៅពេលវាបណ្តែន?

ក. អាច

ខ. មិនអាច

គ. ចម្លើយអាស្រ័យទៅលើភាពលម្អិតនៃការបណ្តែនចំហាយទឹក។

# ១. ប្រព័ន្ធទែម៉ូឌីណាមិច

ប្រព័ន្ធទែម៉ូឌីណាមិច ជាវត្ថុ ឬ សំណុំនៃវត្ថុណាមួយដែលគេងាយសន្មត់ថាជាឯកតា(វត្ថុមួយ)ដែលមានទំនោរផ្លាស់ប្តូរថាមពលជាមួយមជ្ឈដ្ឋានជុំវិញវា។

ភាពនៃប្រព័ន្ធ នៅខណៈមួយជាសំណុំលេខដែលវាស់ទំហំរូបវិទ្យាទាំងឡាយសម្រាប់សម្គាល់ប្រព័ន្ធនៅខណៈនោះ។

លំនាំទែម៉ូឌីណាមិច ជាលំនាំដែលមានបម្លាស់ប្តូរភាពនៃប្រព័ន្ធទែម៉ូឌីណាមិច។




(ក) (ខ)
រូបទី 2.1 (ក)ឧស្ម័នG (ខ)ល្បាយទឹកកកទឹក

ឧទាហរណ៍

ប្រព័ន្ធ៖ ឧស្ម័ន C។ ល្បាយទឹកកក-ទឹក។

ភាពនៃប្រព័ន្ធ៖ មាឌ សីតុណ្ហភាព និងសំពាធ (អថេរសម្គាល់ភាព)។

មាឌ សីតុណ្ហភាព និងសំពាធ ផ្លាស់ប្តូរ → លំនាំទែម៉ូឌីណាមិច

# ១. ប្រព័ន្ធទែម៉ូឌីណាមិច



ឧទាហរណ៍៖ ពោតផ្ទុះ popcorn

ប្រព័ន្ធ៖ ពោត។ ទទួលកម្តៅតាមរយៈការចម្លងពីឆ្នាំង។ ធ្វើកម្មន្តលើគម្រប។

ភាពនៃប្រព័ន្ធ៖ មាឌ សីតុណ្ហភាព និងសំពាធ។

មាឌ សីតុណ្ហភាព និងសំពាធ ផ្លាស់ប្តូរ → លំនាំទែម៉ូឌីណាមិច

# ១. ប្រព័ន្ធទែម៉ូឌីណាមិច

## សញ្ញារបស់កម្តៅ និង កម្មន្តក្នុងទែម៉ូឌីណាមិច

ក្នុងមេកានិច៖ កម្មន្តបំពេញដោយកម្លាំង $\vec{F}$ ទៅលើវត្ថុណាមួយ

ក្នុងទែម៉ូឌីណាមិច៖

កម្មន្ត *ធ្វើដោយ* ប្រព័ន្ធ *ទៅលើ* មជ្ឈដ្ឋានជុំវិញ $W > 0$

កម្មន្ត *ទៅលើ* ប្រព័ន្ធ *ធ្វើដោយ* មជ្ឈដ្ឋានជុំវិញ $W < 0$




កម្តៅ៖



កម្តៅហូរ *ចូល* ប្រព័ន្ធ $Q > 0$

កម្តៅហូរ *ចេញពី* ប្រព័ន្ធ $Q < 0$

# ២. កម្មន្តបំពេញក្នុងពេលមានបម្រែបម្រួលមាឌ




ម៉ូលេគុលថយចុះថាមពលស៊ីនេទិច។
វាធ្វើកម្មន្តវិជ្ជមានលើពិស្តុង។




ម៉ូលេគុលកើនថាមពលស៊ីនេទិច។
វាធ្វើកម្មន្តអវិជ្ជមានលើពិស្តុង។




$$dW = F dx = pA\, dx = p\, dV$$

$$W = \int_{V_{\text{ដើម}}}^{V_{\text{ស្រេច}}} p\, dV$$

បើ $V$ ថេរ ( លំនាំអ៊ីសូករ ) នោះ៖ $dV = 0 \rightarrow W = 0$ J។

បើ $p$ ថេរ ( លំនាំអ៊ីសូបារ ) នោះ៖ $W = p\Delta V = p\left(V_{\text{ស្រេច}} - V_{\text{ដើម}}\right)$

# ២. កម្មន្តបំពេញក្នុងពេលមានបម្រែបម្រួលមាឌ

$$W = \int_{V_{\text{ដើម}}}^{V_{\text{ស្រេច}}} p\, dV$$

បើ $T$ ថេរ( លំនាំអ៊ីសូទែម) នោះ $\quad pV = nRT$

$$W = \int_{V_{\text{ដើម}}}^{V_{\text{ស្រេច}}} \frac{nRT}{V}\, dV = \int_{V_{\text{ដើម}}}^{V_{\text{ស្រេច}}} nRT \frac{dV}{V} = nRT[\ln V]_{\text{ដើម}}^{\text{ស្រេច}} = nRT\left[\ln V_{\text{ស្រេច}} - \ln V_{\text{ដើម}}\right] = nRT\frac{\ln V_{\text{ស្រេច}}}{\ln V_{\text{ដើម}}}$$

សម្រាប់តែឧស្ម័នបរិសុទ្ធ

# ២. កម្មន្តបំពេញក្នុងពេលមានបម្រែបម្រួលមាឌ

ស្វែងយល់អំពីកម្មន្ត( $W = \int_{V_{\text{ដើម}}}^{V_{\text{ស្រេច}}} p\, dV$ )តាមរយៈដ្យាក្រាម




$p$ ថេរ( លំនាំអ៊ីសូបារ) រីកមាឌ

$T$ ថេរ( លំនាំអ៊ីសូទែម) រីកមាឌ

$T$ ថេរ( លំនាំអ៊ីសូទែម) រួមមាឌ

# ៣. គន្លងរវាងភាពទែម៉ូឌីណាមិច

## កម្មន្តបំពេញក្នុងលំនាំទែម៉ូឌីណាមិច

- គន្លង ( path ) គឺជាសំណុំនៃភាពទែម៉ូឌីណាមិច។
- កម្មន្តធ្វើឬបំពេញដោយប្រព័ន្ធមិនអាស្រ័យតែលើភាពដើម និងស្រេចទេ ប៉ុន្តែវាក៏អាស្រ័យនឹងភាពដែលនៅចន្លោះភាពដើម និងភាពស្រេចដែរ ( គន្លង )។




# ៣. គន្លងរវាងភាពទែម៉ូឌីណាមិច

## កម្តៅផ្តល់អោយប្រព័ន្ធក្នុងលំនាំទែម៉ូឌីណាមិច

កម្តៅ មិនអាស្រ័យតែនឹងភាពដើម និងភាពស្រេចនៃលំនាំទេ តែវាក៏អាស្រ័យនឹងគន្លងនៃលំនាំដែរ។

(a) System does work on piston; hot plate adds heat to system ($W > 0$ and $Q > 0$).




នៅសីតុណ្ហភាពថេរ

- ឧស្ម័នស្រូបកម្តៅពីបន្ទះកម្តៅ
- ឧស្ម័នធ្វើកម្មន្តលើពិស្តុង

(b) System does no work; no heat enters or leaves system ($W = 0$ and $Q = 0$).




នៅសីតុណ្ហភាពថេរ

- ឧស្ម័នមិនស្រូបកម្តៅពីមជ្ឈដ្ឋានក្រៅ
- ឧស្ម័នមិនបានធ្វើកម្មន្ត

☞ គេមិនអាចនិយាយថា កម្មន្តនៅក្នុងអង្គធាតុមួយ ឬ កម្តៅក្នុងអង្គធាតុមួយ បានទេ។

# ៤. ថាមពលក្នុង និងច្បាប់ទីមួយនៃទែម៉ូឌីណាមិច

- កម្មន្ត និងកម្តៅនៃប្រព័ន្ធទែម៉ូឌីណាមិច គឺអាស្រ័យនឹងគន្លងនៃលំនាំ (មិនអាចកំណត់អោយដាក់លាក់)។
- បម្រែបម្រួលថាមពលក្នុងរបស់ប្រព័ន្ធទែម៉ូឌីណាមិចមួយ គឺអាស្រ័យតែនឹងភាពដើម និងស្រេច (មិនអាស្រ័យនឹងគន្លង)។
- ថាមពលក្នុង (Internal Energy) នៃប្រព័ន្ធមួយ គឺជាផលបូករវាងថាមពលស៊ីនេទិចនៃភាពល្អិតទាំងអស់ក្នុងប្រព័ន្ធ និងថាមពលប៉ូតង់ស្យែលនៃអន្តរកម្មរវាងភាគល្អិតទាំងនេះ។ $U = U(\text{ភាព})$
- ច្បាប់ទី១ ទែម៉ូឌីណាមិច " ក្នុងលំនាំទែម៉ូឌីណាមិច កម្តៅស្រូបដោយប្រព័ន្ធ ស្មើនឹងផលបូកនៃកម្មន្តដែលបំពេញដោយប្រព័ន្ធ និងបម្រែបម្រួលថាមពលក្នុងនៃប្រព័ន្ធ" ។ (ថ្នាក់ទី១២)

$$Q = W + \Delta U \rightarrow \Delta U = Q - W$$

$Q$ ជាកម្តៅ (J), $W$ ជាកម្មន្ត (J) , $\Delta U$ ជាបម្រែបម្រួលថាមពលក្នុង (J)

# ៤. ថាមពលក្នុង និងច្បាប់ទីមួយនៃទែម៉ូឌីណាមិច

ច្បាប់ទីមួយទែម៉ូឌីណាមិច

$$\Delta U = Q - W$$









# ៤. ថាមពលក្នុង និងច្បាប់ទីមួយនៃទែម៉ូឌីណាមិច



### ច្បាប់ទីមួយទែម៉ូឌីណាមិចក្នុងលំហាត់ប្រាណ

រាងកាយរបស់យើងជាប្រព័ន្ធទែម៉ូឌីណាមិចមួយ។

កម្មន្តៈ push-up, $W > 0$

កម្ដៅៈ រាងកាយមនុស្សក្ដៅ $Q < 0$

បម្រែបម្រួលថាមពលក្នុងៈ $\Delta U = Q - W < 0$

លទ្ធផលៈ ស្រកគីឡូ( ថាមពលក្នុងត្រូវបានរក្សាក្នុងទម្រង់ជាខ្លាញ់ )

# ៤. ថាមពលក្នុង និងច្បាប់ទីមួយនៃទែម៉ូឌីណាមិច

### បម្លែងបិទ និងប្រព័ន្ធត្រមោច

- **បម្លែងបិទ** គឺជាបម្លែងដែលភាពដើម និងភាពស្រេចរបស់ប្រព័ន្ធដូចគ្នា $U_1(p_1, V_1, T_1) = U_2(p_2, V_2, T_2) \to \Delta U = 0 \to Q = W$ ។
- **ប្រព័ន្ធត្រមោច** គឺជាប្រព័ន្ធដែលមិនធ្វើកម្មន្ត និងផ្ទេរកម្ដៅជាមួយមជ្ឈដ្ឋានខាងក្រៅ $Q = W = 0 \to \Delta U = 0$ ។
- បម្លែងបិទ និងប្រព័ន្ធត្រមោចៈ $U_1 = U_2$ ថាមពលក្នុងរបស់ប្រព័ន្ធត្រូវបានរក្សា។

បើ $\Delta U = 0$ វាអាចជាបម្លែងបិទ ឬ ត្រមោច។

### បម្លែងបិទក្នុងរាងកាយមនុស្ស



# ៥. ប្រភេទនៃលំនាំនែម៉ូឌីណាមិច

១. លំនាំអាដ្យាបាទិច៖ មិនមានកម្តៅផ្ទេរ។ $Q = 0,\ U_2 - U_1 = \Delta U = -W$

២. លំនាំអ៊ីសូករ៖ មាឌ $V =$ ថេរ ។ $W = 0,\ U_2 - U_1 = \Delta U = Q$

៣. លំនាំអ៊ីសូបារ៖ $Q \neq 0, \Delta U \neq 0, W = p(V_2 - V_1)$

៤. លំនាំអ៊ីសូទែម៖ $Q \neq 0, W \neq 0, \Delta U \neq 0$

លំនាំអាដ្យាបាទិច



លំនាំអ៊ីសូបារ






# ៦. ថាមពលក្នុងនៃឧស្ម័នបរិសុទ្ធ

យោងតាមលទ្ធផលពិសោធន៍៖ ថាមពលក្នុង($U$)នៃឧស្ម័នបរិសុទ្ធ អាស្រ័យតែនឹងសីតុណ្ហភាព $T$។

តើថាមពលក្នុងនៃអង្គធាតុរឹងមិនអាស្រ័យនឹងមាឌរបស់វាដូចក្នុងករណីឧស្ម័នបរិសុទ្ធដែរឬទេ? ចូរពន្យល់។





# ៧. ចំណុះកម្ដៅនៃឧស្ម័នបរិសុទ្ធ

ឧបមាថាឧស្ម័នបរិសុទ្ធ $n$ ម៉ូលកើនសីតុណ្ហភាព $T \rightarrow T + dT$ ពេលស្រូបកម្ដៅ $Q$ [នៅមាឌថេរ $\rightarrow C_V$ ឬនៅសំពាធថេរ $\rightarrow C_p$]

$$Q = \Delta U + W \ \rightarrow dQ = dU + dW$$

ករណីសំពាធថេរ $nC_p\,dT = dU + p\,dV = dU + nR\,dT$

ថាមពលក្នុងនៃឧស្ម័នបរិសុទ្ធអាស្រ័យតែសីតុណ្ហភាព $dU$(សំពាធថេរ) $= dU$(មាឌថេរ) $= dQ$(មាឌថេរ) $= nC_V\,dT \quad \rightarrow nC_p\,dT = nC_V\,dT + nR\,dT$

$$\boxed{C_p = C_V + R} \qquad \boxed{\gamma = \frac{C_p}{C_V}}$$

នៅមាឌថេរ




នៅសំពាធថេរ







# ៧. ចំណុះកម្ដៅនៃឧស្ម័នបរិសុទ្ធ

**TABLE 19.1** Molar Heat Capacities of Gases at Low Pressure

| Type of Gas | Gas | $C_V$ (J/mol · K) | $C_p$ (J/mol · K) | $C_p - C_V$ (J/mol · K) | $\gamma = C_p/C_V$ |
|---|---|---|---|---|---|
| ឧស្ម័នម៉ូណូអាតូម | He | 12.47 | 20.78 | 8.31 | 1.67 |
| | Ar | 12.47 | 20.78 | 8.31 | 1.67 |
| ឧស្ម័នឌីអាតូម | $H_2$ | 20.42 | 28.74 | 8.32 | 1.41 |
| | $N_2$ | 20.76 | 29.07 | 8.31 | 1.40 |
| | $O_2$ | 20.85 | 29.17 | 8.32 | 1.40 |
| | CO | 20.85 | 29.16 | 8.31 | 1.40 |
| ឧស្ម័នប៉ូលីអាតូម | $CO_2$ | 28.46 | 36.94 | 8.48 | 1.30 |
| | $SO_2$ | 31.39 | 40.37 | 8.98 | 1.29 |
| | $H_2S$ | 25.95 | 34.60 | 8.65 | 1.33 |

# ៨. លំនាំអាដ្យាបាទិចសម្រាប់ឧស្ម័នបរិសុទ្ធ




$$dQ = 0 \rightarrow dU = -dW$$

$$nC_V dT = -p\, dV$$

$$W = -\Delta U = nC_V(T_1 - T_2)$$

$$nC_V dT = -\frac{nRT}{V}\, dV$$

$$\frac{dT}{T} + \frac{R}{C_V}\frac{dV}{V} = 0$$

$$\frac{dT}{T} + (\gamma - 1)\frac{dV}{V} = 0$$

$$\ln T + (\gamma - 1)\ln V = \text{ថេរ}$$

$$\ln(TV^{\gamma-1}) = \text{ថេរ}$$

$$TV^{\gamma-1} = \text{ថេរ} \text{ ឬ } pV^{\gamma} = \text{ថេរ}$$

ការដកដង្ហើមអាដ្យាបាទិច



តើមួយណាត្រជាក់ជាង?



# មេរៀនទី៣

# លំហាត់ឧទាហរណ៍

## ( សៀវភៅក្រសួងអប់រំ )

ក្រុម សុណា 2024

***ឧទាហរណ៍ :*** ឧបមានៅក្នុងស៊ីឡាំង C នៃរូប 2.1 (ក) មានប្រព័ន្ធឧស្ម័នដែលគេសន្មតជាឧស្ម័នបរិសុទ្ធមានមាឌ $100cm^3$ សម្ពាធ $2.00\times10^5Pa$ និងសីតុណ្ហភាព 300K ។ គេផ្តល់កម្តៅឱ្យប្រព័ន្ធឧស្ម័ន ឧស្ម័ននោះទទួលបំលែងទែម៉ូណាមិច មានមាឌ $V_2$ សម្ពាធ $2.10\times10^5Pa$ និងសីតុណ្ហភាព 333K ។ គណនាមាឌ $V_2$ នោះ ។




*(ក)*

*រូបទី 2.1 (ក)ឧស្ម័នG*

✍ ដំណោះស្រាយ

មាឌ $V_2$ នៃឧស្ម័ន

តាមសមីការឧស្ម័នបរិសុទ្ធ

ភាពដើម $P_1V_1 = nRT_1$

ភាពស្រេច $P_2V_2 = nRT_2$

ធ្វើផលធៀប $\frac{P_1V_1}{P_2V_2} = \frac{T_1}{T_2}$ ឬ $\frac{P_1V_1}{T_1} = \frac{P_2V_2}{T_2}$

យើងទាញបាន $V_2 = \frac{P_1V_1}{P_2T_1} \times T_2$

ដោយ $P_1 = 2.00 \times 10^5\text{Pa}$ , $V_1 = 100\text{cm}^3$ , $T_1 = 300\text{K}$

$P_2 = 2.10 \times 10^5\text{Pa}$ , $T_2 = 333\text{K}$

យើងបាន $V_2 = \frac{(2.00 \times 10^5\text{P}_a)(100\text{cm}^3)(333\text{K})}{(2.10 \times 10^5\text{P}_a)(300\text{K})}$

ដូចនេះ $V_2 = 106\text{cm}^3$ ។




(ក)

រូបទី 2.1 (ក) ឧស្ម័ន G

***ឧទាហរណ៍ :*** នៅសម្ពាធថេរ $150 \times 10^3\text{Pa}$ ឧស្ម័នមួយរីកមាឌពី $75 \times 10^4\text{cm}^3$ ទៅ $90 \times 10^4\text{cm}^3$ ។ គណនាកម្មន្តដែលបំពេញដោយឧស្ម័ននោះ ។

✍ ដំណោះស្រាយ

កម្មន្តដែលបំពេញដោយឧស្ម័ន

តាមសមីការ (1.23) យើងបាន

$W = P(V_2 - V_1)$ តែ $V_1 = 75 \times 10^4\text{cm}^3 = 0.75\text{m}^3$

$V_2 = 90 \times 10^4\text{cm}^3 = 0.90\text{m}^3$

$P = 150 \times 10^3\text{Pa}$

យើងបាន $W = (150 \times 10^3\text{Pa})(0.90\text{m}^3 - 0.75\text{m}^3)$

ដូចនេះ $\boxed{W = 22.5\text{kJ}}$

kou.moeys.gov.kh

***ឧទាហរណ៍*** **:** ឧស្ម័នមួយរីកមាឌពី $0.40m^3$ ទៅ $0.60m^3$ និងសម្ពាធកើនស្មើពី $100\times10^3Pa$ ទៅ $220\times10^3Pa$ ។ គណនាកម្មន្តដែលបំពេញដោយឧស្ម័ននោះ ។




***រូបទី 2.4 ដ្យាក្រាម P-V***

ដំណោះស្រាយ

កម្មន្តដែលបំពេញដោយឧស្ម័ន

តាមសមីការ (1.25) យើងបាន

$$W = P_1(V_2-V_1) + \frac{1}{2}(P_2-P_1)(V_2-V_1)$$

ដោយ $P_1 = 100\times10^3Pa$ $P_2 = 220\times10^3Pa$

$V_1 = 0.40m^3$ $V_2 = 0.60m^3$

យើងបាន :

$$W = (100\times10^3Pa)(0.60m^3-0.40m^3)+\frac{1}{2}(220\times10^3Pa-100\times10^3Pa)(0.60m^3-0.40m^3)$$

ដូចនេះ : $\boxed{W = 3.20\times10^4J}$ ។

***ឧទាហរណ៍*** **:** តាមដ្យាក្រាមខាងក្រោម ចូរគណនាកម្មន្តដែលធ្វើដោយឧស្ម័នមួយ ។

ដំណោះស្រាយ




***រូបទី 2.5 ដ្យាក្រាម P-V***

ផ្ទៃចតុកោណកែង

$A_1 = P_1(V_2-V_1)$

$A_1 = (100\times10^3Pa)(0.60m^3-0.40m^3)$

$A_1 = 20\times10^3J$

ផ្ទៃត្រីកោណ

$A_2 = \frac{1}{2}(P_2-P_1)(V_2-V_1)$

$A_2 = \frac{1}{2}(220\times10^3Pa-100\times10^3Pa)(0.60m^3-0.40m^3)$

$A_2 = 12\times10^3J$

សរុបផ្ទៃក្រោមក្រាប ដើម្បីគណនាកម្មន្តធ្វើដោយឧស្ម័ននោះ

$\Delta W = (A_1+A_2)$ $\Rightarrow$ $\Delta W = (20\times10^3J+12\times10^3J)$

ដូចនេះ $\boxed{W = 32\times10^3J}$

***ឧទាហរណ៍*** : ឧស្ម័នបរិសុទ្ធ 1.0mol មានសីតុណ្ហភាពថេរ 0.0°C ក្នុងរយៈពេលបម្រែបម្រួលមាឌ $3.0\ell$ ទៅ $10.0\ell$ ។ គណនាកម្មន្តដែលបំពេញដោយឧស្ម័ននោះ ក្នុងរយៈពេលបម្រែបម្រួលមាឌនោះ ។



រូបទី2.6 ដ្យាក្រាម P-V ករណីសីតុណ្ហភាពថេរ

✍ ដំណោះស្រាយ

កម្មន្តបំពេញដោយឧស្ម័នក្នុងរយៈពេលបម្រែបម្រួលមាឌ

តាមសមីការ (1.26)

យើងបាន $W = nRT\ \ell n\left(\frac{V_2}{V_1}\right)$

$n = 1.0mol \quad R = 8.31J/(molK) \quad T = 273K \quad V_1 = 3.0\ell \quad V_2 = 10.0\ell$

$$W = (1.0mol) \times (8.31 \times J/molK) \times (273K)\ell n\left(\frac{10.0\ell}{3.0\ell}\right)$$

ដូចនេះ $\boxed{W = 27.2 \times 10^2 J}$ ។

***ឧទាហរណ៍*** : ឧស្ម័នមួយស្រូបកម្ដៅ 800J និងបំពេញកម្មន្ត 200J ក្នុងពេលលំនាំនេះវាបានបញ្ចេញកម្ដៅទៅវិញ 300J ។ ចូរគណនាបម្រែបម្រួលថាមពលក្នុងរបស់ឧស្ម័ននោះ ។

✍ ដំណោះស្រាយ

បម្រែបម្រួលថាមពលក្នុងនៃឧស្ម័ន

តាមរូបមន្ត : $\Delta U = Q - W$

តែ $Q = 800J - 300J = 500J$

ហើយ $W = 200J$

យើងបាន $\Delta U = 500J - 200J$

ដូចនេះ $\Delta U = 300J$

តាមចម្លើយនេះបង្ហាញឱ្យឃើញថា ថាមពលក្នុងរបស់ឧស្ម័នកើន ។

***ឧទាហរណ៍*** : ដ្យាក្រាម $P \cdot V$ តាងស៊ិចមួយនៃម៉ូលេគុល ឧស្ម័នបរិសុទ្ធមួយម៉ូល :

ក្នុងបំលែងពី $A \rightarrow B$ សម្ពាធថេរ

ក្នុងបំលែងពី $B \rightarrow C$ មាឌថេរ

ក្នុងបំលែងពី $C \rightarrow A$ សម្ពាធប្រែប្រួលស្មើ

ចូរគណនា :

ក. កម្មន្ត $W_{AB}$ ក្នុងបំលែង $A \rightarrow B$

ខ. កម្មន្ត $W_{BC}$ ក្នុងបំលែង $B \rightarrow C$

គ. កម្មន្ត $W_{CA}$ ក្នុងបំលែង $C \rightarrow A$

ឃ. កម្មន្តសរុបក្នុងបំលែងបិទ

ង. កម្ដៅសរុបក្នុងបំលែងបិទ




*រូបទី 2.9 បំលែងបិទ*

## ✍ ដំណោះស្រាយ

ក. កម្មន្ត $W_{AB}$ ក្នុងបំលែង $A \rightarrow B$

ដោយសម្ពាធថេរ $W_{AB} = P_A \Delta V$ យើងបាន $W_{AB} = 10^5 Pa(0.0125m^3 - 0.02m^3)$

ដូចនេះ $W_{AB} = -7.5 \times 10^2 J$

ខ. កម្មន្ត $W_{BC}$ ដោយ $\Delta V = 0 \Rightarrow W_{BC} = 0$

គ. កម្មន្តធ្វើពី $C \to A$

$$W_{CA} = P_C(V_A - V_C) + \frac{1}{2}(P_A - P_C)(V_A - V_C) \text{ ឬ } W_{CA} = \left(\frac{P_A + P_C}{2}\right)(V_A - V_C)$$

$$W_{CA} = 10^5 Pa(0.02m^3 - 0.0125m^3) + \frac{1}{2}(10^5 Pa - 2 \times 10^5 Pa)(0.02m^3 - 0.0125m^3)$$

$$W_{CA} = -375J$$

ឃ. កម្មន្តសរុបធ្វើក្នុងបំលែងបិទ

$W = W_{AB} + W_{BC} + W_{CA}$ នោះ $W = 750J + 0 + (+375J)$ ដូចនេះ $\boxed{W = 1125J}$

ង. កម្តៅសរុបក្នុងបំលែងបិទនេះ

តាមគោលការណ៍សមមូល យើងបាន $Q - W = 0$ នោះ $Q = W = 1125J$

ដូចនេះ $\boxed{Q = 1125J}$

***ឧទាហរណ៍ :*** កាលណាឧស្ម័នត្រូវបានបណ្ណែនតាមបែបអាដ្យាបាទិច កម្មន្តបានធ្វើទៅលើឧស្ម័ននោះគឺ 640J ។ គណនាបម្រែបម្រួលថាមពលក្នុងរបស់ឧស្ម័ន ។

✍ ដំណោះស្រាយ

បម្រែបម្រួលថាមពលក្នុងនៃឧស្ម័ន

តាមរូបមន្ត $W = -\Delta U$ នាំឱ្យ $\Delta U = -W$ តែ $W = -640J$

យើងបាន $\Delta U = -(-640J)$ ដូចនេះ $\Delta U = 640J$

# មេរៀនទី៣

# លំហាត់ឧទាហរណ៍

## (សៀវភៅក្រសួងអប់រំ)

**ក្រុម សុណា** 2024

***ឧទាហរណ៍ :*** ឧបមានៅក្នុងស៊ីឡាំង C នៃរូប 2.1 (ក) មានប្រព័ន្ធឧស្ម័នដែលគេសន្មតជាឧស្ម័នបរិសុទ្ធមានមាឌ $100cm^3$ សម្ពាធ $2.00 \times 10^5 Pa$ និងសីតុណ្ហភាព 300K ។ គេផ្តល់កម្តៅឱ្យប្រព័ន្ធឧស្ម័ន ឧស្ម័ននោះទទួលបំលែងទែម៉ូណាមិច មានមាឌ $V_2$ សម្ពាធ $2.10 \times 10^5 Pa$ និងសីតុណ្ហភាព 333K ។ គណនាមាឌ $V_2$ នោះ ។




*(ក)*

*រូបទី 2.1 (ក) ឧស្ម័ន G*

✍ ដំណោះស្រាយ

មាឌ $V_2$ នៃឧស្ម័ន

តាមសមីការឧស្ម័នបរិសុទ្ធ

ភាពដើម $P_1V_1 = nRT_1$

ភាពស្រេច $P_2V_2 = nRT_2$

ធ្វើផលធៀប $\frac{P_1V_1}{P_2V_2} = \frac{T_1}{T_2}$ ឬ $\frac{P_1V_1}{T_1} = \frac{P_2V_2}{T_2}$

យើងទាញបាន $V_2 = \frac{P_1V_1}{P_2T_1} \times T_2$

ដោយ $P_1 = 2.00 \times 10^5 Pa$ , $V_1 = 100 cm^3$ , $T_1 = 300K$

$P_2 = 2.10 \times 10^5 Pa$ , $T_2 = 333K$

យើងបាន $V_2 = \frac{(2.00 \times 10^5 P_a)(100 cm^3)(333K)}{(2.10 \times 10^5 P_a)(300K)}$

ដូចនេះ $V_2 = 106 cm^3$ ។




(ក)
រូបទី 2.1 (ក)ឧស្ម័នG

***ឧទាហរណ៍*** : នៅសម្ពាធថេរ $150 \times 10^3 Pa$ ឧស្ម័នមួយរីកមាឌពី $75 \times 10^4 cm^3$ ទៅ $90 \times 10^4 cm^3$ ។ គណនាកម្មន្តដែលបំពេញដោយឧស្ម័ននោះ ។

✍ ដំណោះស្រាយ

កម្មន្តដែលបំពេញដោយឧស្ម័ន

តាមសមីការ (1.23) យើងបាន

$W = P(V_2 - V_1)$ តែ $V_1 = 75 \times 10^4 cm^3 = 0.75 m^3$

$V_2 = 90 \times 10^4 cm^3 = 0.90 m^3$

$P = 150 \times 10^3 Pa$

យើងបាន $W = (150 \times 10^3 Pa)(0.90 m^3 - 0.75 m^3)$

ដូចនេះ $\boxed{W = 22.5 kJ}$

***ឧទាហរណ៍*** **:** ឧស្ម័នមួយរីកមាឌពី $0.40m^3$ ទៅ $0.60m^3$ និងសម្ពាធកើនស្មើពី $100 \times 10^3Pa$ ទៅ $220 \times 10^3Pa$ ។ គណនាកម្មន្តដែលបំពេញដោយឧស្ម័ននោះ ។




*រូបទី 2.4 ដ្យាក្រាម P-V*

✍ ដំណោះស្រាយ

កម្មន្តដែលបំពេញដោយឧស្ម័ន

តាមសមីការ (1.25) យើងបាន

$$W = P_1(V_2-V_1) + \frac{1}{2}(P_2-P_1)(V_2-V_1)$$

ដោយ $P_1 = 100 \times 10^3Pa$ $P_2 = 220 \times 10^3Pa$

$V_1 = 0.40m^3$ $V_2 = 0.60m^3$

យើងបាន :

$$W = (100 \times 10^3Pa)(0.60m^3 - 0.40m^3) + \frac{1}{2}(220 \times 10^3Pa - 100 \times 10^3Pa)(0.60m^3 - 0.40m^3)$$

ដូចនេះ : $\boxed{W = 3.20 \times 10^4J}$ ។

***ឧទាហរណ៍*** **:** តាមដ្យាក្រាមខាងក្រោម ចូរគណនាកម្មន្តដែលធ្វើដោយឧស្ម័នមួយ ។

✍ ដំណោះស្រាយ




*រូបទី 2.5 ដ្យាក្រាម P-V*

ផ្ទៃចតុកោណកែង

$A_1 = P_1(V_2-V_1)$

$A_1 = (100 \times 10^3Pa)(0.60m^3 - 0.40m^3)$

$A_1 = 20 \times 10^3J$

ផ្ទៃត្រីកោណ

$A_2 = \frac{1}{2}(P_2-P_1)(V_2-V_1)$

$A_2 = \frac{1}{2}(220 \times 10^3Pa - 100 \times 10^3Pa)(0.60m^3 - 0.40m^3)$

$A_2 = 12 \times 10^3J$

សរុបផ្ទៃក្រោមក្រាប ដើម្បីគណនាកម្មន្តធ្វើដោយឧស្ម័ននោះ

$\Delta W = (A_1 + A_2) \Rightarrow \Delta W = (20 \times 10^3J + 12 \times 10^3J)$

ដូចនេះ $\boxed{W = 32 \times 10^3J}$

***ឧទាហរណ៍*** : ឧស្ម័នបរិសុទ្ធ 1.0mol មានសីតុណ្ហភាពថេរ 0.0°C ក្នុងរយៈពេលបម្រែបម្រួលមាឌ 3.0ℓ ទៅ 10.0ℓ ។ គណនាកម្មន្តដែលបំពេញដោយឧស្ម័ននោះ ក្នុងរយៈពេលបម្រែបម្រួលមាឌនោះ ។




*រូបទី2.6 ដ្យាក្រាម P-V ករណីសីតុណ្ហភាពថេរ*

✍ ដំណោះស្រាយ

កម្មន្តបំពេញដោយឧស្ម័នក្នុងរយៈពេលបម្រែបម្រួលមាឌ

តាមសមីការ (1.26)

យើងបាន $W = nRT\ \ell n\left(\frac{V_2}{V_1}\right)$

$n = 1.0mol \qquad R = 8.31J/(molK) \qquad T = 273K \qquad V_1 = 3.0\ell \qquad V_2 = 10.0\ell$

$W = (1.0mol) \times (8.31 \times J/molK) \times (273K)\ell n\left(\frac{10.0\ell}{3.0\ell}\right)$

ដូចនេះ $\boxed{W = 27.2 \times 10^2 J}$ ។

***ឧទាហរណ៍*** : ឧស្ម័នមួយស្រូបកម្តៅ 800J និងបំពេញកម្មន្ត 200J ក្នុងពេលលំនាំនេះវាបានបញ្ចេញកម្តៅទៅវិញ 300J ។ ចូរគណនាបម្រែបម្រួលថាមពលក្នុងរបស់ឧស្ម័ននោះ ។

✍ ដំណោះស្រាយ

បម្រែបម្រួលថាមពលក្នុងនៃឧស្ម័ន

តាមរូបមន្ត : $\Delta U = Q - W$

តែ $Q = 800J - 300J = 500J$

ហើយ $W = 200J$

យើងបាន $\Delta U = 500J - 200J$

ដូចនេះ $\Delta U = 300J$

តាមចម្លើយនេះបង្ហាញឱ្យឃើញថា ថាមពលក្នុងរបស់ឧស្ម័នកើន ។

***ឧទាហរណ៍*** : ដ្យាក្រាម $P \cdot V$ តាងស៊ិចមួយនៃម៉ូលេគុល ឧស្ម័នបរិសុទ្ធមួយម៉ូល :

ក្នុងបំលែងពី $A \rightarrow B$ សម្ពាធថេរ

ក្នុងបំលែងពី $B \rightarrow C$ មាឌថេរ

ក្នុងបំលែងពី $C \rightarrow A$ សម្ពាធប្រែប្រួលស្មើ

ចូរគណនា :

ក. កម្មន្ត $W_{AB}$ ក្នុងបំលែង $A \rightarrow B$

ខ. កម្មន្ត $W_{BC}$ ក្នុងបំលែង $B \rightarrow C$

គ. កម្មន្ត $W_{CA}$ ក្នុងបំលែង $C \rightarrow A$

ឃ. កម្មន្តសរុបក្នុងបំលែងបិទ

ង. កម្ដៅសរុបក្នុងបំលែងបិទ




*រូបទី 2.9 បំលែងបិទ*

## ✍ ដំណោះស្រាយ

ក. កម្មន្ត $W_{AB}$ ក្នុងបំលែង $A \rightarrow B$

ដោយសម្ពាធថេរ $W_{AB} = P_A \Delta V$ យើងបាន $W_{AB} = 10^5 Pa(0.0125m^3 - 0.02m^3)$

ដូចនេះ $W_{AB} = -7.5 \times 10^2 J$

ខ. កម្មន្ត $W_{BC}$ ដោយ $\Delta V = 0 \Rightarrow W_{BC} = 0$

គ. កម្មន្តធ្វើពី $C \to A$

$$W_{CA} = P_C(V_A - V_C) + \frac{1}{2}(P_A - P_C)(V_A - V_C) \text{ ឬ } W_{CA} = \left(\frac{P_A + P_C}{2}\right)(V_A - V_C)$$

$$W_{CA} = 10^5\text{Pa}(0.02\text{m}^3 - 0.0125\text{m}^3) + \frac{1}{2}(10^5\text{Pa} - 2 \times 10^5\text{Pa})(0.02\text{m}^3 - 0.0125\text{m}^3)$$

$W_{CA} = -375\text{J}$ កែទៅ $W_{CA} = 375$ J

ឃ. កម្មន្តសរុបធ្វើក្នុងបំលែងបិទ

$W = W_{AB} + W_{BC} + W_{CA}$ នោះ $W = 750\text{J} + 0 + (+375\text{J})$ ដូចនេះ $\boxed{W = 1125\text{J}}$

ង. កម្ដៅសរុបក្នុងបំលែងបិទនេះ កែទៅ $W = -750 + 0 + 375 = 375$ J

តាមគោលការណ៍សមមូល យើងបាន $Q - W = 0$ នោះ $Q = W = 1125\text{J}$

ដូចនេះ $\boxed{Q = 1125\text{J}}$ កែទៅ $Q = 375$ J

***ឧទាហរណ៍*** **:** កាលណាឧស្ម័នត្រូវបានបណ្ដែនតាមបែបអាដ្យាបាទិច កម្មន្តបានធ្វើទៅលើឧស្ម័ននោះគឺ 640J ។ គណនាបម្រែបម្រួលថាមពលក្នុងរបស់ឧស្ម័ន ។

✍ ដំណោះស្រាយ

បម្រែបម្រួលថាមពលក្នុងនៃឧស្ម័ន

តាមរូបមន្ត $W = -\Delta U$ នាំឱ្យ $\Delta U = -W$ តែ $W = -640\text{J}$

យើងបាន $\Delta U = -(-640\text{J})$ ដូចនេះ $\Delta U = 640\text{J}$

moeys.gov.kh

# មេរៀនទី៣
# លំហាត់ពិភាក្សាក្រុម

ក្រុម សុណា 2024

## ៤. ថាមពលក្នុង និងច្បាប់ទីមួយនៃទែម៉ូឌីណាមិច

លំហាត់ ពិភាក្សាក្រុម ១. ប្រធានបទ៖ តើអ្នកចង់ញ៉ាំអាហារនេះទៀតទេ ?

ដើម្បីរក្សាទម្ងន់របស់អ្នក គ្រូកីឡារបស់អ្នកបានប្រាប់អ្នកអោយឡើងជណ្ដើរនៃអគាមួយ ដើម្បីចំនាយទាំងស្រុងនូវថាមពលដែលអ្នកបានពីការញ៉ាំអាហារមួយដែលផ្ដល់ថាមពល 900 kcal ( 900 កាឡូរីនៃម្ហូប )។

ក. តើជណ្ដើរដែលអ្នកឡើងមានកំពស់ប៉ុន្មាន ? សន្មត់ថាអ្នកមានម៉ាស 60.0 kg និង $g = 9.8\ \mathrm{m/s^2}$ ហើយមិនគិតកំហាតថាមពលកម្ដៅពេលឡើងជណ្ដើរ។

ខ. តាមពិតទៅពេលដែលអ្នកឡើងជណ្ដើរ 75% នៃថាមពលបានពីអាហារនេះគឺផ្ទេរចេញពីរាងកាយរបស់អ្នកក្នុងទម្រង់ជាកម្ដៅ។ ចូរធ្វើសំណួរ ( ក ) ឡើងវិញ។

## ៤. ថាមពលក្នុង និងច្បាប់ទីមួយនៃទែម៉ូឌីណាមិច

លំហាត់ ពិភាក្សាក្រុម ២. រូបខាងស្តាំ ជាដ្យាក្រាម(P-V)នៃបំលែងបិទមួយ ដែលភាពដើម និងភាពស្រេចនៃប្រព័ន្ធទែម៉ូឌីណាមិច គឺរក្សា(ដូចគ្នា)។ ភាពនៃប្រព័ន្ធចាប់ផ្តើមពីចំណុច a ហើយដំណើរការតាមទិសដៅផ្ទុយពីទិសដៅទ្រនិចនាឡិកា ក្នុងដ្យាក្រាម(P-V) ទៅដល់ចំណុច b រួចត្រលប់មកដល់ចំណុច a វិញ ដែលមានកម្មន្តសរុប $W = -500$ J។

a) ហេតុអ្វីបានជាតម្លៃកម្មន្តសរុបអវិជ្ជមាន?

b) ចូររកបម្រែបម្រួលថាមពលក្នុង និងកម្តៅដែលផ្តល់អោយប្រព័ន្ធកំឡុងពេលដំណើរការ។




## ៨. លំនាំអាដ្យាបាទិចសម្រាប់ឧស្ម័នបរិសុទ្ធ

លំហាត់ ពិភាក្សាក្រុម ៣. ខ្យល់នៅក្នុងបំពង់ស៊ីឡាំងរបស់ម៉ាស៊ីនមួយត្រូវបានគេបណ្ណែនទៅ 1/15.0 នៃមាឌដើមរបស់វា។

ក. ប្រសិនបើសំពាធដើម និង សីតុណ្ហភាពដើម មានតម្លៃ $1.01 \times 10^5$ Pa និង 27 °C រៀងគ្នា ចូរគណនាសំពាធស្រេច និង សីតុណ្ហភាពស្រេចក្រោយការបណ្ណែនតាមលំនាំអាដ្យាបាទិច។

ខ. ចូរគណនាកម្មន្តដែលបំពេញដោយឧស្ម័នប្រសិនបើមាឌដើមរបស់វាគឺ 1.00 L។ សម្រាប់ខ្យល់ $C_V = 20.8$ J/mol · K និង $\gamma = 1.400$។



# មេរៀនទី៣

# លំហាត់ស្រាវជ្រាវបន្ថែម

# (សៀវភៅក្រសួងអប់រំ+បកប្រែ)

ក្រុម សុណា 2024

## លំហាត់

**លំហាត់អនុវត្តន៍**

ជាមួយនឹងសម្ពាធថេរ 200kPa ឧស្ម័នមួយប្រែប្រួលមាឌពី $0.75m^3$ ទៅ $1.9m^3$ ។ គណនាកម្មន្តបំពេញដោយឧស្ម័នក្នុងរយៈពេលរីកមាឌនេះ ។

**លំហាត់អនុវត្តន៍**

ឧស្ម័នបរិសុទ្ធមួយមានសីតុណ្ហភាពថេរ $T = 300K$ ក្នុងរយៈពេលបម្រែបម្រួលមាឌពី $V_1 = 0.31m^3$ ទៅ $V_2 = 0.45m^3$ ។ គេដឹងថាឧស្ម័នមាន $n = 0.50mol$ ។ គណនាកម្មន្តបំពេញដោយឧស្ម័នក្នុងពេលបម្រែបម្រួលមាឌនោះ ។

# លំហាត់

## លំហាត់អនុវត្តន៍

ម៉ាស៊ីនកម្តៅមួយបានបំពេញកម្មន្ត 250J ក្នុងរយៈពេលដែលថាមពលក្នុងរបស់ម៉ាស៊ីនថយចុះ 500J ។ ក្នុងលំនាំនេះ កម្តៅរបស់ម៉ាស៊ីនមានតម្លៃប៉ុន្មាន ?

## លំហាត់ប្រតិបត្តិ

លំនាំអាដ្យាបាទិចមួយ បើថាមពលក្នុងថយចុះ 500J តើកម្មន្តដែលបំពេញដោយប្រព័ន្ធនោះស្មើនឹងប៉ុន្មាន ?

# លំហាត់

5. គេសន្មតថា ឧស្ម័នមួយនៅក្នុងស៊ីឡាំងដែលបិទដោយពីស្តុងអាចរីកមាឌក្រោមសម្ពាធថេរ 200kPa ពី $2dm^3$ ទៅ $5dm^3$ ។ តើកម្មន្តធ្វើដោយឧស្ម័ននោះមានតម្លៃប៉ុន្មាន ?

   **ចម្លើយ** : $W = 600J$

6. ក្នុងលំនាំនៃឧស្សាហកម្មគីមីមួយ បានផ្តល់កម្តៅ 600J ទៅឱ្យប្រព័ន្ធ និងប្រព័ន្ធបានបំពេញកម្មន្ត 200J ។ តើថាមពលក្នុងនៃប្រព័ន្ធកើនបានប៉ុន្មាន ? **ចម្លើយ** : $\Delta U = 400J$

7. ក. ពិសីរត់ត្រឹកៗតាមបណ្តោយឆ្នេរសមុទ្រ ។ ក្នុងមួយថ្ងៃនាងបានបំពេញកម្មន្ត $4.3\times10^5 J$ និងបញ្ចេញកម្តៅបាន $3.8\times10^5 J$ ។ គណនាបម្រែបម្រួលថាមពលក្នុងរបស់នាង ។

   ខ. នាងបានប្តូរពីរត់មកដើរវិញនិងបានបញ្ចេញកម្តៅ $1.2\times10^5 J$ និងថាមពលក្នុងរបស់នាងថយចុះ $2.6\times10^5 J$ ។ ក្នុងករណីនេះ តើនាងធ្វើកម្មន្តបានប៉ុន្មានស៊ូល ?

   **ចម្លើយ** : ក. $\Delta U = -8.1\times10^5 J$ ខ. $W = 1.4\times10^5 J$

## លំហាត់

8. ក្នុងស៊ីឡាំងមួយមានឧស្ម័នបរិសុទ្ធម៉ូណូអាតូម 0.5mol នៅសីតុណ្ហភាព 310K ។ ដោយរក្សាសីតុណ្ហភាពឱ្យនៅដដែល ឧស្ម័ននេះបានរីកមាឌពី $310dm^3$ ទៅ $450dm^3$ ។

គេឱ្យ $R = 8.31J/molK$

ក. គណនាកម្មន្តដែលបានធ្វើក្នុងរយៈពេលបម្រែបម្រួលមាឌនេះ ។

ខ. គណនាបម្រែបម្រួលថាមពលក្នុងនៃឧស្ម័ន ។

គ. គណនាកម្តៅដែលស្រូបដោយប្រព័ន្ធក្នុងរយៈពេលនៃបម្រែបម្រួលមាឌនេះ ។

ចម្លើយ : ក. $W = 480J$ ខ. $\Delta U = \frac{3}{2}R(T_2 - T_1) = 0$ គ. $Q = 480J$

## លំហាត់

ដ្យាក្រាម (P-V) ខាងស្តាំ បង្ហាញពីសំណុំនៃលំនាំទែម៉ូឌីណាមិច។ ក្នុងលំនាំ ab កម្តៅ 150 J ត្រូវបានផ្តល់អោយប្រព័ន្ធ និងក្នុងលំនាំ bd កម្តៅ 600 J ត្រូវបានផ្តល់អោយប្រព័ន្ធ។ ចូរគណនា

a) បម្រែបម្រួលថាមពលក្នុង ក្នុងលំនាំ ab។

b) បម្រែបម្រួលថាមពលក្នុង ក្នុងលំនាំ abd។

c) កម្តៅសរុបដែលផ្តល់អោយប្រព័ន្ធក្នុងលំនាំ acd។



## លំហាត់

ទឹក 1 g ( 1 $cm^3$ ) ក្លាយជាចំហាយដែលមានមាឌ 1671 $cm^3$ នៅពេលដុតកម្តៅអោយពុះក្នុងលក្ខខណ្ឌសម្ពាធថេរ 1 atm( $1.013 \times 10^5$ Pa )។ កម្តៅរំហួតនៅកម្រិតសម្ពាធនេះគឺ $L_V = 2.256 \times 10^6$ J/kg។ ចូរគណនា

a ) កម្មន្តធ្វើដោយទឹកនៅពេលវាហួត។

b ) កំនើនថាមពលក្នុងរបស់ទឹក។

## លំហាត់

បន្ទប់ស្នាក់នៅក្នុងអន្តេវាសិកដាទូទៅមានផ្ទុកខ្យល់ 2500 ម៉ូល។ ចូរគណនាបម្រែបម្រួលថាមពលក្នុងនៅពេលដែលវាថយចុះសីតុណ្ហភាពពី 35.0°C ទៅ 26.0°C នៅសំពាធថេរ 1.00 atm។ សន្មត់ថាខ្យល់ជាឧស្ម័នបរិសុទ្ធដែលមាន $\gamma = 1.400$។

## លំហាត់

ឧស្ម័នបរិសុទ្ធ 2 mol ត្រូវបានដុតកម្តៅក្រោមលក្ខខណ្ឌសម្ពាធថេរ ពីសីតុណ្ហភាព$T = 27\ ^{\circ}\mathrm{C}$ ទៅ $T = 107\ ^{\circ}\mathrm{C}$។

a) ចូរគូសដ្យាក្រាម(P-V)សម្រាប់លំនាំនេះ។

b) ចូរគណនាកម្មន្តដែលធ្វើដោយឧស្ម័នក្នុងលំនាំនេះ។

## លំហាត់

ឧស្ម័នបរិសុទ្ធ 6 mol ស្ថិតក្នុងស៊ីឡាំងដែលចុងម្ខាងមានពិស្តុងដែលអាចផ្លាស់ទីបាន។ សីតុណ្ហភាពដើមរបស់ឧស្ម័នគឺ 27.0 °C ហើយវារីកក្រោមសម្ពាធថេរ។ វាជាផ្នែកមួយនៃដំណើរការរបស់ម៉ាស៊ីន ចូរគណនាសីតុណ្ហភាពស្រេចរបស់ឧស្ម័ន បន្ទាប់ពីវាធ្វើកម្មន្តបាន $2.40 \times 10^{3}$ J។

## លំហាត់

ឧស្ម័នបរិសុទ្ធ 2 mol ត្រូវបានបណ្ណែនក្នុងស៊ីឡាំងក្រោមលក្ខខណ្ឌសីតុណ្ហភាពថេរ 65.0 ℃ រហូតមាឌរបស់វាកើនឡើងដល់ 3 ដងនៃមាឌដើម ។

a ) ចូរគូសដ្យាក្រាម ( P-V )នៃលំនាំនេះ។

b ) ចូរគណនាកម្មន្តដែលធ្វើដោយឧស្ម័ន។

## លំហាត់

ឧស្ម័នបរិសុទ្ធ 0.305 mol ត្រូវបានបណ្ណែនតាមលំនាំអ៊ីសូទែម នៅសីតុណ្ហភាព 22.0 ℃ ឧស្ម័នរងនូវកម្មន្ត 392 J ពីមជ្ឈដ្ឋានខាងក្រៅ។

a ) ប្រសិនសម្ពាធស្រេចរបស់ឧស្ម័ន1.76 atm តើឧស្ម័នមានសម្ពាធដើមស្មើប៉ុន្មាន ?

b ) ចូរគូសដ្យាក្រាម( P-V )នៃលំនាំនេះ។

## លំហាត់

ឧស្ម័នមួយដំណើរការ ក្រោមលំនាំពីរប្រភេទ។ ដំបូង វាមានមាឌថេរ $0.200\ \mathrm{cm}^3$ ហើយសម្ពាធកើនពី $2.00\times10^5$ Pa ទៅ $5.00\times10^5$ Pa។ លំនាំទីពីរ ឧស្ម័នត្រូវបានបណ្ណែនមាឌនៅត្រឹម $0.120\ \mathrm{cm}^3$ ក្រោមលក្ខខណ្ឌសម្ពាធថេរ $5.00\times10^5$ Pa។

a) ចូរគូសដ្យាក្រាម (P-V) នៃលំនាំទាំងពីរ។

b) ចូរគណនាកម្មន្តបំពេញដោយឧស្ម័នក្នុងលំនាំទាំងពីរ។

## លំហាត់

ឧស្ម័នបរិសុទ្ធមួយស្ថិតក្រោមលំនាំទែម៉ូឌីណាមិច ដែលសម្ពាធត្រូវបានរក្សាអោយសមាមាត្រនឹងមាឌ មានន័យថា $p=\alpha V$ ($\alpha$ ជាតម្លៃថេរវិជ្ជមាន)។ ប្រសិនមាឌឧស្ម័នប្រែប្រួលពី $V_1$ ទៅ $V_2$ ចូរគណនាកម្មន្តដែលធ្វើដោយឧស្ម័ន ជាអនុគមន៍នៃ $V_1, V_2$ និង $\alpha$ ។

## លំហាត់

ឧស្ម័នក្នុងស៊ីឡាំងមួយ រីកមាឌពី 0.110 $m^3$ ទៅ 0.320 $m^3$។ កម្តៅផ្ទេរអោយឧស្ម័ន គឺលឿនខ្លាំងដែលអាចរក្សាសម្ពាធអោយថេរត្រឹម $1.65 \times 10^5$ Pa កំឡុងពេលឧស្ម័នរីកមាឌ។ កម្តៅសរុបដែលផ្តល់អោយឧស្ម័ន គឺ $1.15 \times 10^5$ J។

a) ចូរគណនាកម្មន្តបំពេញដោយឧស្ម័ន។

b) ចូរគណនាបំរែបំរួលថាមពលក្នុងរបស់ឧស្ម័ន។

c) តើវាចាំបាច់ទេដែរឬទេ ដែលឧស្ម័នត្រូវតែជាឧស្ម័នបរិសុទ្ធ? ហេតុអ្វី?

## លំហាត់

ឧស្ម័នបរិសុទ្ធម៉ូណូអាតូម 5 mol មានសីតុណ្ហភាពដើម 127 °C ស្រូបកម្តៅ 1500 J និងធ្វើកម្មន្ត 2100 J កំឡុងពេលដំណើរការពង្រីក។ ចូរគណនាសីតុណ្ហភាពស្រេចរបស់ឧស្ម័ន។

# លំហាត់

លំនាំ abc បង្ហាញក្នុងដ្យាក្រាម(P-V) ក្នុងរូបខាងក្រោម ជាលំនាំទែម៉ូឌីណាមិចរបស់ឧស្ម័នបរិសុទ្ធ 0.0175 mol។

a) ចូរកំណត់សីតុណ្ហភាពដែលទាបបំផុតរបស់ឧស្ម័នក្នុងលំនាំនេះ។ តើវាកើតឡើងត្រង់ណា?

b) រកកម្មន្តក្នុងលំនាំ ab និង bc។

c) ប្រសិនកម្ដៅ 215 J ត្រូវបានផ្ដល់អោយឧស្ម័នក្នុងលំនាំ abc តើកម្ដៅប៉ុន្មានស៊ូលដែលបានបម្លែងទៅជាថាមពលក្នុង?



# មេរៀនទី៤ ÷ ច្បាប់ទី ២ ទែម៉ូឌីណាមិច



ក្រុម សុណា 2024

## សេចក្ដីផ្ដើម






តាមលក្ខណៈធម្មជាតិនៃលំនាំទែម៉ូឌីណាមិចភាគច្រើនប្រព្រឹត្តទៅតាមតែមួយទិសដៅ គឺមិនអាចប្រាសវិញបានទេ។

ឧទាហរណ៍1. កម្ដៅតែងតែហូរពីអង្គធាតុក្ដៅទៅអង្គធាតុត្រជាក់។

ឧទាហរណ៍2. វាមានភាពងាយស្រួលក្នុងការបម្លែងពី ថាមពលមេកានិចទៅជាថាមពលកម្ដៅស្ទើរតែទាំងស្រុង (ដូចជាការចាប់ប្រាំងឡានដែលកំពុងផ្លាស់ទី)

បញ្ច្រាសមកវិញ

ឧបករណ៍ជាច្រើនអាចបម្លែងថាមពលកម្ដៅដោយផ្នែកតែប៉ុណ្ណោះទៅជាថាមពលមេកានិច (ដូចជាម៉ាស៊ីនផ្សេងៗ)។

ហេតុអ្វី? [វាទាក់ទងទៅនឹងទិសដៅនៃលំនាំទែម៉ូឌីណាមិចច្បាប់ទី ២ ទែម៉ូឌីណាមិច]

# ១. ទិសដៅនៃលំនាំនៃម៉ូឌីណាមិច

លំនាំមិនអាចត្រឡប់បាន និង លំនាំអាចត្រឡប់បាន

ក. ទឹកប្លែងភាពតាម*លំនាំមិនអាចត្រឡប់បាន*




កម្តៅហូរពីប្រអប់ទៅទឹកកកនិងទឹក គឺមិនអាចបញ្ច្រាសបាន។

ខ. ទឹកអាចប្លែងភាពតាម*លំនាំអាចត្រឡប់បាន*

[តែងតែស្ថិតនៅជិតលក្ខណ្ឌលំនឹងកម្តៅ]




ដោយគ្រាន់តែបង្កើនឬបញ្ចុះសីតុណ្ហភាពតែបន្តិចទេ យើងអាចធ្វើអោយកម្តៅហូរចេញពី ឬ ហូរចូលទៅប្រអប់

# ១. ទិសដៅនៃលំនាំនៃម៉ូឌីណាមិច

ឧទាហរណ៍ផ្សេងទៀតនៃ*លំនាំមិនអាចត្រឡប់បាន*

ការរីកមាឌដោយសេរី នៃឧស្ម័ន




ការអូសកំណាត់ឈើតុ បម្លែងថាមពលមេកានិចទៅជាកម្តៅតាមរយៈកកិត



# ១. ទិសដៅនៃលំនាំនៃទែម៉ូឌីណាមិច

ភាពឥតសណ្ដាប់ធ្នាប់(Disorder) និង លំនាំទែម៉ូឌីណាមិច មានទំនាក់ទំនងគ្នា




-ឈ្មោះសិស្ស 1000 នាក់ ត្រូវបានគេសរសេរលើក្រដាស(មួយសន្លឹកមួយឈ្មោះ)ដោយតម្រៀបគ្នាយ៉ាងរៀបរយ។ បន្ទាប់ពីគេបោះវាឡើងលើ វាធ្លាក់មកវិញ ឈ្មោះទាំងអស់នោះលែងរៀបរយទៀតហើយ។

-ខោអាវដែលអ្នកបត់ទុកក្នុងទូរខោអាវ មានលក្ខណៈរៀបរយជាងខោអាវដែលអ្នកប្រមូលមកដាក់ចោលលើនាប ឬ ការ៉ូ។

# ១. ទិសដៅនៃលំនាំនៃទែម៉ូឌីណាមិច

ភាពឥតសណ្ដាប់ធ្នាប់(Disorder) និង លំនាំទែម៉ូឌីណាមិច មានទំនាក់ទំនងគ្នា




-ស្រដៀងគ្នានេះដែរ ថាមពលស៊ីនេទិចម៉ាក្រូជាថាមពលដែលពាក់ព័ន្ធចលនានៃម៉ូលេគុលច្រើនដែលមានកូអរដោនេជាក់លាក់និងភាពរៀបរយ តែ ការផ្ទេរកម្ដៅពាក់ព័ន្ធទៅនឹងការផ្លាស់ប្ដូរថាមពលនៃចលនាដែលឥតសណ្ដាប់ធ្នាប់របស់ម៉ូលេគុល។ ហេតុដូចនេះហើយ បានជាការបម្លែងថាមពលមេកានិចទៅជាកម្ដៅគឺមានទំនាក់ទំនងទៅនឹងកំណើននៃភាពឥតសណ្ដាប់ធ្នាប់។

-យើងនឹងប្រើប្រាស់គ្រឿងអគ្គីសនីសំខាន់ពីរ(ម៉ាស៊ីនកម្ដៅ និង ម៉ាស៊ីនត្រជាក់)ដើម្បីសិក្សាស្វែងយល់ពីច្បាប់ទី២ ទែម៉ូឌីណាមិច។

# ២. ម៉ាស៊ីនកម្ដៅ

## ទិដ្ឋភាពទូទៅ

គ្រប់យានយន្តទាំងអស់ដែលប្រើម៉ូទ័រ( លើកលែងតែយានយន្តដែលប្រើអគ្គីសនីសុទ្ធ )សុទ្ធតែបើម៉ាស៊ីនកម្តៅដើម្បីធ្វើចលនា។

យានយន្ត Hybrid ប្រើម៉ាស៊ីនចំហេះក្នុង ( internal-combustion engine ) ដើម្បីជាជំនួយក្នុងការសាកអាគុយសម្រាប់ម៉ូទ័រអគ្គីសនី។









# ២. ម៉ាស៊ីនកម្ដៅ

## ថាមពលផ្សេងៗ

ថាមពលមេកានិចៈ ទឹកហូរ ខ្យល់បក់។

ថាមពលបានពីឥន្ធនៈផូស៊ីលៈ ធ្យូងថ្ម ប្រេង ឧស្ម័ន។

ថាមពលនុយក្លេអ៊ែរៈ ប្រតិកម្មនុយក្លេអ៊ែរ។












# ២. ម៉ាស៊ីនកម្តៅ

ពាក្យបច្ចេកទេស

ម៉ាស៊ីនកម្តៅ ( heat engine ) ជាម៉ាស៊ីនដែលបម្លែងថាមពលកម្តៅទៅជាកម្មន្ត។
សារធាតុដំណើរការនៃម៉ាស៊ីន ( Working substance of the engine ) ជាបរិមាណនៃរូបធាតុនៅក្នុងម៉ាស៊ីនដែលអាច ធ្វើអោយមានលំហូរចូលឬចេញនៃកម្តៅ រឹកឬបណ្ណែន និង ពេលខ្លះអាចប្លែងភាព។ [ល្បាយឧស្ម័ន-សាំង ក្នុងម៉ាស៊ីនចំហេះក្នុង។ ទឹកក្នុងម៉ាស៊ីនចំហាយទឹក]
លំនាំវដ្ត ( cyclic process ) ជាលំនាំដែលមានសារធាតុដំណើរការវិលមកភាពដើម។
ប្រភពក្តៅ ( hot reservoir ) ជាប្រភពដែលអាចផ្តល់កម្តៅដ៏ច្រើនទៅអោយសារធាតុដំណើរការ ហើយសីតុណ្ហភាពរបស់ប្រភពខ្លួនឯងនៅតែថេរ ( $T_H$ )។
ប្រភពត្រជាក់ ( cold reservoir ) ជាប្រភពដែលអាចស្រូបកម្តៅដ៏ច្រើនពីម៉ាស៊ីន ហើយសីតុណ្ហភាពរបស់ប្រភពខ្លួនឯងនៅតែថេរ ( $T_C$ )។

# ២. ម៉ាស៊ីនកម្តៅ

ម៉ាស៊ីនកម្តៅមួយស្រូបកម្តៅ $Q_H$ ពីប្រភពក្តៅមួយ បម្លែងថាមពលមួយផ្នែកទៅជាកម្មន្ត និង បញ្ចេញកម្តៅ $|Q_C|$ ទៅប្រភពត្រជាក់។

ទិន្នផលកម្តៅនៃម៉ាស៊ីនកម្តៅ ( $e$ ) ជាទំហំដែលវាស់ភាគនៃបរិមាណកម្តៅស្រូបពីប្រភពក្តៅ ដែលត្រូវបានបម្លែងទៅជាកម្មន្ត។

$$e = \frac{W}{Q_H} = 1 + \frac{Q_C}{Q_H} = 1 - \left|\frac{Q_C}{Q_H}\right|$$



# ២. ម៉ាស៊ីនកម្តៅ



អនុវត្តន៍ក្នុងជីវសាស្ត្រៈ ទិន្នផលជីវសាស្ត្រ

ទោះបីជាសារពាង្គកាយជីវសាស្ត្រមិនមែនជាម៉ាស៊ីនកំដៅក៏ដោយ ក៏គោលគំនិតនៃទិន្នផលនៅតែអាចអនុវត្តបានៈ $e$ គឺជាផលធៀបនៃកម្មន្តដែលបានធ្វើ ទៅនឹង ថាមពលដែលត្រូវបានប្រើដើម្បីធ្វើកម្មន្តនោះ។ ដើម្បីហាត់ប្រាណនៅលើកង់ស្ថានី( stationary bike ) រាងកាយរបស់អ្នកត្រូវតែបំប្លែងថាមពលសម្ព័ន្ធគីមីនៃជាតិស្ករទៅជាថាមពលសម្ព័ន្ធគីមីនៅក្នុង ATP ( adenosine triphosphate ) បន្ទាប់មកបំប្លែងថាមពលពី ATP ទៅជាចលនានៃសាច់ដុំជើងរបស់អ្នក ហើយចុងក្រោយបំប្លែងសាច់ដុំទៅជាចលនានៃឈ្នាន់។ ទិន្នផលនៃដំណើរការទាំងមូលនេះគឺមានត្រឹមតែ 25% ប៉ុណ្ណោះ។ 75% នៃថាមពលដែលនៅសល់ត្រូវបានបញ្ចេញពីខ្លួយកូសទៅជាកម្តៅ។

# មេរៀនទី៤ ÷ ច្បាប់ទី ២ ទែម៉ូឌីណាមិច



ក្រុម សុណា 2024

## ១. ទិសដៅនៃលំនាំទែម៉ូឌីណាមិច

លំនាំមិនអាចត្រឡប់បាន និង លំនាំអាចត្រឡប់បាន

ក. ទឹកប្លែងភាពតាម *លំនាំមិនអាចត្រឡប់បាន*




កម្ដៅហូរពីប្រអប់ទៅទឹកកកនិងទឹក គឺមិនអាចបញ្ច្រាសបាន។

ខ. ទឹកអាចប្លែងភាពតាម *លំនាំអាចត្រឡប់បាន*

[តែងតែស្ថិតនៅជិតលក្ខណ្ឌលំនឹងកម្ដៅ]




ដោយគ្រាន់តែបង្កើនឬបញ្ចុះសីតុណ្ហភាពតែបន្តិចទេ យើងអាចធ្វើអោយកម្ដៅហូរចេញពី ឬ ហូរចូលទៅប្រអប់

# ២. ម៉ាស៊ីនកម្ដៅ

ម៉ាស៊ីនកម្ដៅមួយស្រូបកម្ដៅ $Q_H$ ពីប្រភពក្ដៅមួយ បម្លែងថាមពលមួយផ្នែកទៅជាកម្មន្ត និង បញ្ចេញកម្ដៅ $|Q_C|$ ទៅប្រភពត្រជាក់។

ទិន្នផលកម្ដៅនៃម៉ាស៊ីនកម្ដៅ($e$) ជាទំហំដែលវាស់ភាគនៃបរិមាណកម្ដៅស្រូបពីប្រភពក្ដៅ ដែលត្រូវបានបម្លែងទៅជាកម្មន្ត។

$$e = \frac{W}{Q_H} = 1 + \frac{Q_C}{Q_H} = 1 - \left|\frac{Q_C}{Q_H}\right|$$




# ៣. ម៉ាស៊ីនចំហេះក្នុង




(1) **Intake stroke:** Piston moves down, causing a partial vacuum in cylinder; gasoline–air mixture enters through intake valve.

(2) **Compression stroke:** Intake valve closes; mixture is compressed as piston moves up.

(3) **Ignition:** Spark plug ignites mixture.

(4) **Power stroke:** Hot burned mixture expands, pushing piston down.

(5) **Exhaust stroke:** Exhaust valve opens; piston moves up, expelling exhaust and leaving cylinder ready for next intake stroke.

# ៣. ម៉ាស៊ីនចំហេះក្នុង

វដ្ត Otto: វដ្តគម្រូនៃលំនាំទែម៉ូឌីណាមិចក្នុងម៉ាស៊ីនសាំង។




# ៣. ម៉ាស៊ីនចំហេះក្នុង

វដ្ត Otto




លំនាំ bc និង da មានមាឌថេរ។

$$Q_H = nC_V(T_c - T_b) > 0, \qquad Q_C = nC_V(T_a - T_d) > 0$$

យើងបាន

$$e = \frac{Q_H + Q_C}{Q_H} = \frac{T_c - T_b + T_a - T_d}{T_c - T_b}$$

លំនាំអាដ្យាបាទិច: ab: $T_a(rV)^{\gamma-1} = T_b V^{\gamma-1}$ និង cd: $T_d(rV)^{\gamma-1} = T_c V^{\gamma-1}$

$$e = \frac{T_d r^{\gamma-1} - T_a r^{\gamma-1} + T_a - T_d}{T_d r^{\gamma-1} - T_a r^{\gamma-1}} = \frac{(T_d - T_a)(r^{\gamma-1} - 1)}{(T_d - T_a) r^{\gamma-1}}$$

$$e = 1 - \frac{1}{r^{\gamma-1}}$$

$r$: មេគុណបណ្ណែន

$\gamma := C_p/C_V$

ឧ. បើ $r = 8, \gamma = 1.4$
$\rightarrow e = 0.56$ ឬ 56%

# ៣. ម៉ាស៊ីនចំហេះក្នុង

វដ្តម៉ាស៊ីនម៉ាស៊ូត:




ចំណុចខុសពីម៉ាស៊ីនសាំង៖

-មិនមានឥន្ទនៈនៅដើមទីទេ គេបញ្ចូលវានៅពេលបណ្ណែនខ្លាំង

-មិនមានប៊ូស៊ីទេ។

-ទិន្នផលខ្ពស់ជាង។ $e = 65\% - 70\%$




# ៤. ម៉ាស៊ីនទូរទឹកកក




ច្បាប់ទី ១ ទែម៉ូឌីណាមិច

$$Q_H + Q_C - W = 0 \quad \text{ឬ} \quad -Q_H = Q_C - W$$

ទម្រង់ទូទៅសម្រាប់ម៉ាស៊ីនកម្ដៅ និង ត្រជាក់៖ $|Q_H| = |Q_C| + |W|$

ករណីទូរទឹកកកគឺគេចង់ចំណាយកម្មន្តតិចបំផុតដើម្បីផ្ទេរកម្ដៅចេញពីប្រភពត្រជាក់អោយបានច្រើនបំផុត។ មេគុណដំណើរការ (coefficient of performance)៖

$$K = \frac{|Q_C|}{|W|} = \frac{|Q_C|}{|Q_H| - |Q_C|}$$

# ៤. ម៉ាស៊ីនទូរទឹកកក

## ទូរទឹកកកជាក់ស្តែង




③ សន្ទនីយរីកមាឌតាមលំនាំអាដ្យាបាទិចតាមរយៈវ៉ាល់ពង្រីក

② សន្ទនីយដែលណែនក្នុងគ្រឿងកំណ មានសីតុណ្ហភាពខ្ពស់ជាងខ្យល់ខាងក្រៅ ដូចនេះវាបញ្ចេញកម្តៅ $|Q_H|$ ទៅខ្យល់។ សន្ទនីយមួយផ្នែកកំណក្លាយជារាវ។




④ ក្រោយការរីក សន្ទនីយក្នុងគ្រឿងបង្ហួតមានសីតុណ្ហភាពទាបជាងផ្នែកខាងក្នុងនៃម៉ាស៊ីនត្រជាក់។ ដូចនេះសន្ទនីយស្រូបកម្តៅ $|Q_C|$ បញ្ចុះសីតុណ្ហភាពរបស់គ្រឿងផ្សេងៗនៃម៉ាស៊ីនទូរទឹកកក។ សន្ទនីយមួយផ្នែកហួតក្លាយចំហាយ។

① គ្រឿងបណ្ណែនស្រូបចូលនូវសន្ទនីយរបស់ម៉ាស៊ីនទូរទឹកកក ធ្វើកម្មន្ត $|W|$ ទៅលើសន្ទនីយដើម្បីបណ្ណែនវាតាមលំនាំអាដ្យាបាទិច ហើយបញ្ជូនសន្ទនីយទៅរបុំកំណក។

⑤ សន្ទនីយត្រឡប់ទៅគ្រឿងបណ្ណែនវិញ ហើយវដ្តថ្មីចាប់ផ្តើម។

# ៤. ម៉ាស៊ីនទូរទឹកកក

## ម៉ាស៊ីនត្រជាក់ជាក់ស្តែង




ករណីម៉ាស៊ីនត្រជាក់គឺគេចង់ចំណាយអានុភាព( $P = |W|/t$ ) តិចបំផុតដើម្បីអោយអត្រាកម្តៅ( $H = |Q_C|/t$ ) ផ្ទេរចេញពីប្រភពត្រជាក់មានតម្លៃធំបំផុត។

មេគុណដំណើរការ (coefficient of performance)៖

$$K = \frac{|Q_C|}{|W|} = \frac{H}{P}$$

តម្លៃទូទៅ $H = 1500 - 3000\ W$ និង $P = 600 - 1200\ W$ ហើយ $K \sim 3$។

# ៤. ម៉ាស៊ីនទូរទឹកកក

ម៉ាស៊ីនត្រជាក់ [ដកស្រង់ពី កាតាឡុក DAIKIN]

https://www.daikin.com.sg/resources/ck/files/catalogue/Daikin_SGPCR2001A_STC.pdf

**FTKS25/35D**

| **Model name** | **Indoor unit** | | **FTKS25DVM** |
|---|---|---|---|
| | **Outdoor unit** | | **RKS25GVMG** |
| Capacity | Rated (Min.-Max.) | kW | 2.5 (1.2-3.2) |
| | | Btu/h | 8,500 (4,050-10,900) |
| Power supply | | | |
| Running current | Rated | A | 3.9 |
| Power consumption | Rated (Min.-Max.) | W | 0.7kW (295-1,050) |
| COP | Rated | W/W | 3.57 |

$$COP = \frac{\text{Capacity (W)}}{\text{Power consumption (W)}}$$

# ៤. ទូរទឹកកក

សំណួរ

តើអ្នកអាចបញ្ចុះសីតុណ្ហភាពផ្ទះរបស់អ្នកដោយបើទ្វារទូរទឹកកកដែរឬទេ? ចូរពន្យល់។

# ៥. ច្បាប់ទី២ នៃទែម៉ូឌីណាមិច

ច្បាប់ទី២ទែម៉ូឌីណាមិច (ពំនោលម៉ាស៊ីនកម្តៅ)៖ ប្រព័ន្ធមួយមិនអាចដើម្បីដំណើរការ ដោយស្រូបយកកម្តៅពីប្រភពដែលមានសីតុណ្ហភាពតែមួយ ហើយបម្លែងកម្តៅទាំងស្រុងទៅជាកម្មន្តមេកានិចដោយនៅទីបញ្ចប់ភាពរបស់ប្រព័ន្ធដូចគ្នានឹងភាពដែលវាបានចាប់ផ្តើម។

ច្បាប់ទី២ទែម៉ូឌីណាមិច (ពំនោលម៉ាស៊ីនទូរទឹកកក)៖ មិនមានលំនាំណាមួយដែលអាចបង្ហូរកម្តៅចេញពីប្រភពត្រជាក់ទៅប្រភពក្តៅដោយឯកឯងនោះទេ។

ច្បាប់ទីមួយបដិសេធលទ្ធភាពនៃការបង្កើត ឬ បំផ្លាញថាមពល។
ច្បាប់ទីពីរដាក់ដែនកំណត់*ភាពអាចរកបាន* (availability) នៃថាមពល និងវិធីដែលវាអាចប្រើបាន និងបំប្លែង។
→លំនាំដែលបម្លែងកម្មន្តទៅជាកម្តៅ និង លំនាំដែលកម្តៅហូរពីប្រភពក្តៅទៅប្រភពត្រជាក់ដោយសារមានសីតុណ្ហភាពខុសគ្នា ជាលំនាំមិនអាចត្រឡប់បាន។

# ៥. ច្បាប់ទី២ នៃទែម៉ូឌីណាមិច

ច្បាប់ទី២ទែម៉ូឌីណាមិច (ពំនោលម៉ាស៊ីនកម្តៅ)




If a workless refrigerator were possible, it could be used in conjunction with an ordinary heat engine to form a 100%-efficient engine, converting heat $Q_H - |Q_C|$ completely to work.

# ៥. ច្បាប់ទី២ នៃទែម៉ូឌីណាមិច

ច្បាប់ទី២ទែម៉ូឌីណាមិច( ពំនោលម៉ាស៊ីនទូរទឹកកក )




If a 100%-efficient engine were possible, it could be used in conjunction with an ordinary refrigerator to form a workless refrigerator, transferring heat $Q_C$ from the cold to the hot reservoir with no input of work.



# ៥. ច្បាប់ទី២ នៃទែម៉ូឌីណាមិច



សំណួរ៖ តើម៉ាស៊ីនកម្តៅទិន្នផល១០០% មិនគោរពតាមច្បាប់ទី១ទែម៉ូឌីណាមិចដែរឬទេ? ចុះករណីម៉ាស៊ីនទូរទឹកកកដែលមិនប្រើកម្មន្ត? ចូរពន្យល់។

# ៦. វដ្តកាកណូ

ម៉ាស៊ីនមិនអាចមានទិន្នផល១០០%។ លោកកាកណូ(Sadi Carnot)បានឆ្លើយនូវសំណួរៈ បើម៉ាស៊ីនដំណើរការចន្លោះប្រភពក្តៅនិងត្រជាក់ ($T_H$ និង $T_C$) តើទិន្នផលខ្ពស់បំផុតដែលគេអាចទទួលបានគឺប៉ុន្មាន?

គោលគំនិតៈ បម្លែងពីកម្មន្តទៅជាកម្តៅជាលំនាំមិនអាចអាចត្រឡប់បាន។ ដូចនេះយើងត្រូវព្យាយាមជៀសវាងលំនាំបែបនេះ។

# ៦. វដ្តកាកណូ

ជំហាននៃវដ្តកាកណូ(សារធាតុដំណើរការជាឧស្ម័នបរិសុទ្ធ)ៈ




១. ឧស្ម័នរីកមាឌតាមលំនាំអ៊ីសូទែមនៅសីតុណ្ហភាព $T_H$ និងស្រូបកម្តៅ $Q_H$ (លំនាំ ab)
២. ឧស្ម័នរីកមាឌតាមលំនាំអាដ្យាបាទិចរហូតធ្លាក់សីតុណ្ហភាពដល់ $T_C$ (លំនាំ bc)
៣. ឧស្ម័នត្រូវបានបណ្ណែនតាមលំនាំអ៊ីសូទែមនៅសីតុណ្ហភាព $T_C$ និងបញ្ចេញកម្តៅ $|Q_C|$ (លំនាំ cd)
៤. ឧស្ម័នត្រូវបានបណ្ណែនទៅភាពដើមតាមលំនាំអាដ្យាបាទិចនៅសីតុណ្ហភាពដល់ $T_H$ (លំនាំ da)

# ៦. វដ្តកាកណូ

$$Q_{\mathrm{H}} = W_{ab} = nRT_H \ln\frac{V_b}{V_a}$$

$$Q_{\mathrm{C}} = W_{cd} = nRT_C \ln\frac{V_d}{V_c}$$

$$= -nRT_C \ln\frac{V_c}{V_d}\ (V_d < V_c \rightarrow Q_C < 0)$$

$$\frac{Q_{\mathrm{C}}}{Q_{\mathrm{H}}} = -\left(\frac{T_{\mathrm{C}}}{T_{\mathrm{H}}}\right)\frac{\ln(V_c/V_d)}{\ln(V_b/V_a)}$$

តាមលំនាំអាដ្យាបាទិច

$T_{\mathrm{H}}V_b^{\gamma-1} = T_{\mathrm{C}}V_c^{\gamma-1}$ និង $T_{\mathrm{H}}V_a^{\gamma-1} = T_{\mathrm{C}}V_d^{\gamma-1}$

យើងបាន $\frac{V_b}{V_a} = \frac{V_c}{V_d}$

$$e_{\mathrm{Carnot}} = 1 - \frac{T_{\mathrm{C}}}{T_{\mathrm{H}}} = \frac{T_{\mathrm{H}} - T_{\mathrm{C}}}{T_{\mathrm{H}}}$$




# ៦. វដ្តកាកណូ

## ម៉ាស៊ីនទូរទឹកកកកាកណូ

ដោយសារលំនាំទាំងអស់ក្នុងវដ្តកាកណូ ជាលំនាំអាចត្រឡប់បាន នោះគេអាចបម្លែងពីម៉ាស៊ីនកម្ដៅទៅម៉ាស៊ីនទូរទឹកកកដោយធ្វើអោយវដ្តទាំងមូលដើរបញ្ច្រាស។

មេគុណដំណើរការ (coefficient of performance)៖

$$K = \frac{|Q_{\mathrm{C}}|}{|Q_{\mathrm{H}}| - |Q_{\mathrm{C}}|}$$

$$K_{\mathrm{Carnot}} = \frac{T_{\mathrm{C}}}{T_{\mathrm{H}} - T_{\mathrm{C}}}$$

ដំណើរការបញ្ច្រាសពីវដ្តកាកណូខាងក្រោម



# ៦. វដ្តកាកណូ

សំណួរ

អ្នកជំនាញច្នៃប្រឌិតម្នាក់(ដែលកំពុងស្វែងរកការគាំទ្រផ្នែកហិរញ្ញវត្ថុ)បានមកជួបអ្នក ដោយបានរៀបរាប់ពីគំនិតនៃការធ្វើអោយម៉ាស៊ីនសាំងមួយអាចដំណើរការតាមវដ្តទែម៉ូឌីណាមិចពិសេសម្យ៉ាង។ ការរចនា (design)របស់គាត់គឺ ធ្វើម៉ាស៊ីននេះពីទង់ដែងនិងខ្យល់ត្រជាក់សុទ្ធសាត។ គាត់បានអះអាងថាម៉ាស៊ីននេះមានទិន្នផល 85%។ តើអ្នកនឹងវិនិយោគលើម៉ាស៊ីនថ្មីនេះដែរឬទេ? សីតុណ្ហភាពខ្យល់ត្រជាក់ 300 K ហើយ ទង់ដែងរលាយនៅសីតុណ្ហភាព 1356 K។

# មេរៀនទី៤ ÷ ច្បាប់ទី ២ ទែម៉ូឌីណាមិច

## លំហាត់ពិភាក្សាក្រុម

ក្រុម សុណា 2024

## ៣. ម៉ាស៊ីនចំហេះក្នុង

លំហាត់4

ចំពោះម៉ាស៊ីនមានវដ្ត Otto ដែលទំហំស៊ីឡាំង និង មេគុណបណ្ណែនថេរ តើករណីខាងក្រោមណាខ្លះក្នុងដ្យាក្រាម pV ខាងស្តាំដែលផ្លាស់ប្តូរ ប្រសិនបើអ្នកបង្កើនបរិមាណឥន្ធនៈ (ក្នុងមួយវដ្ត)ទៅតម្លៃពីរដងនៃតម្លៃដើម។

(i) គម្លាតតាមទិសឈរនៃចំណុច b និង c។

(ii) គម្លាតតាមទិសឈរនៃចំណុច a និង d។

(iii) គម្លាតតាមទិសដេកនៃចំណុច b និង a។



# ៦. វដ្តកាកណូ

លំហាត់5

ម៉ាស៊ីនកាកណូមួយស្រូបកម្ដៅ 2000 J ពីប្រភពដែលមានសីតុណ្ហភាព 500 K ហើយធ្វើកម្មន្តខ្លះនិងបញ្ចេញកម្ដៅទៅប្រភពមួយផ្សេងទៀតដែលមានសីតុណ្ហភាព 350 K។ ចូរគណនាកម្មន្តដែលបានបំពេញដោយម៉ាស៊ីន កម្ដៅដែលបានបញ្ចេញ និង ទិន្នផលកម្ដៅ។




# ៦. វដ្តកាកណូ

លំហាត់6

សន្មត់ថាឧស្ម័នឌីអាតូម($\gamma = 1.40$, $p_a = 10.0 \times 10^5$ Pa) ចំនួន 0.200 ម៉ូលស្ថិតនៅក្រោមវដ្តកាកណូរវាងប្រភពកម្ដៅពីរដែលមានសីតុណ្ហភាព 227 °C និង 27 °C ដូចក្នុងរូបខាងស្ដាំ។ មាឌឧស្ម័នបានកើនដល់តម្លៃពីរដងនៃតម្លៃដើមក្នុងលំនាំអ៊ីសូទែម $a \to b$។

ក. ចូរគណនាមាឌនិងសំពាធឧស្ម័នត្រង់ $a$, $b$, $c$ និង $d$។

ខ. រក $Q$, $W$, និង $\Delta U$ ក្នុងលំនាំនិមួយៗ និង លំនាំពេញមួយវដ្ត។

គ. ចូគណនាទិន្នផលតាមរយៈលទ្ធផលសំនួរ (ខ) ហើយប្រៀបធៀបវាទៅនឹងតម្លៃដែលគណនាតាមរូបមន្ត $e_{\text{Carnot}} = 1 - \frac{T_C}{T_H}$។



# ៦. វដ្តកាកណូ

លំហាត់7

ប្រសិនបើវដ្តក្នុងលំហាត់មុននេះ ដំណើរការបញ្ច្រាសវិញ (រូបខាងស្តាំនេះជារូបលំហាត់មុន) នោះវាជាម៉ាស៊ីនបង្កក( ទូរទឹកកក) ចូរគណនាមេគុណដំណើរការ (coefficient of performance)។

ដំណើរការបញ្ច្រាសពីវដ្តកាកណូខាងក្រោម



**កិច្ចការត្រូវអនុវត្តដើម្បីសម្រេចលទ្ធផលសិក្សារំពឹងទុក៖**

- ក្រោយពីបញ្ចប់ការសិក្សាមុខវិជ្ជានេះដោយជោគជ័យអ្នកសិក្សានឹង៖
  ១. កិច្ចការទី ១៖...........
  ២. កិច្ចការទី ២៖...........
  ៣. កិច្ចការទី ៣៖...........
  ៤. កិច្ចការទី ៤៖...........
  ៥. កិច្ចការទី ៥៖...........